# ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩

## ចាប់បានហើយមេការល្បីរន្ទឺជួញដូរមនុស្សយូរឆ្នាំនៅក្រុងតាខ្មៅ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩ ម៉ោង ១០:៣៨ ប៊ឹង ធដា

ខេត្តកណ្ដាល ៖ ប្រតិបត្តិការណ៍ដ៏ក្ដៅគគុកនេះបានធ្វើឱ្យមហាជនត្រេកអរយ៉ាងខ្លាំង បន្ទាប់ពីនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្ត ចុះបង្ក្រាបករណីសញ្ជួរកម្មសង្គ្រោះជនរងគ្រោះ៦នាក់ និងឃាត់ខ្លួនមេការម្នាក់ដែលកំពុងល្បីរន្ទឺខាងរកស៊ីជួញដូរមនុស្សយូរឆ្នាំណាស់មកហើយ។ ហេតុការណ៍ចុះបង្ក្រាបនេះធ្វើឡើងនៅម៉ោង៩និង៣០នាទីយប់ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ នៅចំណុចផ្ទះ សំណាក់ឃីហោ សុខ វិសាល ផ្លូវលេខ១១០B ភូមិថ្មី២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ។

ជនសង្ស័យជាមេការល្បីរន្ទឺខាងលើឈ្មោះ ទូច ចាន់ ភេទប្រុស អាយុ៣៥ឆ្នាំ ហៅក្រៅក្រពុំឈូក មានទីលំនៅបច្ចុប្បន្ននៅផ្ទះជួលក្នុងភូមិថ្មី២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល និងមានទីលំនៅកំណើតនៅភូមិអង្គបាន ឃុំអង្គបាន ស្រុកកងមាស ខេត្តកំពង់ចាម ចំណែកជនរងគ្រោះ១-ឈ្មោះ លីហួ អនីតិជន ២-ឈ្មោះ ម៉ៅ រក្សា ៣-ឈ្មោះ សៀង គា ៤-ឈ្មោះ ជី ចាន់លីណា ៥-ឈ្មោះ មុន លក្ខិណា និង៦-ឈ្មោះ ពេជ្រ រតនា។

តាមនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានឱ្យដឹងថា ដោយមានសេចក្ដីរាយការណ៍ពីពលរដ្ឋថា មានមេការម្នាក់បាននាំស្រីៗជាច្រើននាក់ទៅផ្ទះសំណាក់ វិសាល ស្ថិតនៅភូមិថ្មី សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។ ភ្លាមនោះលោក រស់ សារិន ប្រធានការិយាល័យការជួញដូរមនុស្ស សហការជាមួយកម្លាំងនគរបាលមូលដ្ឋានចុះធ្វើការឆែកឆេរ ស្រាប់តែ ឃើញមនុស្សប្រុសស្រីជាច្រើននាក់នៅក្នុងបន្ទប់ផ្ទះសំណាក់ ដូចដែលពលរដ្ឋបានរាយការណ៍មកពិតមែន ។

បច្ចុប្បន្នជនសង្ស័យ ត្រូវបានឃាត់ខ្លួនបញ្ជូនមកការិយាល័យជំនាញខេត្ត ចំណែកជនរងគ្រោះ ទាំង៦នាក់បាននាំមកការិយាជំនាញខេត្ត ក្រោមការជួយឧបត្ថម្ភពីអង្គការមេត្រីអន្តរជាតិ៕

## ពលករខ្មែរឆ្លងដែនខុសច្បាប់ ២នាក់ ត្រូវភាគីថៃបញ្ជូនត្រឡប់មកវិញ

https://www.facebook.com/ General Department of Immigration - GDI **February 27 at 11:04 PM**

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃ ២នាក់ នារសៀលថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។ កម្លាំងនគរបាលប៉ុស្តិ៍ បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ពលរដ្ឋខ្មែរម្នាក់ ត្រូវបានថៃបញ្ជូនមកវិញ ដោយសារឆ្លងដែនខុសច្បាប់

https://www.facebook.com/ General Department of Immigration - GDI **February 27 at 5:08 PM**

ឧត្តរមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ បានទទួលពលរដ្ឋខ្មែរម្នាក់ ពីភាគីថៃ នាព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

# ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩

## លោកមន្ត្រីយោធាម្នាក់ឈ្មោះរ៉ាមាន់ចឹកល្បីល្បាញរាប់ឆ្នាំខាងរកស៊ីបទល្មើសឈើគ្រញ៉ូងឆ្លងដែននិងគៀងគពលរដ្ឋស្លូតត្រង់អោយលួចឆ្លងដែនទៅកាប់ឈើក្នុងទឹកដីប្រទេសថៃ

https://www.facebook.com/cpnnews.info/ សារព័ត៌មាន ចក្រភពព័ត៌មាន CPN News 04-03-2019

ខេត្តឧត្តរមានជ័យៈ បុរសជើងខ្លាំងជាមន្ត្រីយោធាម្នាក់ឈ្មោះរ៉ាមាន់ចឹកល្បីល្បាញពេញស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទរឿងរកស៊ីបទល្មើសឈើគ្រញ៉ូងឆ្លងដែន និងដើរគៀងគពលរដ្ឋស្លូតត្រង់ជាច្រើននាក់ អោយឆ្លងដែនតាមច្រកប្រទាលជ្រុំ និងច្រកអន្លង់អាំងទៅលួចកាប់ឈើគ្រញ៉ូងក្នុងទឹកដីប្រទេសថៃ។

តាមសេចក្តីរាយការណ៍ ចេញពីច្រកប្រទាលជ្រុំ និងច្រកអន្លង់អាំង ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យមកថា លោកមន្ត្រីយោធាម្នាក់ឈ្មោះ រ៉ា មាន់ចឹក បានធ្វើការប្រមូលទិញឈើគ្រញ៉ូងយ៉ាងអនាធិបតេយ្យតាមខ្សែរបន្ទាត់ព្រំដែនខ្មែរថៃ និងប្រមូលទិញឈើផ្តាច់មុខនៅតំបន់ទិសទី២ នៃសមរភូមិមុខ ហើយបានដើរគៀងគពលរដ្ឋស្លូតត្រង់ជាច្រើនអោយលួចឆ្លងដែនទៅកាប់ឈើគ្រញ៉ូងក្នុងទឹកដីប្រទេសថៃ ដើម្បីយកមកលក់អោយខ្លួនដោយមិនគិតពីអាយុជីវិតរបស់ពលរដ្ឋ ត្រូវទាហ៊ានយោធាថៃ ចាប់ខ្លួន ឬត្រូវបាញ់សម្លាប់ ។ ពោលៈ គឺជាមនុស្សអត្មានិយម អោយតែខ្លួនមានបានចង់អ្នកណាស្លាប់អីស្លាប់ទៅ។ ដោយសារតែលោកមន្ត្រីយោធាម្នាក់ នេះមានលុយមានអំណាចនិងមានតួនាទីធំនៅក្នុងជួរមន្ត្រីយោធា បានជាគេអាចដើរប្រមូលទិញឈើគ្រញ៉ូងយ៉ាងអនាធិបតេយ្យតាមខ្សែរបន្ទាត់ព្រំដែនខ្មែរថៃបានយ៉ាងរលូនរាប់ឆ្នាំនិងធ្វើអោយមន្ត្រីអាជ្ញាធរមានសម្ថតកិច្ច មន្ត្រីពាក់ពន្ធ័ក្នុងខេត្តឧត្តតមានជ័យកោតញញើតខ្លាចរអាពេលឃើញលោកដឹកបទល្មើសឈើគ្រញ៉ូងកាត់មុខម្តងធ្វើអោយមន្ត្រីមួយចំនួនមិនហ៊ានបង្ក្រាប។

តើឯកឧត្តម ប៉ែន កុសល្យ អភិបាលខេត្តលោកគិតយ៉ាងណាចំពោះបទល្មើសឆ្លងដែនដែលកំពុងកើតមានឡើងរាលថ្ងៃ ជាពិសេសលោកមន្ត្រីយោធាឈ្មោះរ៉ាមាន់ចឹកដែលល្បីល្បាញថាជាមេឈ្មួញរកស៊ីបទល្មើសឈើគ្រញ៉ូងរាប់ឆ្នាំគ្មានលោកមន្ត្រីអាជ្ញាធរ មានសម្ថតកិច្ច មន្ត្រីពាក់ពន្ធ័ក្នុងខេត្តមួយណាហ៊ានបង្ក្រាប ចុះឯកឧត្តមអភិបាលខេត្តនឹងមានវិធានការបង្ក្រាបដែរទេ.? ឬមួយឯកឧត្តមសុខចិត្តអោយលោកមន្ត្រីយោធាឈ្មោះរ៉ាមាន់ចឹងធ្វើព្យុះធ្វើភ្លៀងបន្តទៀតទាន ៕ ដោយៈ សាន់រិទ្ធ

## ពលករចំណាកស្រុក» ជារឿងគួរកើតទុក្ខ ឬគួររីករាយ? មកស្តាប់អ្នកជំនាញ!

https://cambonomist.com/news/ ដោយ ចាន់ មង្គល

រឿងចំណាកស្រុករបស់ប្រជាពលរដ្ឋកម្ពុជា ទៅធ្វើការងារនៅក្រៅប្រទេស ដូចជា ថៃ និងកូរ៉េ ជាដើម ត្រូវបានគេមើលឃើញថា គឺជារឿងក្តៅមួយ ក្នុងចំណោមរឿងក្តៅផ្សេងៗទៀត ដែលអ្នកតាមដានសង្គម ក៏ដូចជា អ្នកនយោបាយមួយចំនួនផងដែរ តែងតែយកមកជជែកយ៉ាងផុសផុល និងយកទៅរិះគន់ការដឹកនាំរបស់រាជរដ្ឋាភិបាល។

វិភាគសេដ្ឋកិច្ច អំពី ចំណាកស្រុកៈ

ទោះយ៉ាងណា បើតាមអ្នកជំនួញធំៗ ក៏ដូចជាអ្នកជំនាញសេដ្ឋកិច្ចល្បីៗ បានអះអាងយ៉ាងជាក់លាក់ ដោយផ្អែកតាមការសិក្សានិងបទពិសោធន៍ថា ការចំណាកស្រុកគឺជាចន្លនិន្នាការសេដ្ឋកិច្ច ដែលមិនអាចហាមឃាត់បានឡើយ ហើយប្រទេសណាក៏មានចំណាកស្រុកដែរ មិនមែនមានតែកម្ពុជាមួយតែឯកឯងនោះឡើយ។ តាមរយៈ ខេមបូណូមីស ក្រុមអ្នកជំនាញសេដ្ឋកិច្ចនិងធុរជនល្បីៗជាច្រើន បានចេញមុខអះអាងថា ការចំណាកស្រុកពីសំណាក់ជនជាតិខ្មែរទៅរកការងារនៅក្រៅប្រទេស គឺជានិន្នាការវិជ្ជមាន សម្រាប់គាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិរយៈពេលយូរអង្វែង។ ការអះអាងរបស់ក្រុមអ្នកជំនួញ និងអ្នកជំនាញដ៏លេចធ្លោទាំងអស់នេះ ស្របពេលដែលកម្ពុជាមានពលករចំណាកស្រុកទៅធ្វើការងារនៅក្រៅប្រទេស ប្រមាណជាង ១,២លាននាក់ និងបានធ្វើប្រាក់មកស្រុកកំណើតប្រមាណ

២ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំៗ។ នេះបើយោងតាមទិន្នន័យរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីឆ្នាំ២០១៧។ មានប្រទេសចំនួន ៧ ដែលកម្ពុជា បានបញ្ជូនពលករឲ្យទៅធ្វើការ មានដូចជា ប្រទេសថៃ កូរ៉េខាងត្បូង ជប៉ុន សាំងហ្គាពួរ ម៉ាឡេស៊ី អារ៉ាប់ប៊ីសាអូឌីត និងទីក្រុងហុងកុង ប្រទេសចិន។ ថ្វីត្បិតតែការចំណាកស្រុកមានច្រើនក៏ពិតមែន ក៏ប៉ុន្តែមន្ត្រីជាន់ខ្ពស់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីពេលថ្មីៗនេះ បានលើកឡើងថា ការធ្វើចំណាកស្រុករបស់ពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេសនេះ កុំថា ជារឿងបញ្ហាសេដ្ឋកិច្ចធំដុំឲ្យសោះ ផ្ទុយទៅវិញត្រូវយកចិត្តទុកដាក់ និងគាំទ្រសម្រួលការងារ និងការពារសិទ្ធិពួកគាត់ ជាប្រយោជន៍បង្កើនចំណូលសេដ្ឋកិច្ចគ្រួសារឲ្យកាន់តែប្រសើរឡើង។

*សំណួរសួរថា តើហេតុអ្វីបានមានពលករចំណាកស្រុក?*

ឯកឧត្តម វង្សី វិស្សុត រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា ការចំណាកស្រុករបស់ប្រជាពលរដ្ឋខ្មែរទៅធ្វើការនៅក្រៅប្រទេសដោយសារតែហេតុផលសេដ្ឋកិច្ច ហេតុផលសង្គម និងគម្លាតប្រាក់ឈ្នួលពលកម្ម ដែលនៅប្រទេសថៃ កូរ៉េ និងជប៉ុន គឺមានប្រាក់ឈ្នួលខ្ពស់ ធៀបនឹងបណ្តាប្រទេសផ្សេងទៀតនោះ ដូច្នេះ យើងត្រូវតែលើកទឹកចិត្ត និងគាំទ្រដល់ពួកគាត់។ ពិសេស គឺការធានានូវសុខសុវត្ថិភាពជូនពួកគាត់ ពេលបំពេញការងារតែម្តង។

ពាក់ព័ន្ធទៅនឹងចំណាកស្រុកនេះដែរ លោកឧកញ៉ា សៀ ឫទ្ធី ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយកក្រុមហ៊ុន WorldBridge Group ដែលជាវិនិយោគិនលេចធ្លោមួយរូបនៅកម្ពុជា បានលើកឡើងដែរថា ការធ្វើចំណាកស្រុករបស់ពលករ មិនមែនមានតែនៅកម្ពុជានោះទេ គ្រប់ប្រទេសលើពិភពលោក ក៏មានចំណាកស្រុកដូចគ្នាដែរ ហើយប្រទេសខ្លះមានចំណាកស្រុកច្រើនជាងកម្ពុជាទៀតផង ដូចជា ថៃ និង ហ្វីលីពីន ជាដើម ហើយបើនិយាយក្នុងន័យសេដ្ឋកិច្ច វាគឺជាកត្តាបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក។ បន្ថែមពីលើនេះដែរ លោក ឧកញ៉ា សៀ ឫទ្ធី បានគូសបញ្ជាក់ទៀតថា ចំណាកស្រុកគឺជារឿងល្អនោះទេ ឲ្យតែការចំណាកស្រុកនោះ ធ្វើឡើងដោយស្របច្បាប់ ហើយរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងខិតខំជួយជ្រោមជ្រែងសម្បើមណាស់ចំពោះការងារនេះ ដើម្បីឲ្យពលករកម្ពុជាអាចធ្វើចំណាកស្រុកទៅរកការងារធ្វើបានសុវត្ថិភាព និងទទួលបានប្រាក់ខែល្អ និងចំណេះជំនាញ ដើម្បីយកមកអភិវឌ្ឍប្រទេសកំណើតវិញ។ លោកឧកញ៉ា បានគូសបញ្ជាក់ថា ការចំណាកស្រុក នឹងនាំមកនូវផលចំណេញ ទាំងចំណូល ចំណេះ និងជំនាញសម្រាប់ពលករ ដែលទាំងអស់នេះហើយ គឺជាអ្វីដែលរាជរដ្ឋាភិបាលចង់បាន ព្រោះនៅពេលដែលពលករទាំងនោះត្រឡប់មកវិញ ជីវភាពពួកគេក៏ប្រសើរ ហើយមានទាំងចំណេះជំនាញ ដែលជាតម្រូវការសម្រាប់ការអភិវឌ្ឍស្រុកទេសទៅថ្ងៃអនាគត។

*សំណួរមួយទៀត ដែលគួរចោទសួរ តើនៅកម្ពុជា គ្មានការងារធ្វើ ឬប្រជាជនជំពាក់បំណុលធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ បានជាពួកគេធ្វើចំណាកស្រុក?*

បើនិយាយថា អត្រាអ្នកគ្មានការងារធ្វើ កម្ពុជាគឺមានក្នុងកម្រិតមួយទាបបំផុត ដែលមាន ០,៣% ប៉ុណ្ណោះ ហើយបើធៀបនឹងប្រទេសក្នុងតំបន់ អត្រាអ្នកគ្មានការងារធ្វើនៅកម្ពុជា គឺមានតិចជាងគេបំផុត។ នេះបើតាមការសិក្សាមួយរបស់ សភាអន្តរអាស៊ាន (AIPA) ដែលបានចេញផ្សាយកាលពីខែកក្កដា ឆ្នាំ២០១៨។ បើនិយាយថា ការធ្វើចំណាកស្រុក ព្រោះតែមកពីការជាប់បំណុលវ័ណ្ឌក ក៏ដូចជាមិនសមហេតុផលដែរ។ ជាក់ស្តែង បើតាមប្រសាសន៍លោកបណ្ឌិត អ៊ិន ចាន់នី អគ្គនាយកប្រតិបត្តិធនាគារ អេស៊ីលីដា ដែលមានបទពិសោធន៍ចាស់វស្សាក្នុងវិស័យនេះ បានអះអាងថា វាមិនមែនជារឿងត្រឹមត្រូវទេ ដែលថា ពលរដ្ឋចំណាកស្រុក ព្រោះបំណុលវ័ណ្ឌក។ លោក អ៊ិន ចាន់នី បាន

គូសបញ្ជាក់ថា រឿងចំណាកស្រុកនេះ គឺជានិន្នាការសេដ្ឋកិច្ចមួយ ដែលផ្តល់ឲ្យប្រជាពលរដ្ឋមានជម្រើស និងឱកាសស្វែងរកការងារ មិនមែនមកពីការជំពាក់បំណុលគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនោះឡើយ។

អគ្គនាយកប្រតិបត្តិធនាគារ អេស៊ីលីដា រូបនេះ បានបន្ថែមទៀតថា ការងារក្នុងស្រុកមានមិនខ្វះទេ ប៉ុន្តែ ជាទូទៅ ពលករចំណាកស្រុក គាត់មើលឃើញឱកាសទៅធ្វើការងារនៅក្រៅប្រទេស ដោយចង់បានទៅស្គាល់ស្រុកគេផង និងចំណូលខ្ពស់ជាងមុនផង។ ទោះយ៉ាងណា លោកថា ការងារនៅក្នុងស្រុកនាពេលបច្ចុប្បន្ននេះ ក៏មានប្រាក់ខែខ្ពស់គួរសមដែរ ហើយបើធ្វើការងារក្នុងស្រុក ក៏មានការផ្តល់ជូនអត្ថប្រយោជន៍ច្រើនណាស់ដែរ ពោលគឺមិនសូវចំណាយច្រើន និងបានរស់នៅជិតក្រុមគ្រួសារ ជាដើម។

*តើកម្លាំងពលកម្មក្នុងស្រុកនឹងប្រឈមដែរទេ ពេលមានការចំណាកស្រុក?*

ទាក់ទងនឹងសំណួរខាងលើនេះ ឯកឧត្តម បណ្ឌិត ម៉ី កល្យាណ ទីប្រឹក្សាជាន់ខ្ពស់ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានគូសបញ្ជាក់ដែរថា ដ្បិតថា កម្ពុជាមានលំហូរកម្លាំងពលកម្មទៅក្រៅប្រទេសមួយចំនួនក៏ដោយ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជា ក៏មានគោលនយោបាយក្នុងការបំពាក់បំប៉នជំនាញសម្រាប់កម្លាំងពលកម្មក្នុងស្រុក បន្ថែមផងដែរ ដូចជា ការបង្កើតនូវជំនាញបន្ថែមសម្រាប់កម្មករ កម្មការិនី សំដៅជំរុញឲ្យមានការធ្វើពិពិធកម្មទីផ្សារ ដើម្បីបង្កើនតម្លៃបន្ថែមកាន់តែខ្ពស់នៅក្នុងវិស័យកាត់ដេរ។ បន្ថែមពីនេះ ការជំរុញនិងលើកស្ទួយនូវជំនាញថ្មីៗ ទាក់ទងនឹងវិស័យព័ត៌មានវិទ្យា បច្ចេកវិទ្យា ក៏ជាទិសដៅសំខាន់មួយក្នុងការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។ ឯកឧត្តម បណ្ឌិត ម៉ី កល្យាណ បានគូសបញ្ជាក់ទៀតថា វិស័យធនធានមនុស្សផ្នែកជំនាញព័ត៌មានវិទ្យានេះ គឺជាវិស័យមួយសំខាន់ណាស់ ដោយឯកឧត្តមបានចាត់ទុកថា វាគឺជាវិស័យនាំចេញដោយមិនដាក់តាមកប៉ាល់របស់កម្ពុជា ហើយបច្ចុប្បន្នកម្ពុជាកំពុងចាប់ផ្តើមមានពន្លកលូតលាស់ជាបណ្តើរៗហើយ។

ទាក់ទិននឹងរឿងចំណាកស្រុកនេះដែរ សេដ្ឋវិទូធនាគារពិភពលោក Miguel Eduardo Sanchez Martin ក៏ធ្លាប់បានបញ្ជាក់នៅក្នុងសន្និសីទសារព័ត៌មានកាលពីខែមេសា ដើមឆ្នាំ២០១៨នេះថា ប្រសិនបើប្រជាជនកម្ពុជាធ្វើចំណាកស្រុកទៅប្រទេសថៃ ពួកគាត់អាចទទួលបានជំនាញ ហើយត្រឡប់មកវិញជាមួយនឹងជំនាញទាំងនោះប្រហែលជាអាចបើកអាជីវកម្ម ឬអាចធ្វើអ្វីផ្សេងទៀតនៅកម្ពុជាដែលវាជាភាពវិជ្ជមាន។ សេដ្ឋវិទូរបស់ធនាគារពិភពលោករូបនេះបានបញ្ជាក់ថា ការធ្វើចំណាកស្រុកពីជនបទទៅកាន់ទីក្រុងដែលមានឱកាសការងារជាច្រើនក្នុងវិស័យផលិតកម្ម និងទេសចរណ៍ក៏អាចជានិន្នាការវិជ្ជមាននិងជា មូលដ្ឋានគាំទ្រដល់កំណើនសេដ្ឋកិច្ចនាពេលអនាគត។

សូមជម្រាបថា បើតាមប្រសាសន៍របស់ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ ធ្លាប់បានលើកឡើង កាលពីខែមីនា ឆ្នាំ២០១៨ កន្លងទៅ នៅក្នុងសន្និបាតប្រចាំឆ្នាំ បានឲ្យដឹងថា ពលករដែលធ្វើចំណាកស្រុកទៅធ្វើការងារនៅក្រៅប្រទេស មានចំនួនជាង ១លាន ២សែននាក់ ហើយពួកគេបានផ្ញើប្រាក់ត្រឡប់មកស្រុកកំណើតវិញប្រមាណ ជិត ២ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ។ តាមរបាយការណ៍ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គិតត្រឹមដើមឆ្នាំ២០១៨ កន្លងទៅ ក្រុមហ៊ុនដែលបានចុះបញ្ជីស្របច្បាប់ ក្នុងការបញ្ជូនពលករឲ្យទៅធ្វើការងារនៅក្រៅប្រទេសមានចំនួន រហូតដល់ជាង ៩០ក្រុមហ៊ុន៕

**ការសិក្សា៖ ចំណូលពលករចំណាកស្រុកកាន់តែច្រើន បំណុលកាន់តែកើន! តើមកពីហេតុអ្វី?**

https://cambonomist.com/news/ ដោយ ជ័យ ជំនះ ថ្ងៃ04 -03-2019

ការសិក្សាថ្មីមួយបានបង្ហាញថា ប្រាក់បញ្ញើពីក្រៅប្រទេសដោយពលករចំណាកស្រុកកម្ពុជា បានលើកទឹកចិត្តឲ្យគ្រួសារពួកគាត់ខ្ចីលុយកាន់តែច្រើនជាងមុន ដែលនេះបញ្ជាក់ថា កាលណាពួកគាត់រកលុយបានកាន់តែច្រើន

បំណុលពួកគាត់ក៏កើនឡើងដែរ។ ក្នុងការសិក្សារបស់ស្ថាប័ន វេទិកាអនាគត (Future Forum) ដែលមានចំណងជើងថា «អន្ទាក់បំណុលកម្ពុជា? ការសិក្សាអំពីទំនាក់ទំនងរវាងលុយផ្ញើចូលនិងបំណុលគ្រួសារ» បានបង្ហាញថា លុយដែលផ្ញើចូល បានផ្សារភ្ជាប់ជាមួយនឹងកំណើនបំណុលជាអប្បបរមា ចំនួន ៦ភាគរយ។ ការសិក្សានេះបានពន្យល់ទស្សនៈពីរផ្សេងគ្នា៖

ដែលទីមួយ ជាតម្រូវការគ្រួសារអ្នកចំណាកស្រុកក្នុងការយកប្រាក់កម្ចីដើម្បីបំពេញតម្រូវការជាដើមទុន ឬចំណាយលើទ្រព្យសម្បត្តិល្អនិងមិនល្អ ផងដែរ។

ទីពីរ នៅលើផ្នែកផ្គត់ផ្គង់ អ្នកផ្តល់ប្រាក់កម្ចី ទាំងផ្លូវការ ទាំងមិនផ្លូវការ មើលឃើញលុយដែលបញ្ជូនចូល ជាយន្តការនៃការកាត់បន្ថយការលំបាកនៃការផ្តល់ប្រាក់កម្ចី ដោយប្រាក់ផ្ញើមកពីក្រៅប្រទេសនោះ មានតួនាទីជាវត្ថុបញ្ចាំលើប្រាក់កម្ចី។

ការសិក្សានេះ បាននិយាយដូច្នេះថា «ជាមួយលទ្ធផលនេះ ការសិក្សាសន្និដ្ឋានថា លុយដែលរកបាននិងប្រាក់កម្ចីជួយបំពេញគ្នាទៅវិញទៅមកដោយសារតែចំណូលហ្នឹងបានបង្កើតបន្ទុកបំណុលបន្តបន្ទាប់ ដើម្បីដោះស្រាយភាពលំបាកក្នុងការខ្វះខាតសាច់ប្រាក់សម្រាប់តម្រូវការប្រើប្រាស់ចម្បងរបស់ពួកគាត់ សកម្មភាពសេដ្ឋកិច្ច វិបត្តិ និងគោលបំណងផ្សេងៗទៀត នៅពេលដែលលំហូរលុយនោះមិនគ្រប់គ្រាន់។» ការស្រាវជ្រាវនេះ ដែលធ្វើដោយលោក ឡោ សំណាង បានអះអាងបន្ត ដោយយោងតាមតួលេខធនាគារពិភពលោកថា ចំណូលរបស់ជនចំណាកស្រុកបញ្ជូនទៅគ្រួសាររបស់ពួកគាត់បានរួមចំណែកចំនួន ៣ភាគរយនៃផលិតផលក្នុងស្រុកសរុប (GDP) ហើយបានកើនឡើងចំនួន ១៦៥ភាគរយ ពីឆ្នាំ២០០៩ ទៅឆ្នាំ២០១៤ គឺកើនពី ១៤២លានដុល្លារ ទៅ ចំនួន ៣៧៦លានដុល្លារ។ គ្រួសារភាគច្រើន ដែលមានចំណូលពីបងប្អូនផ្ញើពីក្រៅប្រទេសមក យកប្រាក់កម្ចីពីស្ថាប័នឲ្យខ្ចី ដោយមិនមានមូលហេតុល្អ ដែលមានចំនួន ៦៣,២៤ភាគរយ ខណៈដែលអ្នកខ្ចីលុយមានផលិតភាពល្អ គឺមានតែចំនួន ៣៦,៧៦ភាគរយ។

កម្ចីដែលមានផលិតភាព ពួកគេប្រើលើសកម្មភាពកសិកម្ម ឧទាហរណ៍ដូចជាទិញពូជស្រូវ ធ្វើសួនបន្លែ និងដាំដំណាំ ការចិញ្ចឹមសត្វ ការនេសាទ ជាដើម ខណៈដែលកម្ចីដែលមិនមានផលិតភាព បានប្រើប្រាស់សម្រាប់តម្រូវការប្រើប្រាស់ ដូចជា ចំណាយលើចំណីអាហារនិងសម្លៀកបំពាក់ជាដើម។ ការស្រាវជ្រាវនេះបានបន្ថែមថា «ស្ថានភាពនៃចំណូលនិងបំណុលនៅក្នុងបរិបទកម្ពុជា ក្នុងរយៈពេលខ្លី អាចត្រូវបានមើលឃើញជាវិជ្ជមានព្រោះវាជួយគ្រួសារចំណាកស្រុក ជានានូវតម្រូវការរស់នៅរបស់ពួកគាត់ ដូចជា អាហារ ការដឹកជញ្ជូន និងកន្លែងស្នាក់នៅ។ ក៏ប៉ុន្តែ ក្នុងរយៈពេលវែង គ្រួសារចំណាកស្រុកអាចជំពាក់បំណុលច្រើនពេក ដូចដែលបានរកឃើញថា ប្រាក់កម្ចីត្រូវបានផ្តល់ឲ្យជាទូទៅ ដោយមិនមានផលិតភាពល្អ។» ដូច្នេះហើយការស្រាវជ្រាវនេះបាននិយាយថា មុននឹងផ្តល់ប្រាក់កម្ចីដល់គ្រួសារចំណាកស្រុក អ្នកផ្តល់ប្រាក់កម្ចី គួរពិនិត្យមើលល្អិតល្អន់នូវប្រវត្តិនៃការខ្ចី សមត្ថភាពទូទាត់បំណុល និងគោលបំណងរបស់ពួកគាត់៕

## នគរបាលការិយាល័យប្រឆាំងការជួញដូរនិងការពារអនីតិជនឃាត់ខ្លួនជនបរទេសម្នាក់ ករណីទិញពេស្យាចារកុមារ

http://bayontv.com.kh/ 03/03/2019

ភ្នំពេញ៖ កម្លាំងនគរបាលជំនាញនៃការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានធ្វើការស្រាវជ្រាវ ស៊ើបអង្កេត ចុះប្រតិបត្តិការ ឃាត់ខ្លួនជនបរទេសម្នាក់ ពាក់ព័ន្ធករណីទិញពេស្យាចារកុមារ ។ប្រតិបត្តិការនេះធ្វើឡើងកាលពីវេលាម៉ោង៦ ល្ងាចនាថ្ងៃទី០២ ខែមិនា ឆ្នាំ២០១៩ ស្ថិតនៅចំណុចផ្ទះម៉ាស្សា យីហោ ស្រីនាង ៨៧១ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ក្នុងប្រតិបត្តិការនេះ ដោយមានចង្អុលបង្ហាញពី ឯកឧត្តម ឧត្តមសេនីយ៍ឯក ស ថេត អគ្គស្នងការរងនិងជាស្នងការនគរបាលរាជធានីភ្នំពេញ មានការសម្របសម្រួល ពី

លោក កែវ សុជា ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងមានការបញ្ជាផ្ទាល់ដោយ លោក ឧត្តមសេនីយ៍ត្រី ចាន់ កិត្តិខុម ស្នងការរងទទួលដឹកនាំការងារការិយាល័យប្រឆាំងការជួញដូរ មនុស្សនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

នគរបាលបានអោយដឹងថា ជនបរទេសដែលឃាត់ខ្លួនមានឈ្មោះ POPE DANNY LEE ហៅ ដ៉ានី ភេទប្រុស អាយុ ៦០ឆ្នាំ ជនជាតិអាមេរិក កាន់លិខិតឆ្លងដែនលេខ 546245420។ នគរបាលដដែលបានបន្តឲ្យដឹងថា មុនឈានដល់ការឃាត់ខ្លួនជនសង្ស័យបរទេសម្នាក់នេះ គឺកម្លាំងនគរបាលជំនាញនៃការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានធ្វើការស្រាវជ្រាវ ស៊ើបអង្កេត កាលពីថ្ងៃទី០១ ខែមិនា ឆ្នាំ២០១៩ រហូតថ្ងៃល្ងាចថ្ងៃទី០២ ខែមិនា ឆ្នាំ២០១៩ បានចុះទៅឃាត់ខ្លួនជន បរទេស តែម្តង នៅចំណុចផ្ទះម៉ាស្សា យីហោ ស្រីនាង៨៧១ សង្កាត់កាកាប ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ក្រោយពេលបញ្ចប់ប្រតិបត្តិការនេះផងដែរកម្លាំងនគរបាលបានឃាត់ខ្លួនបុរសជនជាតិ អាមេរិកម្នាក់ និងធ្វើការស្រាវជ្រាវរកឃើញនារីរងគ្រោះ ចំនួន០៥នាក់ ក្នុងនោះកុមារីចំនួន០៣នាក់ បាននាំខ្លួនជនបរទេសយកមកការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនដើម្បីធ្វើការសាកសួរ។

សូមបញ្ជាក់ផងដែរក្រោយបញ្ចប់ការសាកសួរ ជនបរទេសម្នាក់នេះមានការពាក់ព័ន្ធករណី រំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស និងទិញពេស្យាចារកុមារ ត្រូវបានលោកព្រះរាជអាជ្ញា ឯកភាពអោយនគរបាលឃុំខ្លួនជនបរទេសបណ្តោះអាសន្ន ដើម្បីកសាងសំណុំរឿងបញ្ជូនខ្លួនទៅអយ្យការអមសាលាដំបូងរាជធានីចាត់ការតាមនីតិវិធី។ ចំណែកនារីរងគ្រោះទាំង៥នាក់នោះត្រូវបាន នគរបាលប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ៕ អត្ថបទ&រូបភាពៈ ម៉ឺន កុម្ភៈ

## ទីតាំងម៉ាស្សាយីហោ ៨៨១ម៉ាស្សាកោសជប់ គឺជាកន្លែងបម្រើសេវាផ្លូវភេទ

http://nokorwatnews.com/ 03-03-2019

ខេត្តសៀមរាបៈ ទីតាំងម៉ាស្សា ៨៨១ម៉ាស្សាកោសជប់ ត្រូវបានគេដឹងថា ជាកន្លែងបម្រើសេវាផ្លូវភេទ ឯ ការដាក់ផ្លាក់យីហោនេះ គ្រាន់តែដាក់បំភាន់ភ្នែកមហាជនតែប៉ុណ្ណោះ តែជាតុពិត ជាកន្លែងបម្រើផ្លូវភេទយ៉ាងពេញបន្ទុក ដែលមានទីតាំងស្ថិតនៅក្នុងភូមិទ្រាក សង្កាត់សៀមរាប ក្រុងសៀមរាប ។ តាមប្រភពព័ត៌មានពីពលរដ្ឋបានឲ្យដឹងថា គេឃើញមានសមត្ថកិច្ចមួយចំនួនមិនបង្ក្រាបទេទុកស្ងំពង និងដើរយកលុយ ជាថ្នូរទៅនឹងការមិនបង្ក្រាប កត្តាទាំងនេះហើយ ទើបធ្វើឲ្យក្រុងសៀមរាប ពោរពេញទៅដោយកន្លែងម៉ាស្សាស្ទើរពេញក្រុង ។

ពលរដ្ឋថ្លែងថា ល្មមដល់ពេលសមត្ថកិច្ចចុះចាប់កន្លែងម៉ាស្សា មួយកន្លែងម៉ាស្សាយីហោ ៨៨១ម៉ាស្សាកោសជប់ នេះហើយ ម្យ៉ាងទៀត មួយរយៈពេលចុងក្រោយនេះ គេមិនដែលឃើញសមត្ថកិច្ចចុះបង្ក្រាបកន្លែងម៉ាស្សាឡើយ ប្រហែលជាទុកស្ងំពង ឬត្រូវរ៉ូវគ្នាយ៉ាងស្ងៀមស្ងាត់ ទើបបណ្តោយឲ្យកន្លែងម៉ាស្សារីកដុះដាលដូចផ្សិតបែបនេះ។ ពាក់ព័ន្ធទៅនឹងកន្លែងម៉ាស្សានេះ លោក ពេជ សុខេន មេប៉ុស្តិ៍ សង្កាត់សៀមរាប បានឲ្យដឹងថា ទីតាំងម៉ាស្សា បម្រើផ្លូវភេទនេះ លោកធ្លាប់បានបង្ក្រាបម្តងហើយ តែមិនរាងចាលទេ តែលោកចុះបង្ក្រាបក្នុងពេលឆាប់ៗនេះ។
យើងចាំមើលចំណាត់ការរបស់លោក មេប៉ុស្តិ៍តើមានប្រសិទ្ធភាព ឬទេ ៕ ប៊ុនរិទ្ធី

## បញ្ជូនមេការជួញដូរមនុស្សដ៏ល្បីម្នាក់ នៅក្រុងតាខ្មៅ ទៅតុលាការ

http://nokorwatnews.com/ 03-03-2019

ខេត្តកណ្តាលៈ មេការជួញដូរមនុស្សដ៏ល្បីម្នាក់នៅក្រុងតាខ្មៅ ប្រចាំភោជនីយដ្ឋាន២២២ ដែលមានរហ័សនាម ក្រពុំ ឈូក ដែលនគរបាលប្រឆាំ ងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តកណ្តាលចុះបង្ក្រាបពាក់ពន្ធ័ករណីសញ្ចរកម្មនៅក្នុងផ្ទះសំណាក់ឈ្មោះ សុខ វិសាល ផ្លូវលេខ ១១០B ភូមិថ្មី២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ២១និង៣០នាទី ត្រូវបញ្ជូនទៅសាលាដំបូងខេត្តកណ្តាល បើ

តាមការបញ្ជាក់ពីលោក រស់ សារិន ប្រធានការិយាល័យការជួញដូរ និងការពារអនីតិជន នៃស្នងការនគរបាលខេត្តកណ្ដាល ។

ជនសង្ស័យមានឈ្មោះ ទូច ចាន់ ភេទប្រុស អាយុ៣៥ឆ្នាំ ឈ្មោះហៅក្រៅ ក្រពុំ ឈូក មានទីលំនៅបច្ចុប្បន្ននៅផ្ទះ ជួលក្នុងភូមិថ្មី២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល និងមានទីលំនៅកំណើត ភូមិ អង្គបានឃុំអង្គបាន ស្រុកកងមាស ខេត្តកំពង់ចាម ជនរងគ្រោះទី០១ ឈ្មោះ លីហួ អនីតិជន ទី០២ឈ្មោះ ម៉ៅ រក្សា ទី០៣ឈ្មោះ សៀង គា ទី០៤ឈ្មោះ ធី ចាន់លីណាទី៥ឈ្មោះ មុន លក្ខិណា ទី០៦ឈ្មោះ ពេជ្រ រតនា ។

នគរបាល ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជនបានឲ្យដឹងថាដោយមានសេចក្ដីរាយការណ៍ ពីពលរដ្ឋល្អថា មាន មេការម្នាក់បាននាំស្រីៗ ជាច្រើននា ក់ទៅផ្ទះសំណាក់ វីសាល ស្ថិតនៅភូមិថ្មី ក្នុងសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ភ្លាមនោះ លោក រស់ សារិន ប្រធានការិយាល័យការជួញដូរ បានសហការជាមួយកម្លាំងនគរបាលមូលដ្ឋានចុះធ្វើការឆែកឆេរ ក៏បានឃើញមនុស្សប្រុស ស្រី ជាច្រើននាក់ នៅក្នុងបន្ទប់ផ្ទះសំណាក់ ដូចដែលពលរដ្ឋបានរាយការណ៍មកមែន ។

បច្ចុប្បន្នជនសង្ស័យ ត្រូវបានឃាត់ខ្លួនបញ្ជូនមកការិ ជំនាញខេត្ត ។ ចំណែកជនរងគ្រោះ ទាំង៦នាក់ បាននាំមកការិយាល័យជំនាញខេត្ត ក្រោមការជួយឧបត្ថម្ភ ពីអង្គការ មេត្រី អន្តរជាតិ ៕ ធ ដា

## តុលាការសម្រេចឃុំខ្លួនក្រពុំឈូក មេការជួញដូរមនុស្សដ៏ល្បីម្នាក់នៅក្រុងតាខ្មៅ ដាក់ពន្ធនាគារបណ្ដោះអាសន្ន

http://nokorwatnews.com/ 03-03-2019

ខេត្តកណ្ដាលៈ នៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៩ លោកស្រី ពេជ មារ៉ែន ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាល បានសម្រេចចេញដីកាឃុំខ្លួន ក្រពុំឈូក មេការជួញដូរមនុស្សដ៏ល្បីម្នាក់ នៅក្រុងតាខ្មៅ ដាក់ពន្ធនាគារបណ្ដោះអាសន្នពីបទ "សញ្ជរកម្ម និងផ្តល់កន្លែងសម្រាប់ធ្វើពេស្យាចារ" ដែលប្រព្រឹត្តនៅ ភូមិថ្មី២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពី ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ២១និង៣០នាទីយប់ តាមមាត្រា២៥ មាត្រា២៦ និងមាត្រា៣២ នៃក្រមព្រហ្មទណ្ឌ ។

ជនជាប់ចោទ មានឈ្មោះ ទូច ចាន់ ភេទប្រុស អាយុ៣៥ឆ្នាំ ឈ្មោះហៅក្រៅ ក្រពុំ ឈូក មានទីលំនៅបច្ចុប្បន្ននៅផ្ទះ ជួលក្នុងភូមិថ្មី២ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល និងមានទីលំនៅកំណើត ភូមិ អង្គបានឃុំអង្គបាន ស្រុកកងមាស ខេត្តកំពង់ចាម ។

ជនរងគ្រោះទី១ ឈ្មោះ លីហួ អនីតិជន ទី២ឈ្មោះ ម៉ៅ រក្សា ទី៣ឈ្មោះ សៀង គា ទី៤ឈ្មោះ ធី ចាន់លីណា ទី០៥ឈ្មោះ មុន លក្ខិណា ទី០៦ឈ្មោះ ពេជ្រ រតនា ។

សូមរំលឹកថា នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានឲ្យដឹងថា ដោយមានសេចក្ដីរាយការណ៍ពីពលរដ្ឋល្អថាមាន មេការម្នាក់បាននាំស្រីៗជាច្រើននាក់ទៅផ្ទះសំណាក់ វីសាល ស្ថិតនៅភូមិថ្មី ក្នុងសង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល ភ្លាមនោះ លោក រស់ សារិន ប្រធានការិយាល័យការជួញដូរ បានសហការជាមួយកំលាំងនគរបាលមូលដ្ឋានចុះធ្វើការឆែកឆេរ ក៏បានឃើញមនុស្សប្រុស ស្រី ជាច្រើននាក់នៅក្នុងបន្ទប់ផ្ទះសំណាក់ ដូចដែលពលរដ្ឋបានរាយការណ៍មកមែន ៕ ធ ដា

## បញ្ឈប់មង្គលការ គូស្នេហ៍ចិន-ខ្មែរ កណ្ដាលទី ហៅមកប៉ុស្តិ៍សិន

https://www.dap-news.com/ ByID:112 Posted on 02 March 2019 | 11:52

ភ្នំពេញ ៖ កម្លាំងនគរបាល ជំនាញអន្តោប្រវេសន៍ ខេត្ត ស្រុក និងនគរបាលប៉ុស្តិ៍ បានសហការជាមួយ លោកមេឃុំកន្ទួត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ បានចុះបញ្ឈប់ អាពាហ៍ពិពាហ៍ រវាងគូស្នេហ៍កូនកម្លោះ ជាជនជាតិចិន និងកូនក្រមុំជនជាតិខ្មែរ ព្រោះគ្មានលិខិតអនុញ្ញាត តាមផ្លូវច្បាប់ ។

យោងតាមអគ្គនាយកដ្ឋាន អន្តោរប្រវេសន៍បានឲ្យដឹងថា នៅក្នុងភូមិកន្ទួតឃុំកន្ទួត ស្រុកជាំក្សាន្ត មានបុរសជនជាតិចិនម្នាក់ បានមករៀបការជាមួយពលរដ្ឋខ្មែរ នារសៀលថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩ ។ ករណីនេះ ត្រូវបានកម្លាំងនគរបាលជំនាញអន្តោប្រវេសន៍ ខេត្ត ស្រុក និងនគរបាលប៉ុស្តិ៍ បានសហការជាមួយ លោកមេឃុំកន្ទួត ចុះត្រួតពិនិត្យ និងសាកសួរជនជាតិចិន ឈ្មោះ ZENG YOUXI ភេទប្រុស អាយុ៤៩ឆ្នាំ ស្នាក់នៅភូមិសហភាពរុស្សី សង្កាត់ចោមចៅ ខ័ណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ បានមករៀបការជាមួយជនជាតិខ្មែរ ឈ្មោះ ហ៊ិន លីណា អាយុ២៦ឆ្នាំ ដែលរស់នៅភូមិកន្ទួត គ្មានលិខិតអនុញ្ញាត ហើយត្រូវបានអញ្ជើញមកប៉ុស្តិ៍រដ្ឋបាល ដោយបញ្ឈប់ការរៀបការ និងធ្វើកិច្ចសន្យា និងបានកំណត់សាមីខ្លួនទាំងពីរ បំពេញបែបបទតាមច្បាប់ គ្រប់គ្រាន់ជាមុនសិន ទើបអាចរៀបការបាន ៕

## ឆែកឆេររោងចក្រកម្ទាត់កាកសំណល់ក្នុងខេត្តឈុនបុរី រកឃើញពលរដ្ឋខ្មែរខុសច្បាប់០៨នាក់

http://www.pheaktraofficial.com/ By Pheaktra Prak 03-03-2019

ប្រទេសថៃ៖ កាលពីរសៀលថ្ងៃអាទិត្យ ទី០៣ខែមីនា ឆ្នាំ២០១៩ នេះ កម្លាំងសមត្ថកិច្ចចម្រុះខេត្តឈុនបុរី ប្រទេសថៃ បានចុះធ្វើការឆែកឆេរ រោងចក្រកម្ទាត់កាកសំណល់អេឡិចត្រូនិក មួយឈ្មោះ Muu Hlin Saein ស្ថិតនៅក្នុង សង្កាត់ណងខាម ស្រុកស៊ីរាឆា ខេត្តឈុនបុរី បានឃើញពលករខុសច្បាប់ ចំនួន ១៥នាក់ ក្នុងនោះមានពលរដ្ឋខ្មែរ ចំនួន ០៨នាក់ ភូមា០៧នាក់។ យោងតាមរបស់សម្ថកិច្ចថៃបានអោយដឹងថា រោងចក្រខាងលើជារោងចក្រខាតធំតែពុំមានប័ណ្ណអនុញ្ញាតប្រកិច្ចការតាមស្តង់ដាររដ្ឋព្រម ទាំងទទួលពលករអន្តោប្រវេសន៍ខុសច្បាប់អោយធ្វើការដោយគ្មានច្បាប់អនុញ្ញាត សមត្ថកិច្ចបានកសាងសំណុំរឿងដើម្បីចាត់វិធានការណ៍តាមផ្លូវច្បាប់។

# ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩

## ក្រសួងមហាផ្ទៃ នឹងបើកច្រកទ្វារព្រំដែនជាច្រើនកន្លែងទៀត ដើម្បីទប់ស្កាត់ការឆ្លងដែនខុសច្បាប់

http://bayontv.com.kh/ 05/03/2019

ភ្នំពេញ ៖ នៅពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ និងលើកទិសដៅអនុវត្តបន្តរបស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ថ្ងៃទី៤ ខែមីនានេះ ឯកឧត្តម សន្តិបណ្ឌិត សុខ ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានថ្លែងថា ក្រសួងមហាផ្ទៃ មានផែនការដំឡើងច្រករបៀងជាច្រើនកន្លែងថែមទៀតអោយជាច្រកទ្វារឆ្លងដែនស្របច្បាប់ ដើម្បីទប់ស្កាត់លំហូរជនបរទេសឆ្លងដែនមកកម្ពុជាខុសច្បាប់។ ឯកឧត្តម សុខ ផល ផល រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានថ្លែងថា នៅពេលបច្ចុប្បន្ននេះ លំហូរប្រជាជន និងទំនិញឆ្លងដែនចេញចូលខុសច្បាប់នៅតាមបណ្តាច្រករបៀង មានភាពលំបាកក្នុងការគ្រប់គ្រង។ ការឆ្លងដែនខុសច្បាប់ នៅតែបន្តកើនឡើងជាធម្មតា ខណៈច្រករបៀងមួយចំនួនតូចបានបិទជាផ្លូវការ និងច្រករបៀងជាច្រើនកន្លែងត្រូវបានប្រជាជនកំពុងប្រើប្រាស់ធ្វើដំណើរឆ្លងដែនជារៀងរាល់ថ្ងៃ។ ឯកឧត្តម សុខ ផល បន្តថា ដើម្បីបិទច្រករបៀងឆ្លងដែនខុសច្បាប់បាន គឺរាជរដ្ឋាភិបាល ដែលមានក្រសួង

មហាផ្ទៃ ជាសេនាធិការ បានកំពុងពិនិត្យពិចារណា ដំឡើងច្រកបៀងមួយចំនួនអោយទៅជាច្រកតំបន់ ទ្វេភាគី និងជាច្រកព្រំដែនអន្តរជាតិ។ ឯកឧត្តម សន្តិបណ្ឌិត សុខ ផល បន្ថែមថា នៅពេលបច្ចុប្បន្ននេះ ក្រសួងមហាផ្ទៃ មានផែនការស្នើរាជរដ្ឋាភិបាល ដំឡើងច្រកតំបន់ចំនួន៥កន្លែង អោយទៅច្រកទ្វារអន្តរជាតិ ក្នុងប៉ែកខាងព្រំដែនកម្ពុជា-វៀតណាម មាន២ច្រក គឺមានច្រកទ្វារជ្រៃធំ ឡុងប៊ិន ក្នុងខេត្តកណ្តាល និងច្រកម៉ឺនជ័យ ខេត្តព្រៃវែង។ ដោយឡែកប៉ែកខាងព្រំដែនកម្ពុជា ថៃ គឺមាន៣ច្រក រួមមាន ៖ ច្រកថ្មដារ ខេត្តពោធិ៍សាត់ ច្រកជប់គគី ខេត្តឧត្តរមានជ័យ និងច្រកអានសេះ ខេត្តព្រះវិហារ។

ទន្ទឹមនឹងការទប់ស្កាត់ឆ្លងដែនខុសច្បាប់នៅតាមខ្សែបន្ទាត់ព្រំដែនកម្ពុជានេះផងដែរ ឯកឧត្តម សុខ ផល ក៏បានជំរុញអោយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ពង្រឹងការល្បាតត្រួតពិនិត្យតាមច្រករបៀង និងបង្កើតប៉ុស្តិ៍ នគរបាលតាមច្រកតំបន់ទ្វេភាគី ដើម្បីប្រចាំការទប់ស្កាត់លំហូរជនបរទេសឆ្លងដែនខុសច្បាប់ចូលមកក្នុងទឹកដីព្រះរាជាណាចក្រកម្ពុជា៕

## រដ្ឋមន្ត្រីការងារ៖ មកដល់ឆ្នាំ២០១៨ ពលរដ្ឋទទួលបានការងារធ្វើក្នុងប្រទេស ៣.៦លាននាក់

http://www.freshnewsasia.com/ 2019-03-05

**(ភ្នំពេញ)៖** ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៨ និងលើកទិសដៅការងារ ឆ្នាំ២០១៩ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាថ្ងៃទី០៥ ខែមីនានេះ លោករដ្ឋមន្ត្រី អ៊ិត សំហេង បានឱ្យដឹងថា គិតមកដល់ឆ្នាំ២០១៨ ប្រជាពលរដ្ឋខ្មែរប្រមាណជាង ៣.៦លាននាក់ ទទួលបានការងារធ្វើក្នុងប្រទេស។

លោករដ្ឋមន្ត្រីបានថ្លែងយ៉ាងដូច្នេះថា «**រាជរដ្ឋាភិបាល បានបង្កើតការងាររហូតជាង ៤.៨លាននាក់ ក្នុងនោះការងារនៅក្នុងប្រទេសមានប្រមាណ ៣.៦លាននាក់ (ផ្នែកសេដ្ឋកិច្ចក្នុងប្រព័ន្ធមានជាង ១.៤លាននាក់ និងផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធមាន ២.២លាននាក់) និងពលករដែលធ្វើការនៅក្រៅប្រទេស មានប្រមាណជាង ១.២លាននាក់**»។ លោក អ៊ិត សំហេង បានបន្តថា អត្រាមានការងារធ្វើរបស់ប្រជាពលរដ្ឋកម្ពុជា នៅតែរក្សាបានជាង ៩៩.៣% ពោលអត្រាអត់ការងារធ្វើ គឺមានតែ ០.៧% ប៉ុណ្ណោះ នៃកម្លាំងពលកម្មសរុបជិត ១០លាននាក់។ លោកថា សហគ្រាស-គ្រឹះស្ថានសេដ្ឋកិច្ចក្នុងប្រព័ន្ធ ដែលមានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសរុបចំនួន ១២,៧៩៦សហគ្រាស ដែលមានកម្មករនិយោជិតចំនួន ១,៤២០,៥៤៧នាក់ ដោយបានទទួលប្រាក់ឈ្នួលជាមធ្យមជិត ៣ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ លោករដ្ឋមន្ត្រីបានបន្តទៀតថា សហគ្រាសផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធមានចំនួន ២៣,០៩២រោងចក្រ មានកម្មករនិយោជិតចំនួន ១២៤,៩៤៦នាក់ បានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ បើតាមរដ្ឋមន្ត្រីក្រសួងការងារ ផ្នែកសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះបានដើរតួនាទីយ៉ាងសកម្ម ក្នុងការបំពេញឱ្យគ្នាទៅវិញទៅមករវាងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងបានរួមវិភាគទានយ៉ាងធំក្នុងសេដ្ឋកិច្ចជាតិប្រមាណជាង ៦ពាន់លានដុល្លារ ក្នុងមួយឆ្នាំ៕

## កម្ពុជាទទួលបានប្រាក់ចំណូល ២.៣ពាន់លានដុល្លារ ពីពលករក្រៅប្រទេសជាង១លាននាក់

http://www.freshnewsasia.com/ 2019-03-05

**(ភ្នំពេញ)៖** លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ថា ក្នុងឆ្នាំ ២០១៨ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់ឱកាសការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋ ១,២៣៤,១១១នាក់ (ស្រី ៤៩៩,០៧០នាក់) ហើយពួកគេបានផ្ញើថវិកាមកឱ្យក្រុមគ្រួសារវិញបានប្រមាណជាង ២.៣ពាន់លានដុល្លារ។ លោករដ្ឋមន្ត្រីលើកឡើងយ៉ាងដូច្នេះ ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៨ និងលើកទិសដៅការងារ ឆ្នាំ ២០១៩ និងការប្រកាសអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-

២០២៣ នាថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការងារ។ លោករដ្ឋមន្ត្រីបានលើកឡើងថា ក្នុងឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានផ្តល់ឱកាសការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋចំនួន ១,២៣៤,១១១នាក់ (ស្រី ៤៩៩,០៧០នាក់) ក្នុងនោះរួមមាន៖

* ប្រទេសថៃមានចំនួន ១,១៤៦,៦៨៥នាក់ ដោយទទួលបានប្រាក់ឈ្នួលអប្បបរមាចាប់ពី ៣០៥-៣១០បាតថៃ ក្នុងមួយថ្ងៃ ឬប្រហាក់ប្រហែលនឹង ៣០០ដុល្លារអាមេរិក ក្នុងមួយខែ។

* សាធារណរដ្ឋកូរ៉េមានចំនួន ៤៩,០៩៩នាក់ ដោយទទួលបានប្រាក់ឈ្នួលអប្បបរមាជាង ៥,០០០វ៉ុន ក្នុងមួយម៉ោង ឬប្រហាក់ប្រហែលនឹង ១,២០០ដុល្លារអាមេរិក ក្នុងមួយខែ។

* ប្រទេសជប៉ុនមានចំនួន ៩,១០០នាក់ ដោយទទួលបានប្រាក់ឈ្នួលជាមធ្យមប្រមាណជា ១,៥០០ដុល្លារអាមេរិក ក្នុងមួយខែ។

* ប្រទេសម៉ាឡេស៊ីមានចំនួន ៣០,១១៣នាក់ ដោយទទួលបានប្រាក់ឈ្នួលអប្បបរមាប្រមាណជា ៣០០ដុល្លារអាមេរិក ក្នុងមួយខែ។

* ប្រទេសសិង្ហបុរីមានចំនួន ៨៣១នាក់ ដោយទទួលបានប្រាក់ឈ្នួលអប្បបរមាប្រមាណ ៤៥០ដុល្លារអាមេរិក ក្នុងមួយខែ។

* តំបន់រដ្ឋបាលពិសេសហុងកុង ទើបចាប់ផ្តើមបញ្ជូនពលការិនីបានចំនួន ៥៤នាក់ ដោយទទួលបានប្រាក់ឈ្នួល ៥៥០ដុល្លារអាមេរិក ក្នុងមួយខែ។ ចាប់ពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨ ទទួលបានប្រាក់ឈ្នួល ៥៧៨ដុល្លារអាមេរិក ក្នុងមួយខែ។

* ប្រទេសអារ៉ាប់ប៊ីសាអូឌីត ទើបចាប់ផ្តើមបញ្ជូនពលការិនីបានចំនួន ១៦នាក់ ដោយទទួលបានប្រាក់ឈ្នួលអប្បបរមាប្រមាណ ៣០០ដុល្លារអាមេរិក ក្នុងមួយខែ។

លោក អ៊ិត សំហេង បានបន្តថា ក្នុងមួយឆ្នាំៗ ពលករខ្មែរបានផ្ញើថវិកាជូនក្រុមគ្រួសារបានប្រមាណជាង ២.៣ ពាន់លានដុល្លារអាមេរិក ព្រមទាំងទទួលបាននូវមុខជំនាញវិជ្ជាជីវៈ ពេលត្រលប់មកវិញ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។

ជាមួយគ្នានេះ ពេលពលករខ្មែរដែលទៅធ្វើការនៅក្រៅប្រទេស ក៏ទទួលបានភាពអនុគ្រោះដោយមិនបាច់បង់ថ្លៃលើលិខិតធ្វើដំណើរផងដែរ។ ក្រៅពីនោះ ពួកគេក៏ទទួលបាននូវការគាំពារតាមផ្លូវច្បាប់ និងអន្តរាគមន៍សង្គ្រោះ នៅពេលមានហានិភ័យជាយថាហេតុ និងការយកចិត្តទុកដាក់ តាមរយៈការជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំការរៀបចំពិធីផ្សេងៗ និងការលើកទឹកចិត្តពីរាជរដ្ឋាភិបាល ទាំងមុនចេញដំណើរ និងចំពេលមានកម្មវិធីបុណ្យប្រពៃណីជាតិខ្មែរ នៅឯមូលដ្ឋានការងាររបស់ពលករខ្មែរថែមទៀតផង៕

## បុរសជនជាតិអាមេរិកាំងម្នាក់ ត្រូវបញ្ជូនទៅតុលាការពាក់ព័ន្ធអំពើពេស្យាចារ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 05 March 2019 | 09:15 ICT

**ភ្នំពេញ:** សមត្ថកិច្ចក្រុងភ្នំពេញ បញ្ជូនជនបរទេសម្នាក់ទៅតុលាការ ក្រោយឃាត់ខ្លួនកាលពីថ្ងៃសៅរ៍ ពាក់ព័ន្ធនឹងអំពើពេស្យាចារនិងរំលោភសេពសន្ថវៈលើអនីតិជនចំនួន ៥ នាក់ ខណៈមន្ត្រីជំនាញ កំពុងស្រាវជ្រាវរកអ្នកពាក់ព័ន្ធដទៃទៀត ដែលតាមការសន្និដ្ឋានអាចមានជនរងគ្រោះនិងជនសង្ស័យច្រើនជាងនេះ។ កាលពីថ្ងៃទី ២ ខែ មីនា ជនបរទេសម្នាក់ ឈ្មោះ POPE DANNY LEE ហៅដានី អាយុ ៦០ ឆ្នាំ ជនជាតិអាមេរិក កាន់លិខិតឆ្លងដែនលេខ 546245420 ត្រូវបានឃាត់ខ្លួន នៅចំណុចផ្ទះម៉ាស្សា ឃីហោ ស្រីនាង ៨៧១ សង្កាត់កាកាប ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

លោក កែវ ធា ប្រធានការិយាល័យប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន រាជធានីភ្នំពេញ ប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា ជនបរទេសរូបនេះ បានប្រព្រឹត្តបទល្មើសនេះជាយូរមកហើយ ប៉ុន្តែមិនទាន់មានភ័ស្តុ

តាង ទើបតែពេលនេះឈានដល់ការឃាត់ខ្លួន ព្រោះតែមន្ត្រីជំនាញ បានប្រមូលភស្តុតាងគ្រប់គ្រាន់ ហើយបានឃាត់ខ្លួននៅនឹងកន្លែងប្រព្រឹត្តបទល្មើសតែម្តង។ លោកបានបញ្ជាក់ថា៖ «ជនបរទេសរូបនេះបានចេញចូលមកស្រុកខ្មែរយូរហើយ ហើយក៏បានដឹងយូរដែរ ប៉ុន្តែយើងមិនទាន់មានភស្តុតាងច្បាស់លាស់ ទើបតែដល់ឥឡូវយើងមានភស្តុតាងគ្រប់គ្រាន់ ដើម្បីឃាត់ខ្លួនគាត់។ ច្បាស់ណាស់មានអ្នកពាក់ព័ន្ធផ្សេងទៀត ដែលយើងកំពុងស៊ើបអង្កេតបន្តទៀតរកជនពាក់ព័ន្ធក្នុងបទល្មើស នេះតែក្រុមការងារយើងកំពុងធ្វើ ការយើងមិនអាចប្រាប់បានទេ»។ លោកបន្តថា៖ «ចំពោះមុខយើងបានចោទគាត់ ចំនួន ២ បទល្មើស គឺអំពើពេស្យាចារលើកុមារ និងអំពើរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោស។ ក្នុងករណីនេះ មានអនីតិជនចំនួន ៥ នាក់ អាយុ ៨ ឆ្នាំ ៣ នាក់និងលើអាយុ ១៨ ឆ្នាំ ២ នាក់ ប៉ុន្តែវាបានប្រព្រឹត្តយូរឆ្នាំកន្លងមកហើយ ទម្រាំចាប់បាន សរុបទៅទាំង ៥ នាក់ហ្នឹង គឺសុទ្ធតែអនីតិជនទាំងអស់។ តាមការស្រាវជ្រាវ នៅមានជនរងគ្រោះផ្សេងទៀត ជាបន្តបន្ទាប់ ដែលប៉ូលិសយើងកំពុងធ្វើការបន្តទៀត»។

តាមនាយកដ្ឋានប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ក្រោយការឃាត់ខ្លួន ជនសង្ស័យត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនរាជធានីភ្នំពេញ ដើម្បីកសាងសំណុំរឿងបញ្ជូនខ្លួន ទៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញចាត់ការតាមនីតិវិធី។ ចំណែកជនរងគ្រោះទាំង ៥ នាក់ គឺត្រូវបាននគរបាលប្រគល់ជូនមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ។

តាមរបាយការណ៍លទ្ធផលការងារឆ្នាំ ២០១៨ របស់ក្រសួងមហាផ្ទៃ បានឲ្យដឹងថា សមត្ថកិច្ចបានអន្តរាគមន៍ជួយជនរងគ្រោះក្នុងករណីអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ២៣០ នាក់ ក្នុងចំណោម ៣៤៥ នាក់ រួមមាន អាយុក្រោម១៥ឆ្នាំ ៩២នាក់ អាយុពី១៥ ដល់ ១៧ឆ្នាំ២៣នាក់ និងអាយុចាប់ពី១៨ឆ្នាំឡើង១១៥នាក់។ ក្នុងចំណោមជនរងគ្រោះទាំងនោះ គឺមាន ៩២ នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសង្គមកិច្ច ២ នាក់ បញ្ជូនទៅអង្គការនិង ១៣៦ នាក់ បញ្ជូនទៅអាណាព្យាបាលគ្រប់គ្រងវិញ។

លោក ខឹម វ៉ានដូ អ្នកឯកទេស ការពារកុមារ នៃអង្គការសកម្មភាពដើម្បីកុមារដែលធ្វើការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងអំពើរំលោភផ្លូវភេទលើកុមារ និយាយថា ករណីរំលោភបំពានលើកុមារពីសំណាក់ជនបរទេស តែងតែកើតមានជារឿយៗព្រោះមានកត្តាបូករួមជាច្រើនដែលបណ្តាលឲ្យជនល្មើសនៅតែបន្តប្រព្រឹត្ត។ លោកបញ្ជាក់ថា៖ «អ្វីដែលសំខាន់បំផុតចំពោះទិដ្ឋភាពរួមការរំលោភបំពាននេះ បណ្តាលមកពីការយល់ដឹងពួកគាត់នៅមានកម្រិត ហើយវិធីសាស្ត្រលួងលោមរបស់ជនល្មើសរំលោភផ្លូវភេទលើកុមារមួយចំនួននោះ តែងតែប្រើនូវវិធីសាស្ត្រលួងលោមបែបស្មុគស្មាញ ក៏ដូចជាវិធីអូសទាញ ដែលធ្វើឲ្យគ្រួសារមានចំណូលទាប និងមិនមានការយល់ដឹងខ្ពស់ គាត់មិនបានការពារលើកុមារឲ្យបានត្រឹមត្រូវ និងធ្វេសប្រហែសប្រការណាមួយ។ ដូច្នេះស្នើឲ្យការអនុវត្តទោសធ្ងន់ធ្ងរទៅលើជនល្មើសតាមច្បាប់ ព្រោះថា បទល្មើសរំលោភផ្លូវភេទលើកុមារ គឺជាទង្វើមួយដែលធ្វើឲ្យប៉ះពាល់ដល់កុមារធ្ងន់ធ្ងរនិងបន្តទៅមុខទៀត ដែលពួកគេទទួលបានពីផលប៉ះពាល់ទាំងនេះ»៕

## ក្រសួងការបរទេសខ្មែរ ជួយសង្គ្រោះពលរដ្ឋខ្លួន ជាង៨ពាន់នាក់ ដែលរងការរំលោភបំពាន នៅបរទេស

https://www.dap-news.com/ ByID:114 Posted on 05 March 2019 | 13:05

ភ្នំពេញ ៖ ក្រសួងការបរទេសខ្មែរ បានជួយសង្គ្រោះ និងអន្តរាគមន៍ពលករ-ពលការិនី ដែលរងគ្រោះពីការរំលោភបំពាននៅ បរទេស និងធ្វើមាតុភូមិនិវត្តន៍ ចំនួន៨៤៨៩នាក់។ យោងតាមរបាយការណ៍ ស្តីពីសមិទ្ធផលដែលក្រសួងការបរទេសខ្មែរ សម្រេចបានក្នុងឆ្នាំ២០១៨ នាព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩នេះ បានឲ្យដឹងថា "ក្រសួងការបរទេសខ្មែរ បានជួយអន្តរាគមន៍សង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ប្រជាពលរដ្ឋខ្មែរ ជាពិសេស ពលករ-ពលការីនីដែលរងគ្រោះពីការរំលោភបំពាន នៅបរទេសបានចំនួន៨៤៨៩ នាក់" ។ ជាមួយគ្នានេះដែរ ក្រសួងការបរទេសខ្មែរ ក៏បានចាត់បញ្ជូនបេសកកម្មសុច្ឆន្ទៈ ទៅបកស្រាយបំភ្លឺជូនឥស្សរជនសំខាន់ៗ នៃគណៈកម្មការអឺរ៉ុប និងជួបពិភាក្សា

ជាមួយសមាជិក សភាសហភាពអឺរ៉ុបមួយចំនួនផងដែរ ។ ក្នុងនោះ បានចរចាជាមួយប្រទេសជិតខាង ក្នុងការដោះស្រាយបញ្ហាព្រំដែនសេសសល់ ដោយសន្តិវិធី ដើម្បីប្រែក្លាយតំបន់ ព្រំដែនឲ្យទៅជាតំបន់ សន្តិភាព មិត្តភាពកិច្ចសហ-ប្រតិបត្តិការ និងការអភិវឌ្ឍ៕ ដោយ៖ នឿត សម្ផស្ស

## ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩

### នាយករដ្ឋមន្ត្រី ផ្តល់អនុសាសន៍ ៥ចំណុច ដើម្បីលើកស្ទួយតួនាទីស្ត្រី

https://www.dap-news.com/ ByID:114 Posted on 05 March 2019 | 13:12

ភ្នំពេញ ៖ ដើម្បីលើកស្ទួយនូវតួនាទីស្ត្រី ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានផ្តល់ជាអនុសាសន៍ចំនួន ៥ចំណុចសំខាន់ៗ ដើម្បីឲ្យភាគីពាក់ព័ន្ធយកទៅអនុវត្តន៍។ ក្នុងឱកាសអញ្ជើញ ជាអធិបតីភាពអបអរសាទរ ទិវាអន្តរជាតិនារី ៨មីនា នៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩ សម្តេចតេជោបានលើកឡើងថា ″ ដើម្បីលើកស្ទួយនូវតួនាទីស្ត្រី ដែលជាឆ្អឹងខ្នង នៃសេដ្ឋកិច្ច និងសង្គមជាតិ ក្នុងកិច្ចគាំពារសង្គម ឲ្យមានប្រសិទ្ធភាពនោះ សូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល វិស័យឯកជន និងជនរួមជាតិទាំងអស់អនុវត្ត នូវចំណុចសំខាន់ៗចំនួន៥ចំណុច″។

**អនុសាសន៍ទាំង៥នោះរួមមាន៖**

ទី១) ត្រូវរួមគ្នាយកចិត្តទុកដាក់ តាមរយៈការផ្តល់អាទិភាព ចំពោះការបង្កើនចំនួនស្ត្រី ដែលមានតួនាទីជាថ្នាក់ដឹកនាំ នៅតាមវិស័យផ្សេងៗ និងគ្រប់កម្រិត ព្រមទាំង តាមដានសមត្ថភាព ដែលមានជំនាញហើយ ត្រូវជួយដោះស្រាយបញ្ហាផ្សេងៗ ដែលកើតមាននៅក្នុងឱកាស បំពេញការងារតាមតួនាទីរបស់ពួកគាត់។

ទី២) ត្រូវរួមគ្នាពង្រឹងការអនុវត្តច្បាប់ និងត្រូវពន្លឿនដំណើរការកាត់ក្តីស្ត្រី ដែលជាប់ទោសឲ្យទាន់ពេលវេលា ហើយត្រូវសហការគ្នា បង្កើតឲ្យមានមូលដ្ឋានស្ថិតិរួម មកជាផ្លូវការមួយ ដែលអាចតាមដានស្ថានភាពពួកគាត់។

ទី៣) ក្រសួងអប់រំ ត្រូវធ្វើការណែនាំ គ្រប់ក្រសួងស្ថាប័នអនុវត្តវិន័យ ផ្តល់ឱកាសដល់ក្មេងស្រី នៅគ្រប់កំរិតដើម្បីបានសិក្សាមុខវិជ្ជា ជំនាញវិទ្យាសាស្រ្ត បច្ចេកវិទ្យាវិស្វកម្មនិងគណិតវិទ្យាជាដើម។

ទី៤) ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍ និងក្រសួងវប្បធម៌ ត្រូវគ្រប់គ្រងការប្រើប្រាស់ប្រព័ន្ធ Internet នៅទូទាំងប្រទេសឲ្យមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់បញ្ហាជាច្រើន ដែលពាក់ព័ន្ធទៅ អំពើហិង្សា ការកេងប្រវ័ញ្ចលើស្ត្រី និងក្មេងស្រីតាមប្រព័ន្ធ Internet និងបណ្តាញផ្សព្វផ្សាយជាច្រើន ដែលធ្វើឲ្យបាត់សណ្តាប់ធ្នាប់សង្គម។

និងទី៥) ក្រសួងវប្បធម៌ ក្រសួងព័ត៌មាន និងបណ្តាញផ្សព្វផ្សាយទាំងអស់ ត្រូវបន្តពង្រឹង និងលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ តាមរយៈការបង្កើតកម្មវិធីអប់រំ ដែលបង្ហាញអំពីអត្តសញ្ញាណស្ត្រីខ្មែរ ជាពិសេសតាមរយៈ ការស្លៀកពាក់ ប្រកបដោយភាពថ្លៃថ្នូរ និងមានលក្ខណៈជាស្ត្រីខ្មែរ៕ ដោយ៖ បាន ធារ៉ូ

### សម្តេច ហ៊ុន សែន៖ ស្ត្រីធ្វើការតាមផ្ទះ ធ្វើការពេលគេឈប់សម្រាក...តើយើងយល់អារម្មណ៍មួយនេះទេ?

https://thmeythmey.com 06, Mar 2019 , 8:59 am ដោយ: ធឿន បញ្ញាឬទ្ធិ

ភ្នំពេញ៖ ជាថ្មីម្តងទៀត សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អំពាវនាវឲ្យម្ចាស់ផ្ទះទាំងអស់ ត្រូវយោគយល់ និងអាធ្យាស្រ័យដល់ស្ត្រីដែលបម្រើការងារនៅក្នុងផ្ទះ ដោយមិនត្រូវធ្វើទុក្ខបុកម្នេញដល់ពួកគេនោះទេ។ ថ្លែងក្នុងពិធីអបអរសាទរទិវានារីអន្តរជាតិ នៅព្រឹកថ្ងៃអង្គារ ទី៥ ខែមីនា សម្តេច ហ៊ុន សែន ដែលដឹងពីសុខទុក្ខស្ត្រីបម្រើការងារតាមផ្ទះនោះ បានរៀបរាប់ថា ស្ត្រីធ្វើការងារតាមផ្ទះ គ្មានពេលសប្បាយដូចគេឡើយ ពោលគឺនៅថ្ងៃបុណ្យជាតិ ពលរដ្ឋទូទៅ

តែងតែមានពេលឈប់សម្រាក ប៉ុន្តែស្ត្រីធ្វើការតាមផ្ទះ គ្មានពេលឈប់សម្រាកនោះទេ។ ដោយសារតែបញ្ហានេះហើយ ទើបប្រមុខរដ្ឋាភិបាល ស្នើឲ្យពលរដ្ឋទាំងអស់ ត្រូវគិតគូពីបញ្ហានេះឡើងវិញ ទើបវាជះផលវិជ្ជមាន និងគ្មានការរើសអើងរវាងម្ចាស់ផ្ទះ និងអ្នកបម្រើនៅក្នុងសង្គម ។ «សូម្បីពេលបុណ្យទាន តើគ្នា(ស្ត្រីបម្រើការងារតាមផ្ទះ)មានពេលឯណាទៅសម្រាកដូចគេ បើគ្នាទៅសម្រាកតើអ្នកណាដាំបាយឲ្យយើងស៊ី រឿងវានៅកន្លែងហ្នឹង។ អ៊ីចឹង បានជាយើងត្រូវយកចិត្តទុកដាក់ ព្រោះគ្នាធ្វើដោយសារតែគ្នាក្រ។ ជួនកាល អ្នកខ្លះចោលប្តី ចោលកូននៅផ្ទះ ហើយមកធ្វើការបម្រើយើង។ នៅពេលដែលបានស៊ីឆ្ងាញ់ នឹកដល់កូន នឹកដល់ប្តីដែលកំពុងពិបាកនៅឯណោះ(ផ្ទះ)។ អ៊ីចឹងតើយល់ទេ អារម្មណ៍មួយនេះ?...។ នេះជាការលើកឡើងរបស់សម្តេច ហ៊ុន សែន។ ក្រៅពីហាមម្ចាស់ផ្ទះធ្វើបាបស្ត្រីបម្រើការងារក្នុងផ្ទះហើយ ប្រមុខរដ្ឋាភិបាល ក៏ស្នើឲ្យម្ចាស់ផ្ទះទាំងនោះ ត្រូវផ្តល់ប្រាក់ខែសមរម្យដល់ពួកគេ ដើម្បីឲ្យពួកគេអាចមានលទ្ធភាពរស់នៅ ក្នុងជីវភាពថ្លៃថ្នូរនៅក្នុងសង្គម៕

## កម្ពុជា និងសិង្ហបុរី បន្តសហការទប់ស្កាត់រាល់បទល្មើស ការប្រឆាំងភេរវកម្ម ការប្រឆាំងបទល្មើសបច្ចេកវិទ្យា និងបទល្មើសឆ្លងដែន

http://www.cen.com.kh/archives/ March 5, 2019

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេងឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានសម្តែងការគាំទ្រ និងស្វាគមន៍ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងអគ្គស្នងការដ្ឋាននគរបាលជាតិកម្ពុជា និងអគ្គស្នងការដ្ឋាននគរបាលជាតិសិង្ហបុរី លើកិច្ចសហការទប់ស្កាត់បទឧក្រិដ្ឋឆ្លងដែន និងប្រយុទ្ធប្រឆាំងអំពើភេរវកម្មរួមគ្នា ។ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឲ្យ លោក Hoong Wee Teck អគ្គស្នងការនគរបាលសឹង្ហបុរី ដើម្បីចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នារសៀលថ្ងៃចន្ទ ១៣រោច ខែមាឃ ឆ្នាំចសំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងមហាផ្ទៃ ។

សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា វាជាការល្អបំផុតដែលភាគីកម្ពុជា និងសិង្ហបុរី បន្តសហការគ្នាក្នុងការទប់ស្កាត់ រាល់បទល្មើសឧក្រិដ្ឋផ្សេងដូចជា ការប្រឆាំងភេរវកម្ម ការប្រឆាំងបទល្មើសបច្ចេកវិទ្យា និងបទល្មើសឆ្លងដែនៗទៀត។ សម្តេចក្រឡាហោម បានបន្ថែមថា កម្ពុជាពិតជាអរគុណយ៉ាងខ្លាំងចំពោះរដ្ឋាភិបាល ក៏ដូចជាអគ្គស្នងការនគរបាលជាតិសិង្ហបុរី ដែលបានជួយដល់កម្ពុជាតាំងពីដើមរហូតដល់បច្ចុប្បន្ននេះ ជាពិសេសនគរបាលសិង្ហបុរី បានជួយផ្តល់វគ្គបណ្តុះបណ្តាលជំនាញផ្នែកបង្ក្រាបបទឧក្រិដ្ឋឆ្លងដែនដល់នគរបាលកម្ពុជា។ យ៉ាងណាក៏ដោយ សម្តេចក្រឡាហោម បានរំពឹងថាកិច្ចសហប្រតិបត្តិការទ្វេភាគី រវាងនគរបាលនៃប្រទេសទាំងពីរ នឹងកាន់តែល្អប្រសើរបន្ថែមទៀត ដើម្បីធ្វើយ៉ាងណារួមសហការគ្នាទប់ស្កាត់រាល់បទល្មើសផ្សេងៗ ក្នុងគោលបំណងការពារផលប្រយោជន៍រួមនៃប្រជាជន និងប្រទេសទាំងពីរ ក៏ដូចជាផលប្រយោជន៍ទាំងថ្នាក់តំបន់ និងពិភពលោក។

ថ្លែងនៅក្នុងកិច្ចជំនួបនោះដែរ លោក HOONG WEE TECH បានលើកឡើងថា ប្រទេសកម្ពុជា និងសឹង្ហបុរី គឺជាមិត្តដ៏ល្អនឹងគ្នា ហើយសិង្ហបុរីរីករាយជានិច្ច ចំពោះកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយកម្ពុជា ហើយសិង្ហបុរី នឹងបន្តជួយបើកវគ្គបណ្តុះបណ្តាល នូវជំនាញផ្សេងៗទៀត ដល់កម្ពុជាគ្រប់ពេលវេលា ជាពិសេសជំនាញផ្នែកនគរបាលតែម្តង ៕ ដោយ ៖ កូឡាប

## ប្ដី-ប្រពន្ធ២នាក់ ដែលជាមេការហាងកាត់សក់ឃីហោ «លីណា»បង្កប់សេវាផ្លូវភេទ ត្រូវតុលាការចេញដីកាឃុំខ្លួនដាក់គុកព្រៃស

http://nokorwatnews.com/ 05-03-2019

ភ្នំពេញ៖ កាលពីរសៀលថ្ងៃអង្គារ ១៤រោច ខែមាឃ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី៥ ខែមីនា ឆ្នាំ ២០១៩ លោក ឡុង វណ្ណា ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចចេញដីកាឃុំខ្លួន ជនត្រូវចោទ២នាក់ប្ដី-ប្រពន្ធ ដែលជាមេការហាងកាត់សក់ឃីហោ «លីណា» លួចបង្កប់សេវាផ្លូវភេទ ជាបណ្ដោះអាសន្ននៅគុកព្រៃស ។

យោងតាមប្រភពពីសមត្ថកិច្ច បានឲ្យដឹងថា ជនត្រូវចោទទាំង២នាក់នោះទី១ ឈ្មោះ លឹម ដីណាម អាយុ ៣៧ឆ្នាំ ជាប្រពន្ធ និងទី២ឈ្មោះ មិត្ត ចិន្តា ហៅច័ន្ទ អាយុ៣៧ឆ្នាំ ជាប្ដី ត្រូវបានតុលាការសម្រេចឃុំខ្លួនក្រោមបទចោទ «សញ្ចារកម្ម» យោងតាមមាត្រា ២៦ នៃច្បាប់ស្ដីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ គួរបញ្ជាក់ផងដែរថា កាលពីរសៀលថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩កន្លងទៅនេះ កម្លាំងនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ បានឃាត់ខ្លួនជនត្រូវចោទទាំង២នាក់ខាងលើនេះ ស្ថិតនៅចំណុចហាងកាត់សក់ឃីហោ «លីណា» មានទីតាំងផ្ទះលេខ៨៤ ផ្លូវ៦៣ ភូមិ១១ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ ក្នុងប្រតិបត្តិការបង្ក្រាបទីតាំងខាងលើ សមត្ថកិច្ចបានជួយសង្គ្រោះ នារីរងគ្រោះចំនួន០៧នាក់ ។

បច្ចុប្បន្នជនត្រូវចោទទាំង២នាក់ ត្រូវកម្លាំងនគរបាលនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ បញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ននៅគុកព្រៃស រង់ចាំបន្តនីតិវិធីនាពេលក្រោយ ៕ស តារា

## ថៃបញ្ជូនពលរដ្ឋខ្មែរ ៣នាក់ឲ្យមកកម្ពុជាវិញ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/ General Department of Immigration - GDI 05-03-2019

ឧត្តរមានជ័យ៖ នៅថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩ ខាងភាគីថៃ បានបញ្ជូនពលរដ្ឋខ្មែរ ៣នាក់ឲ្យ មកប៉ុស្តិ៍នគរបាលច្រកទ្វារអន្តរជាតិជាំពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅថៃ ដែលចេញតាមច្រកចំការគ ខេត្តបន្ទាយមានជ័យ៕

# ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩

## លោក សុខ ឥសាន៖ ប្រទេសមានសន្តិភាព ទើបធ្វើឲ្យពលករខ្មែរ ចំណាកស្រុក ស្វែងរកការងារ នៅក្រៅប្រទេសស្រួល

https://www.dap-news.com/ ByID:119 Posted on 07 March 2019 | 09:15

**ភ្នំពេញ៖** អ្នកនាំពាក្យ គណបក្សប្រជាជនកម្ពុជា លោក សុខ ឥសាន បានអះអាងថា ដោយសារប្រទេសកម្ពុជាមានសុខសន្តិភាពទើបបានជាពលករខ្មែរ ចំណាកស្រុក ទៅរកការងារធ្វើ នៅក្រៅស្រុកច្រើន។

លោក សុខ ឥសាន បានឲ្យដឹងតាមប្រព័ន្ធតេឡេក្រាម នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ថា មានមតិមួយចំនួន និយាយថា ការដែលមានពលករ ចំណាកស្រុកពីកម្ពុជា ច្រើននៅបរទេស ដោយសារកម្ពុជា គ្មានសន្តិភាព ប៉ុន្តែនេះជាការគិតខុសទេ។ លោកបញ្ជាក់ថា "ការនិយាយនេះ មិនត្រឹមត្រូវតាមការពិតទេ ដោយសារតែប្រទេស មានសន្តិភាពហ្នឹងហើយ បានជារាជរដ្ឋាភិបាល មានលទ្ធភាពចេញលិខិតឆ្លង ដែនឲ្យពលករចេញ ទៅក្រៅប្រទេស មានគោលនយោបាយ ទាក់ទងរកទីផ្សារពលកម្ម នៅក្រៅប្រទេសបាន ដើម្បីពលករមានការងារធ្វើ" ។ លោក សុខ ឥសាន បន្តថា ផ្ទុយទៅវិញ បើប្រទេសមានសង្គ្រាម អត់មានពលករចំណាកស្រុក រៀបរយចេញទៅធ្វើការ ឯបរទេសទេ ពេលនោះ គេហៅថា ជាជនភៀសខ្លួន ឬភៀសសឹក ដែលបណ្តាប្រទេសទាំងនោះ នឹងមិនទទួលយកទេ ។ ដូច្នេះ ការដែលមានពលករចំណាកស្រុកខ្មែរ បានទៅធ្វើការច្រើន ដោយសារនយោបាយ ការបរទេស របស់រាជរដ្ឋាភិបាលកម្ពុជា មាន

ទំនាក់ទំនងល្អ ជាមួយបណ្តាប្រទេស ក្នុងពិភពលោក ទើបយល់ព្រមទទួលយក ពលករខ្មែរ ។ មិនមែនដូចអតីតបក្សប្រឆាំង និយាយថា រាជរដ្ឋាភិបាលកម្ពុជា អសមត្ថភាព រកការងារឲ្យពលករធ្វើការ នៅក្នុងស្រុកបាននោះទេ ។ ពួកគេចោទរាជរដ្ឋាភិបាលថា ចង់ឲ្យកូនខ្មែរ ទៅធ្វើខ្ញុំកញ្ជះគេឯបរទេស ។ លោកបន្ថែមថា ពលរដ្ឋចំណាកស្រុក បានទទួលផលប្រយោជន៍ ជាច្រើន ដូចជា ពលករមានប្រាក់ចំណូល ដើម្បីយកមកផ្គត់ផ្គង់ក្រុមគ្រួសារ លើកកម្ពស់ជីវភាពរស់នៅ ឲ្យប្រសើរឡើង ។ មានចំណូលមក ក្នុងប្រទេសរួមចំណែក ដល់សេដ្ឋកិច្ចជាតិ ។ នៅកម្ពុជា បានចំណូលជាង ២០០០លានដុល្លារ ក្នុង១ឆ្នាំ ៗ ដោយសារពលករចំណាកស្រុក ។ អ្នកនាំពាក្យបក្សកាន់អំណាចថា សរុបមក ជារឿងធម្មតា ដែលបណ្តាប្រទេស លើពិភពលោក មានពលករចំណាកស្រុក ហើយប្រទេសនានា មានពលករចំណាកស្រុកច្រើនជាងកម្ពុជាផង ។

បើតាមរបាយការណ៍ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករកម្ពុជា បានកំពុងធ្វើការនៅក្រៅប្រទេស ជាង១លាននាក់ ៕ ដោយ ស សំណាង

## រដ្ឋមន្ត្រីក្រសួងការងារ បានដាក់ចេញនូវទិសដៅការងារចំនួន ២៤ចំណុច ដើម្បីឱ្យមន្ត្រីរាជការក្រោមឱវាទ បន្តសហការគ្នាខិតខំប្រឹងប្រែងអនុវត្ត នៅឆ្នាំ២០១៩

http://www.cen.com.kh/archives/ March 8, 2019

(ភ្នំពេញ) ៖ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញ សេចក្តីជូនដំណឹង ស្តីពីលទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ និងការប្រកាសដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ ។ ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ចេញនូវទិសដៅការងារចំនួន ២៤ចំណុច ដើម្បីឱ្យមន្ត្រីរាជការក្រោមឱវាទបន្តសហការគ្នាខិតខំប្រឹងប្រែងអនុវត្ត នៅឆ្នាំ២០១៩ ។ លោករដ្ឋមន្ត្រី អ៊ិត សំហេង បានផ្តល់អនុសាសន៍ថា ឆ្នាំ២០១៩នេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ ត្រូវអនុវត្តការងារសំខាន់ៗចំនួន ២៤ចំណុច រួមមាន ៖

១.បន្តខិតខំអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវអនុសាសន៍ណែនាំទាំង ១០ចំណុច របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ដើម្បីគាំពារ និងសម្រួលដល់បន្ទុកចំណាយ ក៏ដូចជាដោះស្រាយបញ្ហានានារបស់កម្មករនិយោជិត។

២៖ បន្តសិក្សាស្រាវជ្រាវលទ្ធភាពធ្វើវិសោធនកម្មច្បាប់ និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងសិទ្ធិ និងលក្ខខណ្ឌការងារ ស្របតាមតម្រូវការសង្គម-សេដ្ឋកិច្ច។

៣៖ ពង្រឹងគុណភាព និងប្រសិទ្ធភាពអធិការកិច្ចការងារ ដោយដាក់ឱ្យប្រើប្រាស់របាយការណ៍អធិការកិច្ចការងាររួមលើប្រព័ន្ធទិន្នន័យស្វ័យប្រវត្តិកម្មដែលអាចធ្វើការសំយោគ និងវាយតម្លៃលក្ខខណ្ឌការងារដោយស្វ័យប្រវត្តិ។

៤៖ កែសម្រួលវិធីសាស្ត្រចុះធ្វើអធិការកិច្ចការងារ ដោយផ្អែកលើកម្រិតហានិភ័យរបស់សហគ្រាស គ្រឹះស្ថាន និងកំណត់ការធ្វើអធិការកិច្ចការងារលើសហគ្រាស គ្រឹះស្ថាននាំចេញចំនួន ១លើក/ឆ្នាំ។

៥៖ ប្រកាសកំណត់លក្ខខណ្ឌការងារស្នូល ៣១ចំណុច និងលក្ខខណ្ឌការងារទូទៅ ៤១ចំណុច ដែលសហគ្រាស គ្រឹះស្ថានត្រូវអនុវត្ត។

៦៖ បន្តពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ចការងារ ដោយបង្កើតឱ្យមានគ្រូបង្គោលលើវិស័យការងារយ៉ាងតិចចំនួន ៥០នាក់ និងធ្វើវិក្រឹត្យការដល់មន្ត្រីអធិការកិច្ចការងារយ៉ាងតិចចំនួន ៤៥០នាក់ ជាមួយនឹងការប្រឡងបញ្ជាក់សមត្ថភាពក្រោយពេលវគ្គវិក្រឹត្យការ។

៧៖ ផ្សព្វផ្សាយ និងបញ្ជ្រាបចំណេះដឹងអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ ជាពិសេសអំពីសិទ្ធិការងារដល់ប្រតិភូបុគ្គលិក ប្រតិភូសហជីព ថ្នាក់ដឹកនាំសហជីពយ៉ាងតិចចំនួន ១,២០០នាក់ និងដល់បុគ្គលិករដ្ឋបាលនៃសហគ្រាស គ្រឹះស្ថានយ៉ាងតិចចំនួន ៧៥០នាក់។

៨៖ បន្តសហការជាមួយគម្រោងកម្មវិធីរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) គម្រោងបទដ្ឋានសង្គម និងការងារក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរនៅទ្វីបអាស៊ី (GIZ, SLSG) នៅប្រទេសកម្ពុជា និងគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងជាសកលរបស់ស៊ុយអ៊ែត។

៩៖ បន្តទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុត នៃកម្លាំងពលកម្មកុមារ និងការងារដោយបង្ខំ។

១០៖ បន្តខិតខំដោះស្រាយវិវាទការងារ ជូនដល់គ្រប់ភាគីពាក់ព័ន្ធឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ដោយសិក្សាជាមួយក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដើម្បីបញ្ចូលការដោះស្រាយវិវាទបុគ្គលមួយចំនួន ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាលព្រមទាំងខិតខំទប់ស្កាត់ការធ្វើកូដកម្មបាតុកម្មខុសច្បាប់ ដោយឈរលើគោលការណ៍ច្បាប់ និងនីតិរដ្ឋ។

១១៖ ជំរុញប្រែក្លាយសហគ្រាស គ្រឹះស្ថានមួយជាសហគមន៍សុខសាន្តមួយរបស់កម្មករនិយោជិត ដែលពោរពេញដោយសមត្ថភាព ផលិតភាព ឥរិយាបថការងារ និងមនសិការវិជ្ជាជីវៈខ្ពស់។

១២៖ រៀបចំកញ្ចប់ស្តង់ដារបណ្តុះបណ្តាលផ្អែកលើសមត្ថភាព (CBT) ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិត ១ ២ ៣ ៤ លើវិស័យអគ្គិសនី-អេឡិចត្រូនិក(២មុខរបរ-៣គុណវុឌ្ឍិ)មេកានិករថយន្ត(៤មុខរបរ-៦គុណវុឌ្ឍ) សំណង់ (៣មុខរបរ-៥គុណវុឌ្ឍ) និងវិស័យធុរកិច្ច-ព័ត៌មានវិទ្យា (១មុខរបរ-២គុណវុឌ្ឍ) សរុប១០មុខរប-១៦គុណវុឌ្ឍ។

១៣៖ បង្កើនចំនួនសិស្សទទួលបានសេវាអប់រំបណ្ដុះបណ្ដាល បច្ចេកទេស និងវិជ្ជាជីវៈ លើជំនាញអាទិភាព៖ វគ្គខ្លី (ក្រោម១ឆ្នាំ) យ៉ាងតិចចំនួន ២៧,០០០នាក់, រយៈពេលវែង សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ ១, ២, ៣ (CQF2,3,4) យ៉ាងតិចចំនួន ៤,០៥០នាក់ សញ្ញាបត្រជាន់ខ្ពស់-បរិញ្ញាបត្ររង បច្ចេកទេស-ឯកទេស (CQF5) យ៉ាងតិចចំនួន ៥,៥០០នាក់ និងសញ្ញាបត្របច្ចេកវិទ្យា ឬឯកទេសវិស្វករយ៉ាងតិចចំនួន ៦,០០០នាក់ ដែលនឹងកើនឡើង ២០% ជារៀងរាល់ឆ្នាំ។

១៤៖ រៀបចំយន្តការ និងកម្មវិធីបណ្ដុះបណ្ដាលជំនាញឡើងវិញ (Reskilling) និងយន្តការជាមួយដៃគូពាក់ព័ន្ធ ដើម្បីផ្តល់ឥណទានដល់សិក្ខាកាម សិស្ស និស្សិត ដែលបញ្ចប់វគ្គបណ្តុះបណ្តាល ដើម្បីបង្កើតមុខរបរខ្លួនឯង។

១៥៖ កែសម្រួលលិខិតបទដ្ឋាន ដែលផ្តល់ភាពស្មើគ្នារវាងកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងកាតព្វកិច្ចហ្វឹកហាត់ការងារ-កម្មសិក្សា និងពង្រឹងការហ្វឹកហ្វឺនកូនជាង និងកម្មសិក្សា និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។

១៦៖ ពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងធ្វើសមាហរណកម្មកម្មវិធីការងារសមរម្យ សម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ និងកម្មវិធីរបស់ដៃគូអភិវឌ្ឍ។

១៧៖ បន្តលើកកម្ពស់ការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាព ដោយពង្រីកយន្តការ «វេទិកាការងារ» ព្រមទាំងការជំរុញកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់កម្លាំងពលកម្ម ជាមួយបណ្តាប្រទេសដៃគូ ជាពិសេសបង្កើតសេវាគាំទ្រដល់ពលករទេសន្តប្រវេសន៍ខ្មែរ សំដៅធានាបាននូវការគាំពារពលករទេសន្តប្រវេសន៍ខ្មែរ និងក្រុមគ្រួសារ។

១៨៖ បន្តពង្រីកការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងការរៀបចំ ការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គម ផ្នែកសោធននិវត្តន៍ នៅឆ្នាំ២០១៩ ពង្រីកការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ពង្រីកការអនុវត្តប្រកាសអន្តរក្រសួងស្តីពី ការអនុវត្តការថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិត ជាស្ត្រីនៅពេលសម្រាលកូន។

១៩៖ បង្កើនការអប់រំ ការផលិតស្ព័តអប់រំ និងការផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍ ដើម្បីបង្ការទប់ស្កាត់គ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ និងការជួលសន្លប់។

២០៖ បន្តការអនុវត្តផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្តអនុសាសន៍របស់អង្គការ ILO ពាក់ព័ន្ធនឹងសេរីភាពអង្គការវិជ្ជាជីវៈ ដើម្បីជំរុញការលើកកម្ពស់ការអនុវត្តសេរីភាពអង្គការវិជ្ជាជីវៈនៅកម្ពុជា។

២១៖ ពង្រឹងសមត្ថភាពមន្ត្រី និងអង្គភាពក្នុងការផ្តល់សេវាសាធារណៈនានា ប្រកបដោយភាពទន់ភ្លន់ ក្រមសីលធម៌វិជ្ជាជីវៈ និងទាន់ពេលវេលាជូនប្រជាពលរដ្ឋ ជាពិសេសកម្មករនិយោជិត ស្របតាមគោលការណ៍វិមជ្ឍការ និងវិសហមជ្ឍការ។

២២៖ កសាងឱ្យបាននូវប្រព័ន្ធរដ្ឋបាល និងហិរញ្ញវត្ថុប្រកបដោយតម្លាភាព គណនេយ្យភាព និងការត្រួតពិនិត្យវាយតម្លៃមួយត្រឹមត្រូវ និងទៀងទាត់ ដើម្បីធ្វើជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តអភិក្រមទាំង៥ គឺ«ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់» និងបាវចនាកែទម្រង់ផ្ទៃក្នុងរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី។

២៣៖ ជំរុញ និងលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋ-វិស័យឯកជន (Public-Private Partnership) ភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ ស្របតាមបាវចនា «បង្កើនមិត្តខាងក្រៅ ក្នុងស្មារតីឯករាជ្យ» របស់សម្តេចតេជោនាយករដ្ឋមន្ត្រី។

២៤៖ រៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងាររបស់គ្រប់អង្គភាពក្រោមឱវាទក្រសួង ដោយបង្កើតក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣៕ ដោយៈកូឡាប

## ឃាត់ខ្លួនជនសង្ស័យម្នាក់ ប្រើត្រាក្លែងក្លាយបោះលើលិខិតឆ្លងដែន ដើម្បីពន្យារសុពលភាពឲ្យពលករខ្មែរ ធ្វើការនៅថៃ

http://www.cen.com.kh/archives/ March 9, 2019

បន្ទាយមានជ័យ ៖ បុរសម្នាក់ ប្រើត្រាក្លែងក្លាយ បោះលើលិខិតឆ្លងដែនពិតប្រាកដ ដើម្បីពន្យារសុពលភាពឲ្យពលករខ្មែរកំពុងធ្វើការនៅប្រទេសថៃ ត្រូវនគរបាល ស្រាវជ្រាវឃាត់ខ្លួនបានហើយ កាលពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ នៅក្រុងប៉ោយប៉ែត។

លោកវរសេនីយ៍ឯក ធិនែ ស៊ិនដេត អធិការ នៃអធិការដ្ឋាននគរបាលក្រុងប៉ោយប៉ែត បានបញ្ជាក់ថា សមត្ថកិច្ចនគរបាល នៅអធិការដ្ឋាននគរបាលក្រុងប៉ោយប៉ែត និងមានការសម្របសម្រួល ពីព្រះរាជអាជ្ញាអមសាលាដំបូង ខេត្តបន្ទាយមានជ័យ បានឃាត់ខ្លួនបុរសម្នាក់នេះ ពិតប្រាកដមែន ក្នុងករណីក្លែងត្រា និងបោះត្រាពន្យារសុពលភាព យកប្រាក់ពីពលករខ្មែរ ដែលឆ្លងដែនទៅធ្វើការនៅប្រទេសថៃ ដោយសារតម្រួតថៃ ពិនិត្យឃើញត្រាក្លែងក្លាយ និងមានភាពមិនប្រក្រតី ដែលវាយនៅលើប៉ាសស្ព័រ ហើយបានចាប់ឃាត់ខ្លួន ពលករខ្មែរជាច្រើននាក់ តែត្រូវបាន អគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ សុំធានាមកវិញ ហើយទំនាក់ទំនងមកនគរបាល ទើបលោកដាក់ កម្លាំងស្រាវជ្រាវអស់រយៈពេលមួយខែ ទើបរកឃើញមុខសញ្ញានេះ។ បច្ចុប្បន្នមុខសញ្ញា ត្រូវកសាងសំណុំរឿង បញ្ជូនទៅតុលាការ ដើម្បីចាត់ការតាមច្បាប់។

គួរបញ្ជាក់ថា កាលពីថ្ងៃ៨ ខែមករា ឆ្នាំ២០១៩ កម្លាំងជំនាញនគរបាល បានទទួលជនរងគ្រោះ ពីស្ថានអគ្គកុងស៊ុល ប្រចាំខេត្ត ស្រះកែវ ប្រទេសថៃ ដែលត្រូវបានអាជ្ញាធរថៃចាប់ខ្លួនពីករណីប្រើប្រាស់ លិខិតឆ្លងដែនពិតប្រាកដ តែត្រាពន្យារសុពលភាពក្លែងក្លាយ ឈ្មោះ ខាត់នី ផល្លី ភេទស្រី អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ មានទីលំនៅភូមិតាសល់ ឃុំចំនោម ស្រុកមង្គលបុរី បន្ទាយមានជ័យ ។ ខណៈនោះជនរងគ្រោះបានដាក់បណ្តឹងប្តឹង ឈ្មោះ

ពេជ្រ រិន ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែររត់ម៉ូតូឌុប មានទីលំនៅភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត បន្ទាយមានជ័យ។

ក្រោយពេលទទួលបណ្តឹងហើយ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវរកឃើញ ឈ្មោះ ពេជ្រ រិទ្ធ ដើម្បីសាកសួរ ដោយសាមីខ្លួនបានប្រាប់ថា ខ្លួនបម្រើការងារនៅក្រុមហ៊ុន B S R O នាំពលករស្របច្បាប់ទៅប្រទេសថៃ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ ក្រុមហ៊ុននៅភ្នំពេញ បានធ្វើលិខិតឆ្លងដែនមួយក្បាល ឈ្មោះ ខាត់នី ផល្លី ដើម្បីពន្យារសុពលភាព ហើយខ្លួនបានយកលិខិតឆ្លងដែនឲ្យទៅ ឈ្មោះ ណារ៉ាត់ ហើយ ណារ៉ាត់ ថា ចាំយកមកឲ្យឈ្មោះ ភស្ស័ បោះត្រាឲ្យ ហើយក៏ប្រគល់ប៉ាសស្ព័រ និងលុយ១០០០បាត។

ក្រោយការសាកសួរ ឈ្មោះ នូ ណារ៉ាត់ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរបាននិយាយថា ខ្លួនពិតជាបានទទួលលិខិតឆ្លងដែន ឈ្មោះ ខាត់នី ផល្លី អាយុ៣១ឆ្នាំ យកមកឲ្យ ឈ្មោះ ភស្ស័ ពន្យារពិតមែន។ ទើបនៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩ ម៉ោង៩ព្រឹក បានហៅ ឈ្មោះ អ៊ឹម សម្ប័ស ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ បានសារភាពថា ខ្លួនពិតជាមានត្រា ពន្យារ ប៉ាសស្ព័រ និងបានបោះត្រាពន្យារមួយរយៈកន្លងមកបានប្រហែល៣០ក្បាល ក្នុងនោះក៏បានយកត្រាមកប្រគល់ជូនសមត្ថកិច្ច ប៉ោយប៉ែតផងដែរ។ បច្ចុប្បន្ន ជនសង្ស័យ ត្រូវបានសមត្ថកិច្ចចាត់ការទៅតាមច្បាប់៕ ដោយៈកូឡាប

## អគ្គនាយដ្ឋានអន្តោប្រវេសន៍ សូមប្រកាសជម្រាប ជូន សាធារណជន ស្តីពីភាពអសកម្ម របស់ មន្ត្រី នគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិ ប៉ោយប៉ែត

http://cambodiapolice.com/policekh/ 3:22 pm 9 មីនា 2019

**ភ្នំពេញ៖** អគ្គនាយដ្ឋានអន្តោប្រវេសន៍ សូមប្រកាសជម្រាប ជូន សាធារណជន ឲ្យបានជ្រាបថា ក្នុងរយៈពេលកន្លងមកថ្មីៗនេះ មានការលើកឡើងចោទប្រកាន់ក្នុងបណ្តាញសង្គម និង សារព័ត៌មានមួយចំនួនស្តីពីភាពអសកម្ម របស់ មន្ត្រី នគរបាលអន្តោប្រវេសន៍ច្រកទ្វារអន្តរជាតិ ប៉ោយប៉ែត ។ ទោះបីការចោទប្រកាន់ទាំងនោះ មិនមានការបង្ហាញ ភស្តុតាជាក់លាក់ក៏ដោយចុះ ប៉ុន្តែក្រុមប្រឹក្សាវិន័យនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក៏បានកោះអញ្ជើញ ថ្នាក់ដឹកនាំ និង មន្ត្រីមួយចំនួននៃប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត ស្រាយបំភ្លឺ និង បានចាត់វិធានការដើម្បីបំបាត់ភាពអសកម្មទាំងឡាយ។ ដើម្បីចៀសវាងភាពអសកម្ម ប៉ះពាល់ដល់ប្រជាពលរដ្ឋដែលធ្វើដំណើរឆ្លងកាត់ព្រំដែន ក៏ដូចជាការរក្សា សណ្តាប់ធ្នាប់ និងការសម្រួលដល់ប្រជាពលរដ្ឋខ្មែរ និង ជនបរទេសទាំងអស់ដែល ធ្វើដំណើរឆ្លងកាត់ព្រំដែនកម្ពុជា ថៃ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានធ្វើការណែនាំអប់រំលោកនាយប៉ុស្តិ៍ឲ្យយកចិត្តទុកដាក់អនុវត្តឲ្យបានត្រឹមត្រូវ តាមតួនាទីភារៈកិច្ច និង ការប៉ះពាល់ដល់ប្រជាពលរដ្ឋ ដោយក្នុងនោះត្រូវយកចិត្តទុកដាក់៖

- ត្រូវដាក់ស្លាកអក្សរសម្គាល់សម្រាប់សាធារណជនឲ្យបានជ្រាបថា ការបម្រើសេវានេះមិនតម្រូវឲ្យមានការបង់ប្រាក់ទេ ។

- រៀបចំកែលម្អរបញ្ជរបំពេញ បែបបទចេញ ចូល ឲ្យបានសមស្របនិងរៀបចំលំហូរអ្នកដំណើរ ឲ្យមានការតម្រង់ជួរត្រឹមត្រូវ តាមលំដាប់មុនក្រោយ ដើម្បីកុំឲ្យមានការឆ្លៀតឱកាសជួយសម្រួល លឿន រហ័ស រកផលប្រយោជន៍ខុសច្បាប់ ។

- ហាមយកប្រាក់ដើម្បីអនុញ្ញាត ឲ្យយានយន្ត រ៉ឺម៉ក ម៉ូតូកង់បី ម៉ូតូឌុប ដែលធ្វើឲ្យបាត់សណ្តាប់ធ្នាប់នៅបរិវេណច្រកទ្វាអន្តជាតិប៉ោយប៉ែត ។

- មន្ត្រីនគរបាលគ្រប់ច្រកទ្វារព្រំដែនទាំងអស់ (រួមទាំងក្រៅពីច្រកទ្វារអន្តរជាតិ ប៉ោយប៉ែត) ត្រូវយកចិត្តទុកដាក់ និងបង្កលក្ខណៈងាយស្រួលដល់ពលរដ្ឋខ្មែរ និងបរទេសដែលធ្វើដំណើរឆ្លងកាត់ព្រំដែន ជាពិសេស ពលករដែលធ្វើការនៅប្រទេសថៃក្នុងរដូវចូលឆ្នាំខ្មែរខាងមុខឆាប់ៗនេះដោយមិនត្រូវទទួលប្រាក់កាសឡើយ ។

- ត្រូវពង្រឹងការគោរពបទបញ្ជា វិន័យរបស់កងកម្លាំងនគរបាលជាតិ អប់រំសីលធម៌ ឥរិយាបថ និង អកប្ប-កិរិយា បំពេញការងាររបស់មន្ត្រី យកចិត្តទុកដាក់លើមុខជំនាញវិជ្ជាជីវៈរបស់ខ្លួន និង ធ្វើការដាក់វិន័យយ៉ាងតឹងរ៉ឹងបំផុត ចំពោះមន្ត្រីដែលបានប្រព្រឹត្តខុសឆ្គង។

អាស្រ័យហេតុនេះសូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និង ជួយចូលរួមផ្តល់យោបល់ក្នុងន័យស្ថាបនា ដើម្បីផ្តល់ឱកាសឲ្យមន្ត្រីនគរបាលយើងកែលម្អសកម្មភាពការងារក្នុងការផ្តល់សេវាដល់ពលរដ្ឋកាន់តែល្អប្រសើរថែមទៀត ៕

## សមត្ថកិច្ចបញ្ជូនជនសង្ស័យ ក្លែងលិខិតឆ្លងដែនខុសច្បាប់ ទៅតុលាការ

http://cambodiapolice.com/policekh/ 10:30 am 11 មីនា 2019

បន្ទាយមានជ័យ៖ នគរបាលជំនាញព្រហ្មទណ្ឌកំរិតស្រាល កាលពីថ្ងៃទី១០ ខែ មីនា ឆ្នាំ២០១៩ បានបង្ហាញមុខជនសង្ស័យម្នាក់ បានធ្វើសកម្មភាពក្លែងបន្លំឯកសារសាធារណៈ (ធ្វើលិខិតឆ្លងដែនក្លែងក្លាយ) ឲ្យ ពលករឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ ។

យោងតាមរបាយការណ៍របស់ លោកវរសេនីយ៍ឯក ខែម សុភ័ណ នាយការិយាល័យ នគរបាលព្រហ្មទណ្ឌកំរិតស្រាល បានឲ្យដឹងថា៖ ជនសង្ស័យឈ្មោះ អ៊ឹម សម្ផស្ស ភេទប្រុស អាយុ៣៨ឆ្នាំ មានទីលំនៅភូមិគីឡូម៉ែត្រលេខ៤ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត មុខរបរជាកម្មករ ។ លោកនាយការិយាល័យ បានបញ្ជាក់ថា៖ ក្រោយពីមានបន្តឹងពីជនរងគ្រោះជាពលករជាច្រើននាក់ ដែលបានធ្វើលិខិតឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ ពេលសមត្ថកិច្ចថៃត្រួតពិនិត្យលិខិតឃើញថា ជាលិខិតក្លែងក្លាយ ហើយត្រូវភាគីថៃ ចាប់បញ្ជូនមកវិញនោះ ។

លោកឧត្តមសេនីយ៍ទោ អាត់ ខែម ស្នងការនគរបាល ខេត្តបន្ទាយមានជ័យ បានដាក់ចេញនូវបទបញ្ជា មកដល់កម្លាំងជំនាញនគរបាលព្រហ្មទណ្ឌកំរិតស្រាល ក៏ដូចជាកម្លាំងអធិការដ្ឋានក្រុងប៉ោយប៉ែត បើកការស៊ើបអង្កេតស្រាវជ្រាវ ឈានដល់ការចាប់ឃាត់ខ្លួន ជនសង្ស័យឈ្មោះ អ៊ឹម សម្ផស្ស នៅវេលាម៉ោង៣និង៥០នាទី កាលពីរសៀលថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ ក្នុងភូមិសាស្ត្រក្រុងប៉ោយប៉ែត។

លោកវរសេនីយ៍ឯក ខែម សុភ័ណ បានបន្តថា៖ ក្រោយពីធ្វើការឃាត់ខ្លួននឹងសាកសួរចម្លើយ ជនសង្ស័យបានសារភាពថា៖ខ្លួនគេពិតជាអ្នកបោះត្រាពន្យាលើលិខិតឆ្លងដែន របស់ពលករដែលហួសកាលបរិច្ឆេតនោះមែន ការធ្វើនេះតាំងពីឆ្នាំ២០១៧មកម្លេះ ។ហើយកាលពីឆ្នាំ២០១១ដល់ឆ្នាំ២០១៣ រូបគេធ្លាប់បានធ្វើការងារនៅកន្លែងស្ថានទូតខ្មែរ នៅទីក្រុងបាងកក ផ្នែកខាងពន្យាពេលលិខិតឆ្លងដែន ពេលចាប់ការងារខ្លួនបានត្រឡប់មកនៅប៉ោយប៉ែត ដោយបានទិញត្រាឆ្លាន់ទូតមួយឈុត ។ដោយផ្អែកលើបណ្តឹង ជនរងគ្រោះជាពលករ និងចម្លើយសារភាព ។

បច្ចុប្បន្នជនសង្ស័យ រួមទាំងវត្ថុតាងត្រូវបានកម្លាំងជំនាញ រៀបចំសំណុំរឿងបញ្ជូនទៅទៅតុលាការខេត្ត ដើម្បីចាត់ការតាមនិតិវិធីច្បាប់៕ សម្រួលដោយ៖ លោកស្រី វ.ទោ ជា សារ៉ាត់

## អ្នកស្រី យឹម សុធីៈ ស្ត្រីបម្រើការងារតាមផ្ទះនៅក្រៅប្រទេសបានប្រាក់ខែសមរម្យ តែជួបបញ្ហាច្រើនជាងស្ត្រីបម្រើការងារនៅក្នុងស្រុក

https://thmeythmey.com/ 09, Mar 2019 , 10:59 am

ភ្នំពេញ៖ ស្ត្រីបម្រើការងារតាមផ្ទះនៅក្រៅប្រទេសអាចរកចំណូលបានសមរម្យ តែត្រូវប្រឈមនឹងបញ្ហាធ្ងន់ធ្ងរជាងស្ត្រីបម្រើការងារតាមផ្ទះនៅក្នុងស្រុកដែរ។ នេះបើតាមប្រធានសមាគមអ្នកបម្រើការងារតាមផ្ទះ។ ស្ត្រីបម្រើការងារតាមផ្ទះនៅក្រៅប្រទេស តែងតែជួបបញ្ហាផ្សេងៗដូចជា ប៉ះទង្គិចបញ្ហាផ្លូវចិត្ត និងរងអំពើហិង្សាពីម្ចាស់ផ្ទះ តាមរយៈការបង្ខំឲ្យធ្វើការលើសពីកម្លាំងកាយ និងប្រឈមគ្រោះថ្នាក់ខ្លាំងជាងស្ត្រីបម្រើការងារនៅក្នុងស្រុក ។

អ្នកស្រី យឹម សុធី ដែលធ្វើការងារទាក់ទងនឹងបញ្ហានេះ បាននិយាយថា មូលហេតុដែលនាំឲ្យស្ត្រីបម្រើការងារទាំងនោះប្រឈមនឹងបញ្ហា ដោយសារតែពួកគេមិនទាន់ទទួលបានសេវាការពារសុវត្ថិភាពឲ្យបានទូលំទូលាយនៅឡើយ ដែលផ្ទុយពីស្ត្រីបម្រើការងារនៅក្នុងស្រុក ដែលអាចទទួលបានសេវាណែនាំ និងការពារពីសមាគមអ្នកបម្រើការងារតាមផ្ទះ ។ ថ្លែងប្រាប់សារព័ត៌មានថ្មីៗ ប្រធានសមាគមអ្នកបម្រើការងារតាមផ្ទះរូបនេះ បាននិយាយដូច្នេះថា៖« បញ្ហាដែលស្ត្រីបម្រើការងារតាមផ្ទះនៅក្រៅប្រទេសជួបប្រទះជាញឹកញាប់នោះ គឺការចាញ់បោកមេខ្យល់ និងតែងតែត្រូវបានម្ចាស់ផ្ទះដកហូតលិខិតឆ្លងដែនរបស់ពួកគេ ដោយជាហេតុធ្វើឲ្យពួកគេមិនអាចត្រឡប់មកប្រទេសខ្លួនឯងវិញបានឡើយ។ ចំណែកឯស្ត្រីដែលបម្រើការងារក្នុងស្រុក ទោះបីពួកគេជួបបញ្ហាផ្សេងៗនោះក៏ ពួកគាត់អាចទៅប្តឹអាជ្ញាធរដើម្បីដោះស្រាយបញ្ហានេះ»។ ត្រង់ចំណុចនេះអ្នកស្រី យឹម សុធី ចង់ឲ្យស្ត្រីគួរតែគិតឲ្យបានម៉ត់ចត់ មុននឹងចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស ដ្បិតវាទទួលបានប្រាក់ខែសមរម្យជាងក្នុងស្រុកក្តី។ «ដើម្បីធានាបានសុវត្ថិភាព ស្ត្រីគួរណាស់តែបម្រើការងារនៅក្នុងស្រុក។ ប្រសិនបើពួកគេខិតខំធ្វើការ ស្មោះត្រង់ទៀតណាស់ ច្បាស់ណាស់ម្ចាស់ផ្ទះនឹងអាចដំឡើងប្រាក់ឲ្យកាន់តែខ្ពស់ សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ពួកគេផងដែរ»។ នេះជាការបញ្ជាក់របស់អ្នកស្រី សុធី។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានជួយសង្គ្រោះប្រជាពលរដ្ឋខ្មែរ៨៤៨៩នាក់ ដែលក្នុងនោះក៏មានស្ត្រីបម្រើការងារតាមផ្ទះ ជាពិសេសពលករ-ពលការិនី ដែលរងគ្រោះពីការរំលោភបំពាននៅបរទេស ឲ្យបានធ្វើមាតុភូមិនិវត្តន៍វិញ។ នេះបើតាមរបាយការណ៍ក្រសួងការបរទេស នៅព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩។ កន្លងមករដ្ឋាភិបាល ក៏បានជួយដោះស្រាយបញ្ហាពលករទៅធ្វើការនៅក្រៅប្រទេស ដោយស្នើឲ្យម្ចាស់ប្រទេសសាមី អនុវត្តច្បាប់ការពារនិងគោរពសិទ្ធិពលករខ្មែរឲ្យបានត្រឹមត្រូវដែរប៉ុន្តែការរំលោភបំពានសិទ្ធិការងារលើពលករនេះ នៅតែកើតមាន។

ទាក់ទងនឹងបញ្ហាស្ត្រីបម្រើការងារនៅតាមផ្ទះនេះ រដ្ឋាភិបាលក៏កំពុងរកដំណោះស្រាយសម្រាប់ពួកគេផងដែរ ។ ដ្បិតមិនទាន់ចែងច្បាប់កំណត់ក្តី តែសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើឲ្យម្ចាស់ផ្ទះទាំងអស់ គោរពសិទ្ធិការងារនិងមានការយោគយល់ដល់ស្ត្រីបម្រើការងារតាមផ្ទះ ដើម្បីលុបបំបាត់វប្បធម៌រើសអើង និងការរំលោភសិទ្ធិការងារនៅក្នុងសង្គម។ ជាពិសេសម្ចាស់ផ្ទះ ត្រូវផ្តល់ប្រាក់បៀវត្សឲ្យបានខ្ពស់ដល់ពួកគេ ដើម្បីឲ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ ហើយអាចរស់នៅក្នុងជីវភាពសមរម្យ ។ ស្ត្រីដែលបម្រើការងារតាមផ្ទះទូទាំងរាជធានី-ខេត្ត មានជាង២៥ម៉ឺននាក់ ស្ត្រីទាំងនោះធ្វើការជា ស្ត្រីមើលថែកូន បោសសំអាតផ្ទះ បោកសំលៀកបំពាក់ ធ្វើម្ហូប លាងចានជាដើម។ ខេត្តដែលមានស្ត្រីបម្រើការងារតាមផ្ទះច្រើនជាងគេ គឺខេត្តពោធិ៍សាត់ កំពង់ធំ និងក្រចេះ ហើយពួកគេមានអាយុចាប់ពី១៨ឆ្នាំ ដល់៥០ឆ្នាំ។ ស្ត្រីមួយចំនួនទៀត ក៏បានចំណាកស្រុកទៅក្រៅប្រទេសធ្វើការជាអ្នកបម្រើតាមផ្ទះផងដែរ។ នេះបើតាមរបាយការណ៍៕

## អាសូរណាស់ ជួយស៊ែរឲ្យសម្តេចបានឃើញផង! សិប្បកម្មឡឥដ្ឋមួយប្រើក្មេងមិនគ្រប់អាយុ រហូតចូលម៉ាស៊ីនដាច់ដៃត្រឹមភ្លៀក

http://isharetoday.com/archives/ POSTED BYBRID DONMARCH 10, 2019

កណ្តាល៖ កុមារីវ័យ៩ឆ្នាំម្នាក់បានបានរអិលធ្លាក់ចូលម៉ាស៊ីនកិនដីបណ្តាលឱ្យដាច់ដៃស្តាំម្ខាងគួរត្រឹមភ្លៀកឱ្យសង្វេកខណៈដែលកំពុងធ្វើបញ្ចូលដីទៅក្នុងម៉ាស៊ីនជាមួយឪពុកម្តាយ៖ គ្រោះថ្នាក់នេះបានកើតឡើងកាលពីវេលាម៉ោង០៩និង៣០នាទីព្រឹក ថ្ងៃទី០៩ មិនា ២០១៩ នៅក្នុងសិប្បកម្មឡឥដ្ឋមួយ ស្ថិតក្នុងភូមិព្រះប្រសប់ ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានម្ចាស់ឈ្មោះ លាង ស្រ៊ុន។ ចំណែកឯកុមាររីងគ្រោះឈ្មោះ ឆេង ស្រី ភក្ត្រ័ អាយុ៩ឆ្នាំ ស្នាក់នៅនិងបម្រើការងារក្នុងសិប្បកម្មខាងលើ ជាមួយឪពុកឈ្មោះ ឆេង ប៊ុន ហំ អាយុ៣៧ឆ្នាំ និងម្តាយឈ្មោះ យឹម ចាន់ណា អាយុ៣៣ឆ្នាំ ហើយគ្រួសារនេះបានស្នាក់នៅនិងធ្វើការក្នុងសិប្បកម្មនេះរយៈពេល៦ឆ្នាំមក

ហើយ។ នៅមុនពេលកើតហេតុ ឪពុកម្តាយ ជាអ្ន កដាក់ដីចូលក្នុងម៉ាស៊ីន ចំណែកឯកូនស្រីរងគ្រោះ ជាអ្នកកាត់ឥដ្ឋចេញពីម៉ាស៊ីន និងលើករៀ បឥដ្ឋដាក់លើរទេះ ហើយនៅពេលដែលកំពុងធ្វើការស្រាប់តែ កុមារីរងគ្រោះបានជ្រុលដៃចូលទៅក្នុងម៉ាស៊ីន បណ្តាលឱ្យដាច់ដៃស្តាំម្ខាងត្រឹមក្លៀក ហើយឪពុកម្តាយក៏បញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកស្រុក តែដោយសាររបួសធ្ងន់ធ្ងរពេក ក៏បញ្ជូនបន្តទៅរាជធានីភ្នំពេញ។

លោក លាង ស៊ុន ដែលជាមេការឡូតឥដ្ឋខាងលើ បានទទួលស្គាល់ថា គ្រួសារកុមារីរងគ្រោះពិតជាបានធ្វើការនៅក្នុងសិប្បកម្មរបស់លោកជាង៦ឆ្នាំមកហើយមែន ហើយលោកក៏តែ ងតែបានដាស់តឿនឱ្យមានការប្រុងប្រយ័ត្ន និងប្រាប់កុំឱ្យក្មេងអាយុក្រោម១៨ឆ្នាំធ្វើការដែរ ប៉ុ ន្តែ ឪពុកម្តាយក្មេងស្រីរងគ្រោះ ចេះតែឆ្លើយថាមិនអីៗ ក៏ចេះតែឱ្យធ្វើទៅ ហើយក្រោយពេលកើតហេតុលោកបានឧបត្ថមប្រាក់ចំនួន៥០០ដុល្លារ និងធានាចេញថ្លៃព្យាបាលរហូតជាសះស្បើយ។

ចំណែកឯលោក ធុល នាង ប្រធានមន្ទីរការងារខេត្តកណ្តាល បានប្រាប់តាមទូរសព្ទ័ថា ករណីនេះលោកបានទទួលព័ត៌មានហើយ ហើយក៏បានបញ្ជូនមន្ត្រីឱ្យចុះទៅធ្វើការពិនិត្យស្រាវជ្រាវហើយដែរ ហើយកំពុងរង់ចាំរបាយការណ៍ពីមន្ត្រី ដើម្បីរកឱ្យឃើញថា តើកុមារីដែលរងគ្រោះនោះ បម្រើការងារធ្ងន់ធ្ងរ ឬគ្រាន់តែស្នាក់នៅជាមួយឪពុកម្តាយ ក្នុងសប្បកម្មខាង ទើ បយើងអាចអនុវត្តវិធានការច្បាប់បាន។

គួរបញ្ជាក់ដែរថា យើងតាមច្បាប់ការងារ គឺមិនអនុញ្ញាតឱ្យកុមារអាយុក្រោម១៨ឆ្នាំ បម្រើការងារនៅតាមបណ្តាររោងចក្រ សហគ្រាស ឬសិប្បកម្មនានា ដាច់ខាត ពិសេសនៅតាមសិប្បកម្មឡូតឥដ្ឋតែម្តង ប៉ុន្តែ ជារឿយៗ នៅតែមានកុមាររងគ្រោះដាច់ដៃ ជើង ក្លាយជាក្មេងពិកា រ ដោយសារគ្រោះថ្នាក់ ក្នុងពេលបំពេញការងារក្នុងសប្បកម្មឡូឥដ្ឋ៕

## ថៃត្រៀមបញ្ជូនខ្លួនពលរដ្ឋខ្មែរ ២៣ នាក់ ធ្វើការចែកបៀរ ទៅស្រុកកំណើតវិញ

http://www.pheaktraofficial.com/ By Pheaktra Prak 10/03/2019

ប្រទេសថៃ:យោងតាមរបាយការណ៍ពីអគ្គនាយកដ្ឋាននៃក្រសួងការងារថៃ នៅថ្ងៃអាទិត្យទី១០ ខែមីនា ឆ្នាំ២០១៩ នេះបានអោយដឹងថា ពលរដ្ឋខ្មែរចំនួន ២៣នាក់ និងឡាវចំនួន ២នាក់ ខុសច្បាប់ ដែលលួចធ្វើការចែកបៀរនៅក្នុងបនល្បែង ស៊ីសង មួយក្បែរទីក្រុងបាងកក បន្ទាប់ពីត្រូវកម្លាំងសមត្ថកិច្ចរក្សាសន្តិសុខក្រសួងមហាផ្ទៃថៃ ចាប់ខ្លួនបានកាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ កន្លងទៅនេះបាន សារភាពថាពួកគេ លួចធ្វើការចែកបៀរនិងហៃឡូ ខុសច្បាប់ពិតមែន។ ខាងសមត្ថកិច្ចថៃ កំពុងកសាងសំណុំរឿងដើម្បីចាត់វិធានការតាមផ្លូវច្បាប់ រួចបញ្ជូនអោយវិលត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ចុះប្រវត្តិរូបក្នុងបញ្ជីខ្មៅហាមចូលធ្វើការនៅក្នុងប្រទេសថៃ រយៈពេល០២ឆ្នាំ រាប់ចាប់ពីថ្ងៃទទួលបានទោស។

## កម្ពុជាទទួលពលរដ្ឋ២នាក់ ពីភាគីវៀតណាម

https://www.facebook.com/ General Department of Immigration – GDI 10-03-2019

ក្រចេះ៖ កម្លាំងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងស្រែ នាថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ១៩និង០០នាទី បានទទួលពលរដ្ឋខ្មែរចំនួន ០២នាក់ ពីកម្លាំងប៉ុស្តិ៍រៈយោធាការពារព្រំដែនវៀតណាមលេខ៨០១ហ័រលឺ។ សមត្ថកិច្ចបានឲ្យដឹងថា ពលរដ្ឋខ្មែរទាំងពីរនាក់មាន ១-ឈ្មោះ តាំង វ៉ាន់ធី ភេទប្រុស អាយុ១៩ឆ្នាំ ទីលំនៅត្រពាំងស្រែក្រៅ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ មុខរបរ បើកបរ និង២-ឈ្មោះ យិន ឡុង ភេទប្រុស អាយុ ១៩ឆ្នាំ ទីលំនៅភូមិជើងឃ្លូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ មុខរបរ បើកបរ។

តាមការសាសួរពលរដ្ឋខ្មែរទាំងពីរនាក់ខាងលើ បានបញ្ជាក់ថា ពួកគាត់បានស៊ីឈ្នួលបើកគោយន្តដឹកស្វាយចេញពីប្រទេស ទៅលក់នៅវៀតណាម តាមច្រករបៀង D2 គ្រប់គ្រងដោយវរៈនគរបាលការពារព្រំដែន ៦១៩ ហើយត្រូវឃោជាការពារព្រំដែនវៀតណាម ឃាត់ខ្លួនកាលពីវេលាម៉ោង ០១និង០០នាទី រំលងអាធ្រាត ឈានចូល ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៩។ ក្រោយពីការណែនាំអប់រំ កម្លាំងនគរបាលប៉ុស្តិ៍បានឲ្យសាម៉ីខ្លួន ធ្វើកិច្ចសន្យា និងបានអនុញ្ញាតឲ្យទៅលំនៅដ្ឋានរៀងៗខ្លួនវិញ៕

## សមត្ថកិច្ចថៃចាប់រថយន្តស៊ីឈ្នួលដឹកពលករខុសច្បាប់ នៅព្រំដែន

http://www.pheaktraofficial.com/ By Pheaktra Prak 08/03/2019

ប្រទេសថៃៈកាលពីថ្ងៃព្រហស្បតិ៍ ទី០៧ ខែមីនា ឆ្នាំ២០១៩ ម្សិលមិញនេះ កម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍បានធ្វើការស្ទាក់ចាប់ រថយន្ត Pickup ម៉ាកIZUZU មួយគ្រឿង នៅលើផ្លូវជាតិ ជាតិ ខេត្តស្រះកែវ ក្នុងការឆែកឆេរនៅក្នុងរថយន្ត កម្លាំងសមត្ថកិច្ចថៃបានរកឃើញពលករខ្មែរខុសច្បាប់ប្រុសស្រីរួមទាំងកូនក្មេង ចំនួន ១១នាក់ កំពុងអង្គុយប្រជ្រៀតគ្នាក្នុងរថយន្ត ។ តាមរបាយការណ៍របស់សមត្ថកិច្ចថៃបានប្រាប់អោយដឹងថា ពលករដែលរកឃើញនៅក្នុងរថយន្តខាង លើជាពលករចំណាក់ស្រុកខុសច្បាប់ ធ្វើការទីក្រុងបាងកក តាមការអះអាងរបស់អ្នកបើកបររថយន្តជាជនជាតិថៃ រៀបរាប់ថាមានមេខ្យល់ជាជនជាតិខ្មែរ ទាក់ទងអោយម្ចាស់រថយន្តទៅទទួលពលករទាំងតាមកន្លែងណាត់ ហើយដឹកបន្តទៅព្រំដែនដោយគិតថ្លៃឈ្នួលម្នាក់១៥០០បាត សមត្ថកិច្ចថៃបានឃាត់ខ្លួនម្ចាស់រថយន្តខាងយកទៅកសាងសំណុំរឿងដើម្បីចាត់វិធានការណ៍តាមផ្លូវច្បាប់។

## ទីប្រឹក្សាទទួលបន្ទុកពលករតំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានជួយអន្តរាគមន៍ ដោះស្រាយបញ្ហាជូនប្អូនពលករ

https://www.facebook.com/ ទីប្រឹក្សាទទួលបន្ទុកពលករប្រចាំប្រទេសថៃ March 8 at 6:46 PM

ថ្ងៃសុក្រ ៣កើត ខែផល្គុន ឆ្នាំច ព.ស២៥៦២ ត្រូវនឹងថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៩ៈ ទីប្រឹក្សាទទួលបន្ទុកពលករ តំណាងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះមកខេត្តអយុទ្យា ដើម្បីជួយអន្តរាគមន៍ ដោះស្រាយបញ្ហាជូន ដល់បងប្អូនពលករយើង ដែលនិយោជកបានដកហូតលិខិតឆ្លងដែន និងមិនបើកប្រាក់ឈ្នួលអោយជាច្រើនខែ ដោយសារតែក្រុមហ៊ុនក្ស័យធន ដោយមានការចូលរួមសហការពីសំណាក់មន្ទីរការងារថៃ ការិយាល័យសុខមាលភាព និងគាំពារពលករ មន្ទីរអភិវឌ្ឍន៍សង្គម និងធនធានមនុស្ស ការិយាល័យអន្តោប្រវេសន៍ និងកងកំលាំងរក្សាសន្តិសុខផ្ទៃក្នុងប្រចាំខេត្តអយុធ្យា។ បន្ទាប់ពីការស្វែងរកដំណោះស្រាយរួមគ្នារួចមក និយោជកយល់ព្រមប្រគល់លិខិតឆ្លងដែនជូនដល់ពលករទាំងអស់ និងបានប្រាក់ឈ្នួលជូនដល់ពលករ យើងគ្រប់ចំនួនទាំងអស់ ព្រមទាំងរៀបចំធ្វើលិខិតបណ្តឹងចេញដែលអាច អនុញ្ញាតអោយពលករយើងអាចប្តូរការងារថ្មីបានផងដែរ។

## របាយការណ៍ៈ ស្ត្រីជាង៦០ម៉ឺននាក់ ត្រូវបានជួញដូរខុសច្បាប់តាមព្រំដែនអន្តរជាតិរៀងរាល់ឆ្នាំ

https://thmeythmey.com/ 09, Mar 2019 , 8:39 pm

របាយការណ៍របស់អង្គការសហប្រជាជាតិ និងក្រសួងការបរទេសអាមេរិក បានព្រមានថា ចំនួនជនរងគ្រោះដោយសារតែអសន្តិសុខនៅក្នុងប្រទេសលើពិភពលោក ហើយត្រូវបានគេជួញដូរខុសច្បាប់តាមព្រំដែនជាសកលមានការកើនឡើងគួរឲ្យព្រួយបារម្ភ។ របាយការណ៍ បានរកឃើញផងដែរថា ជនរងគ្រោះភាគច្រើន គឺជាស្ត្រីតែម្តង។

តាមរបាយការណ៍ ស្ដីពីការជួញដូរមនុស្សប្រចាំឆ្នាំ២០១៨ របស់ក្រសួងការបរទេសអាមេរិក ដែលទើបតែចេញផ្សាយនាពេលថ្មីៗនេះ មានមនុស្សចន្លោះពី ៦០ម៉ឺននាក់ ទៅ ៨០ ម៉ឺននាក់ ត្រូវបានគេជួញដូរតាមច្រកព្រំដែនអន្តរជាតិជារៀងរាល់ឆ្នាំ ដែលក្នុងចំណោមជនរងគ្រោះទាំងនោះ មាន៨០ភាគរយគឺជាស្ត្រីភេទ។ របាយការណ៍របស់ក្រសួងការបរទេសអាមេរិកដដែលនោះ ក៏បានរកឃើញផងដែរថា គ្រាន់តែនៅសហរដ្ឋអាមេរិក យ៉ាងហោចណាស់មានមនុស្សប្រមាណ ១៧.០០០នាក់ ត្រូវបានជួញដូររៀងរាល់ ដែលជាចំនួន បានបង្កើតជាក្តីបារម្ភធំមួយសម្រាប់រដ្ឋាភិបាលអាមេរិកផងដែរ។

ស្របជាមួយនឹងរបាយការណ៍របស់អាមេរិក ភ្នាក់ងារជំនាញអង្គការសហប្រជាជាតិលើបញ្ហាគ្រឿងញៀន និងបទល្មើស (UNODC ) ក៏បានធ្វើការស្ទង់មតិ និងរកឃើញផងដែរថា រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ករណីនៃការជួញដូរមនុស្សមានការកើនឡើង ហើយកត្តាចម្បងនៃបញ្ហានេះជាប់ពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធនៅក្នុងប្រទេសរបស់ពួកគេ។ របាយការណ៍ UNODC បានគូសបញ្ជាក់ថា ខណៈដែលករណីជនរងគ្រោះ ដែលភាគច្រើនជាស្ត្រី ត្រូវបានជួញដូរផ្លូវភេទនៅក្នុងបណ្តាប្រទេសជាច្រើនរបស់ពិភពលោក ការផ្តន្ទាទោស បែរជានៅក្នុងកម្រិតទាប ជាពិសេសនៅក្នុងតំបន់ប្រទេសមជ្ឈិមបូព៌ា និងអាហ្វ្រិក៕

## ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩

### អង្គការ លីកាដូ នឹងចុះស្រាវជ្រាវករណីក្មេងស្រីម្នាក់នៅខេត្តកណ្តាលដាច់ដៃម្នាងចូលក្នុងម៉ាស៊ីនកិនដីធ្វើឥដ្ឋ

https://www.rfa.org/khmer/ ដោយ សេក បណ្ឌិត 2019-03-11

មន្ត្រីសិទ្ធិមនុស្ស នៃអង្គការលីកាដូ (LICADHO) ថា ខ្លួននឹងចុះទៅស្រាវជ្រាវករណីក្មេងស្រីម្នាក់នៅខេត្តកណ្តាលដាច់ដៃម្ខាងចូលក្នុងម៉ាស៊ីនកិនដីធ្វើឥដ្ឋ។ ការលើកឡើងបែបនេះ គឺក្រោយពេលអង្គការលីកាដូ ទទួលព័ត៌មានថា ក្មេងស្រីអាយុ ៩ឆ្នាំម្នាក់បានរអិលធ្លាក់ចូលម៉ាស៊ីនកិនដី បណ្តាលឱ្យដាច់ដៃស្តាំម្ខាងត្រឹមក្លៀក។

លោក អំ សំអាត ប្រធានគ្រប់គ្រងការិយាល័យឃ្លាំមើលសិទ្ធិមនុស្ស លីកាដូ ប្រាប់ថា អង្គការរបស់លោកបានទទួលបានព័ត៌មាននៃករណីគ្រោះថ្នាក់ក្មេងស្រីម្នាក់ អាយុ ៩ឆ្នាំ ឈ្មោះ ឆេង ស្រីភ័ក្រ ដែលជាកូនស្រីកម្មករធ្វើការនៅសិប្បកម្មឡឥដ្ឋ បានរអិលធ្លាក់ចូលម៉ាស៊ីនកិនដីបណ្តាលឱ្យដាច់ដៃស្តាំម្ខាង ត្រឹមក្លៀក ក្នុងពេលបញ្ចូលដីទៅក្នុងម៉ាស៊ីនជាមួយឪពុកម្តាយ កាលពីព្រឹកថ្ងៃទី៩ ខែមីនា។ លោកបន្តថា លោកឲ្យដឹងទៀតថា នៅថ្ងៃទី១១ ខែមីនាស្អែកនេះ ក្រុមមន្ត្រីរបស់លោកនឹងចុះទៅស្រាវជ្រាវដល់ទីតាំងកើតហេតុ និងមន្ទីរពេទ្យ ដែលព្យាបាលក្មេងស្រីនោះ៖ «»
លោក អំ សំអាត អង្គការ លីកាដូ ទទួលព័ត៌មានថា ហេតុការណ៍នេះកើតឡើងនៅក្នុងសិប្បកម្មផលិតឥដ្ឋមួយកន្លែងឋិតនៅភូមិព្រះប្រសប់ ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ លោកបន្តថា ក្រោយកើតហេតុកម្មករឡឥដ្ឋនៅក្បែរនោះបាននាំកុមាររងគ្រោះបញ្ជូនទៅមន្ទីរពេទ្យបង្អែកស្រុក ប៉ុន្តែដោយស្ថានភាពរបួសធ្ងន់ធ្ងរត្រូវបញ្ជូនទៅសង្គ្រោះបន្តនៅពេទ្យរាជធានីភ្នំពេញ។

អាស៊ីសេរីបានព្យាយាមទូរស័ព្ទជាច្រើនដងទៅអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ ដើម្បីសុំការបញ្ជាក់បន្ថែមពីករណីនេះ ប៉ុន្តែទូរស័ព្ទចូលគ្មានអ្នកទទួលនៅថ្ងៃទី១០ ខែមីនា។

ព័ត៌មានដែលផ្សព្វផ្សាយដោយបណ្តាញសង្គមហ្វេសប៊ុកបញ្ជាក់ថា ប្រធានមន្ទីរការងារខេត្តកណ្តាល លោក ធុល នាង បានដឹងពីករណីនេះ ហើយថែមទាំងបានចាត់មន្ត្រីឲ្យចុះទៅស្រាវជ្រាវបន្ថែម។

លោក អំ សំអាត ប្រធានគ្រប់គ្រងការិយាល័យឃ្លាំមើលសិទ្ធិមនុស្ស លីកាដូ ឲ្យដឹងថាកន្លងមក ក៏ធ្លាប់កើតមានករណីកុមារធ្វើការងារនៅសិប្បកម្មឡឥដ្ឋជួបគ្រោះថ្នាក់បែបនេះដែរ។ លោកបន្តថា មូលហេតុដែលបណ្តាលឲ្យកើតបញ្ហានេះ ព្រោះនៅក្នុងសិប្បកម្មឡឥដ្ឋជាកន្លែងគ្រោះថ្នាក់គ្មានប្រព័ន្ធការពារសុវត្ថិភាពត្រឹមត្រូវ៖ «» តាមច្បាប់ការងារមិនអនុញ្ញាតឱ្យកុមារអាយុក្រោម ១៨ឆ្នាំបម្រើការងារនៅតាមរោងចក្រ សហគ្រាសឬសិប្បកម្មឡឥដ្ឋទេ។ របាយការណ៍របស់អង្គការសិទ្ធិមនុស្ស លីកាដូ (LICADHO) កាលពីចុងឆ្នាំ២០១៦ ដែលនិយាយពីការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារនៅក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជាបានលើកឡើងថា ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារជាប្រភេទការងារខុសច្បាប់ ដោយយោងតាមច្បាប់របស់កម្ពុជា និងសន្ធិសញ្ញាអន្តរជាតិ។ របាយការណ៍ដដែលលើកឡើងទៀតថា ការបញ្ចាំខ្លួនដោះបំណុលជាការអនុវត្តស្រដៀងគ្នាទៅនឹងទាស ភាព៕

## ជប៉ុនគ្រោងទទួលពលករជំនាញកម្ពុជា តែសកម្មជនបារម្ភពីការកេងប្រវ័ញ្ច

https://khmer.voanews.com/ 08 មិនា 2019 ម៉ែន គីមសេង

បច្ចុប្បន្នមានពលករកម្ពុជាធ្វើការនៅប្រទេសជប៉ុនចំនួនជាង៩០០០នាក់ ក្រោមកម្មវិធីធ្វើកម្មសិក្សា។ ពួកគេទទួលបានប្រាក់ខែជាមធ្យម១៥០០ដុល្លារ។ ប៉ុន្តែក្រុមអ្នកជំនាញមើលឃើញថា ដោយសារមានការបើកទូលាយជាងមុនក្នុងពេលខាងមុខគឺចំនួនពលករជំនាញគ្រោងនឹងកើនឡើងខ្លាំង។

វ៉ាស៊ីនតោន៖ ប្រទេសកម្ពុជានិងជប៉ុនគ្រោងនឹងចុះហត្ថលេខាលើអនុស្សារណៈស្តីពីការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការនៅទីក្រុងតូក្យូ ប្រទេសជប៉ុន នៅចុងខែមីនានេះ ដើម្បីបង្កើនទីផ្សារការងារ និងឱកាសដល់ពលករកម្ពុជា។ ក្រសួងការងារកម្ពុជាបានបញ្ជាក់ដូចនេះ កាលពីខែកុម្ភៈ ក្រោយពីប្រទេសជប៉ុនបានធ្វើវិសោធនកម្មច្បាប់អន្តោប្រវេសន៍ដែលនឹងចូលជាធរមាននៅខែមេសាខាងមុខ ដោយបើកឱកាសឱ្យក្រុមហ៊ុនជប៉ុនជួលកម្មករជំនាញដោយផ្ទាល់ពីប្រទេសនានាដើម្បីបំពេញកង្វះខាតកម្លាំងពលកម្មក្នុងស្រុក ដោយសារតែពលរដ្ឋជប៉ុនមានវ័យចំណាស់កាន់តែច្រើន។ ការណ៍នេះដោយសារតែរដ្ឋាភិបាលជប៉ុនទទួលស្គាល់ថា មានការយកថ្លៃខ្ពស់ពីភ្នាក់ងារជ្រើសរើសពលករដែលនាំឱ្យពួកគេជំពាក់បំណុលច្រើន និងចាកចោលពីការងារមុនពេលបញ្ចប់កិច្ចសន្យា។ ប៉ុន្តែសកម្មជនសិទ្ធិពលករសម្តែងការព្រួយបារម្ភថា ការផ្លាស់ប្តូរថ្មីនេះក៏នៅតែមិនអាចដោះស្រាយបញ្ហាកេងប្រវ័ញ្ចលើកម្លាំងពលកម្មរបស់ពលករជំនាញឡើយ ប្រសិនបើមិនបានកំណត់ច្បាស់លាស់លើនីតិវិធីនៃការជ្រើសរើសបុគ្គលិក និងការកំណត់លក្ខខណ្ឌនៃការងារទេ។

លោកស្រីរីកូ ហារីម៉ា អ្នកសម្របសម្រួលថ្នាក់តំបន់នៃបណ្តាញជនចំណាកស្រុកទន្លេមេគង្គ (Mekong Migrant Network) បានបញ្ជាក់ថា៖ «ជាគោលការណ៍ នេះគឺជាជំហានវិជ្ជមានរបស់រដ្ឋាភិបាលជប៉ុន ប៉ុន្តែនៅពេលបច្ចុប្បន្ននេះការពិតនៅមិនទាន់ច្បាស់នៅឡើយទេ ថាតើពួកគេមើលឃើញថាការជួលដោយផ្ទាល់នឹងត្រូវអនុវត្តយ៉ាងណា ហើយក៏មិនច្បាស់លាស់ថាតើពលករត្រូវសុំទិដ្ឋាការប្រភេទណាដែរ។ តើពួកគេត្រូវអនុវត្តតាមនីតិវិធីអ្វី។ ព័ត៌មានទាំងអស់នេះនៅមិនទាន់ច្បាស់លាស់នៅឡើយទេ»។ លោកស្រីរីកូ ហារីម៉ា ព្រួយបារម្ភពីការកេងប្រវ័ញ្ចកម្លាំងពលកម្មលើពលករចំណាកស្រុកដោយក្រុមហ៊ុនជ្រើសរើសពលករដែលមិនសុច្ចរិត។ លោកស្រីបន្ថែមថា៖ «ដោយសារតែមិនមានព័ត៌មានច្បាស់លាស់សម្រាប់ពលករ យើងឃើញថា មានចន្លោះប្រហោងដ៏ធំសម្រាប់ក្រុមហ៊ុនជ្រើសរើសពលករដែលចង់កេងចំណេញពីកង្វះព័ត៌មាននេះ»។

កម្ពុជាគឺជាប្រទេសគោលដៅមួយក្នុងចំណោមប្រទេសអាស៊ីចំនួន៨ ដូចជាចិន វៀតណាម ហ្វីលីពីន និងថៃជាដើម ដែលរំពឹងថា នឹងទទួលផលប្រយោជន៍ពីច្បាប់ថ្មីនេះព្រោះអាចបញ្ជូនពលករជំនាញទៅធ្វើការដោយស្របច្បាប់ទន្ទឹមគ្នានឹងការបន្តកម្មវិធីកម្មសិក្សាដែលមាននាពេលបច្ចុប្បន្ន។

លោកស្រីជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ បានប្រាប់ដល់អង្គប្រជុំមួយកាលពីខែកុម្ភៈថា រាជរដ្ឋាភិបាលកម្ពុជាបានសម្តែងក្តីព្រួយបារម្ភថា ដំណើរការជួលពលករដោយផ្ទាល់នេះក៏ទំនងជានឹងមិនរារាំងក្រុមហ៊ុនជ្រើសរើសពលករដែលមិនសុច្ចរិតមិនឱ្យគេបន្លំពលករបានឡើយ។ លោកស្រីជូ ប៊ុនអេង បានស្នើឱ្យមានច្បាប់កំណត់ច្បាស់លាស់ស្តីពីនីតិវិធីជួលបុគ្គលិកដោយផ្ទាល់ និងការបកស្រាយពីតួនាទីនៃទីភ្នាក់ងារជ្រើសរើសបុគ្គលិកទាំងនោះ។

បច្ចុប្បន្នមានពលករកម្ពុជាធ្វើការនៅប្រទេសជប៉ុនចំនួនជាង៩០០០នាក់ ក្រោមកម្មវិធីធ្វើកម្មសិក្សា។ ពួកគេទទួលបានប្រាក់ខែជាមធ្យម១៥០០ដុល្លារ។ ប៉ុន្តែក្រុមអ្នកជំនាញមើលឃើញថា ដោយសារមានការបើកទូលាយជាងមុនក្នុងពេលខាងមុខគឺចំនួនពលករជំនាញគ្រោងនឹងកើនឡើងខ្លាំង។

របាយការណ៍ស្រាវជ្រាវកាលពីឆ្នាំ២០១៦ របស់រដ្ឋាភិបាលជប៉ុន រកឃើញថា ជាង៧០ភាគរយនៃក្រុមហ៊ុនដែលជួលកម្មសិក្សាការីមកពីប្រទេសនានាបានប្រព្រឹត្តសកម្មភាពរំលោភសិទ្ធិមនុស្ស។ កម្មសិក្សាការីខ្លះត្រូវបង្ខំឱ្យធ្វើការជាច្រើនម៉ោង ហើយផ្តល់ប្រាក់កម្រៃតិចជាងកម្រិតអប្បបរិមាដែលច្បាប់តម្រូវ។ អ្នកខ្លះត្រូវបង្ខំឱ្យធ្វើការលើសម៉ោង។ កន្លែងធ្វើការមិនត្រូវតាមនិយាមសុវត្ថិភាព។ ការណ៍នេះជំរុញឱ្យពលកររត់ចេញពីកន្លែងធ្វើការមុនបញ្ចប់កិច្ចសន្យាដែលនាំឱ្យមានការសេងសឹកពីថៅកែ។

លោកស្រីរីកូ ហារីម៉ា ថាមិនមានសញ្ញាណាបញ្ជាក់ថា ការប្តូរឋានៈថ្មីនេះនឹងកែលម្អនិងកាត់បន្ថយការរំលោភសិទ្ធិពលករយ៉ាងណាទេ ប៉ុន្តែអ្វីដែលលោកស្រីសង្ឃឹមនោះគឺច្បាប់ថ្មីនេះនឹងអនុញ្ញាតឱ្យពលករផ្លាស់ប្តូរការងារនៅក្នុងវិស័យដូចគ្នាបាន។ លោកស្រីរីកូ ហារីម៉ា បន្ថែមទៀតថា៖ «យើងមើលមិនឃើញថា ការផ្តល់ទិដ្ឋាការប្រភេទថ្មីនេះអាចដោះស្រាយបញ្ហាការរំលោភសិទ្ធិពលករដោយក្រុមថៅកែដោយរបៀបណាទេ»។

សកម្មជនថា ការដកយកក្រុមហ៊ុនជ្រើសរើសពលករចេញក៏មិនមែនជាជម្រើសល្អដែរ ដោយសារតែមិនមានព័ត៌មានជាក់លាក់។ ពួកគេស្នើឡើងថា មធ្យោបាយដ៏ល្អគឺការកំហិតចំនួនប្រាក់កម្រៃជើងសារឱ្យបានត្រឹមត្រូវសម្រាប់ក្រុមហ៊ុនអាចយកថ្លៃបាន។ បច្ចុប្បន្ន តម្លៃសម្រាប់ជ្រើសរើសពលករម្នាក់មានចំនួនរហូតដល់៦០០០ដុល្លារដែលជាតម្លៃខ្ពស់។ ក្រុមសកម្មជនសង្ឃឹមថា ក្នុងកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាងជប៉ុននិងកម្ពុជានឹងលើកយកបញ្ហានេះមកបញ្ជាក់ឱ្យបានច្បាស់ជាងពេលបច្ចុប្បន្ន។

លោក ហៃ វណ្ណា ពលរដ្ឋខ្មែរដែលរស់នៅក្នុងប្រទេសជប៉ុនយល់ថា ការផ្តល់ឋានៈឱ្យពលករខ្មែរបានធ្វើជាកម្មករជំនាញ គឺមានលក្ខណៈប្រសើរសម្រាប់ពួកគេទាំងលើផ្នែកជំនាញនិងចំណូល។ ប៉ុន្តែ លោកព្រួយបារម្ភពីការបន្តបាត់បង់ពលរដ្ឋខ្មែរ ដែលបន្តធ្វើចំណាកស្រុកកាន់តែច្រើន។ «អ្វីដែលកត់សម្គាល់គឺថា យុវជននឹងមានការខ្វះខាតច្រើននៅក្នុងប្រទេស។ គាត់មកធ្វើឱ្យសេដ្ឋកិច្ចជប៉ុនកាន់តែប្រសើរឡើង ប៉ុន្តែសេដ្ឋកិច្ចស្រុកខ្មែរយើងវាកើនឡើងខ្លះដែរតាមរយៈការផ្ញើថវិកាទៅដោយប្រយោលគឺមិនដោយផ្ទាល់។ ខ្ញុំមើលឃើញថា វាល្អពាក់កណ្តាលនិងមិនល្អពាក់កណ្តាល»។ លោកហៃ វណ្ណា ក៏មានការព្រួយបារម្ភស្រដៀងគ្នានឹងក្រុមសកម្មជនដែរលើការមិនកំណត់ប្រាក់កម្រៃជើងសារឱ្យបានច្បាស់លាស់ ដែលជាឱកាសសម្រាប់ក្រុមហ៊ុនជ្រើសរើសពលករកេងប្រវ័ញ្ចលើពលករខ្មែរ។ «ខ្ញុំបារម្ភជាងគេ គឺក្រុមហ៊ុននៅក្នុងប្រទេសកម្ពុជាយើងផ្ទាល់ ដែលគាត់តែងតែធ្វើអ្វីទៅតាមទំនើងចិត្ត មិនមានការមើលការខុសត្រូវឱ្យបានដិតដល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ចំពោះក្រុមហ៊ុននៅជប៉ុន បើច្បាប់គេចែងយ៉ាងម៉េច គឺគេត្រូវអនុវត្តអីចឹងហើយ ប៉ុន្តែនៅមានក្រុមហ៊ុនមួយចំនួន គាត់ធ្វើការនៅជិតបន្ទាត់ក្រហម ប៉ុន្តែគាត់នៅតែអាចស្ថិតនៅក្រោមច្បាប់ជប៉ុន។ ប៉ុន្តែនៅស្រុកខ្មែរពិបាក។ អីចឹងខ្ញុំបារម្ភត្រង់ចំណុចហ្នឹង»។ លោកវណ្ណា ថាផលវិបាកដែលក្រុមហ៊ុនជ្រើសរើសពលករយកកម្រៃច្រើន គឺកម្មសិក្សាការីមិនមានសល់ប្រាក់កម្រៃអ្វីទេ នៅពេលបំពេញការងារនៅជប៉ុនក្នុងរយៈពេលបីឆ្នាំ ហើយប្រឈមនឹងការងារលំបាកជាច្រើន។

លោកអ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារបានបញ្ជាក់ថា កម្ពុជាត្រៀមខ្លួនជាស្រេចក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមើលឃើញថា វាជា«ឱកាសដ៏ល្អមួយដែលប្រទេស

ទាំងពីរនឹងទទួលបាននូវផលប្រយោជន៍ទៅវិញទៅមក ជាពិសេសការផ្តល់ប្រាក់ខែខ្ពស់ ចំណេះដឹងនិងវិជ្ជាជីវៈដល់ពលករកម្ពុជា។ មានពលករខ្មែរជិត២លាននាក់បានធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសដែលភាគច្រើនគឺប្រទេសថៃ។ ពួកគេបានផ្ញើប្រាក់មកក្រុមគ្រួសារវិញចំនួនជាង៤០០លានដុល្លារក្នុងឆ្នាំ២០១៨។ នេះបើតាមតួលេខរបស់ធនាគារពិភពលោក។ប៉ុន្តែតួលេខរបស់រដ្ឋាភិបាលកម្ពុជាថាចំនួនប្រាក់បញ្ញើមានរហូតដល់២.៣០០លានដុល្លា៕

## បិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៨ របស់ស្នងការខេត្តក្រចេះ, ឧត្តមសេនីយ៍ឯក អ៊ិន បូរ៉ា ជំរុញឲ្យនគរបាលបន្តបំពេញកិច្ចការងារសន្តិសុខ និងសណ្តាប់ធ្នាប់ជូនប្រជាជន

http://www.freshnewsasia.com/ **2019-03-11**

**(ក្រចេះ)៖** លោកឧត្តមសេនីយ៍ឯក អ៊ិន បូរ៉ា អគ្គស្នងការរងនគបាលជាតិ បានជំរុញឲ្យនគរបាលបន្តការខិតខំបំពេញកាតព្វកិច្ចការងារ តាមមុខជំនាញតួនាទីភារកិច្ចរបស់ខ្លួនឱ្យកាន់តែប្រសើរជាងមុន បើទោះបីជាអត្រាបទល្មើសផ្សេងៗនៅខេត្តក្រចេះ មានតួរលេខថយចុះ យ៉ាងណាក៏ដោយ។ ការថ្លែងបែបនេះរបស់ លោកឧត្តមសេនីយ៍ឯក អ៊ិន បូរ៉ា បានធ្វើឡើងនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩នេះ នៅក្នុងឱកាសដែលលោកឧត្តមសេនីយ៍ បានអញ្ជើញជាតំណាង នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការងនគរបាលជាតិ នៅក្នុងពិធីបិទសន្និបាតបូកសរុបសភាព ការណ៍លទ្ធផល កិច្ចប្រតិបត្តការប្រចាំឆ្នាំ២០១៨ របស់ស្នងការដ្ឋាននគរបាលខេត្តក្រចេះ ពិធីបំពាក់ឋាននន្តរសក្តិដល់នាយ នាយរងនគរបាលខេត្ត និងពិធីផ្លាស់ប្តូរមុខតំណែងការងារផងដែរ។

ជាមួយគ្នានេះដែរ លោកឧត្តមសេនីយ៍ទោ លន់ សុផាត ស្នងការនគរបាលខេត្តក្រចេះ បានឱ្យដឹងថា សភាពការការទូទៅនៅខេត្តក្រចេះ ក្នុងឆ្នាំ២០១៨ រួមមាន៖ បទល្មើសព្រហ្មទណ្ឌ បទល្មើសគ្រឿងញៀន បទល្មើសជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទក៏ដូចជា អត្រាគ្រោះថ្នាក់ចរាចរណ៍គឺពុំមានអត្រាកើនឡើងគួឱ្យកត់សម្គាល់នោះទេ។

លោក វ៉ា ថន អភិបាលខេត្តក្រចេះ បានថ្លែងដោយសម្តែងការកោតសសើរ លើកកិច្ចការងាររបស់កងកម្លាំងនគរបាលខេត្តក្រោមការដឹកនាំ ពីលោកឧត្តមសេនីយ៍ទោ លន់ សុផាត ដែលខិតខំប្រឹងប្រែក ក្នុងកាតព្វកិច្ចតួនាទីរក្សាបាននូវសុខសណ្តាប់ធ្នាប់ជូន ដល់ពលរដ្ឋនៅទូទាំងខេត្តរហូតទទួលបានលទ្ធផលយ៉ាងល្អប្រសើរ។ លោកអភិបាលខេត្ត បានជំរុញឱ្យនាយ នាយរងនគរបាលទាំងអស់បន្តការខឹតខំអនុវត្ត ភារកិច្ចឱ្យខ្លាំងក្លាជាងមុនបន្ថែមទៀតប្រយោជន៍រក្សាបាន នូវសុខសណ្តាប់ធ្នាប់តាមគ្រប់មូលដ្ឋានធ្វើយ៉ាងណាឱ្យពលរដ្ឋមានទំនុកចិត្តមកលើកងកម្លាំងនគរបាលជាតិ៕

## ក្រសួងការងារប្តឹងព្រហ្មទណ្ឌលើម្ចាស់សិប្បកម្មឡឥដ្ឋ ករណីកុមារីជួបគ្រោះថ្នាក់ដាច់ដៃ

https://thmeythmey.com/ 12, Mar 2019 , 10:31 am ដោយ: ញ៉ង ហេង

ភ្នំពេញ៖ ក្រសួងការងារកំពុងកសាងសំណុំរឿងបណ្តឹងព្រហ្មទណ្ឌលើម្ចាស់សិប្បកម្មផលិតឥដ្ឋ នៅខេត្តកណ្តាល ចំពោះករណីកុមារីម្នាក់ជួបគ្រោះថ្នាក់ដាច់ដៃ។ នេះបើតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងនៅថ្ងៃទី១១ ខែមីនានេះ។ កាលពីថ្ងៃទី៩ខែមីនា កុមារីអាយុ១០ឆ្នាំម្នាក់ ដែលជាកូនរបស់កម្មករឡឥដ្ឋ បានជួបគ្រោះថ្នាក់នៅសិប្បកម្មផលិតឥដ្ឋរបស់ម្ចាស់ឈ្មោះ លាង ស្រ៊ុន ក្នុងឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលកុមារីរូបនោះបានដាច់ដៃចូលក្នុងម៉ាស៊ីនផលិតឥដ្ឋ។

ក្រោយការចុះអង្កេត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសម្រេចពិន័យសិប្បកម្មផលិតឥដ្ឋមួយនេះស្របតាមមាត្រា ៣៦៨នៃច្បាប់ការងារ និងកសាងសំណុំរឿងព្រហ្មទណ្ឌលើម្ចាស់សិប្បកម្មនេះ អំពីករណីប្រើប្រាស់ពលកម្មកុមារ និងខ្វះវិធានការការពារសុវត្ថិភាពកុមារ មិនឲ្យចូលកៀកទៅកន្លែងខ្សែសង្វាក់ផលិតកម្ម។ ក្រសួងបញ្ជាក់ថា កុមារីរងគ្រោះទទួលបានការគាំទ្រពីរបបសន្តិសុខសង្គម ដូចជាការព្យាបាលរបួស សេវាស្តារនីតិសម្បទាឡើងវិញ ប្រាក់ឧបត្ថម្ភសម្រាប់ការបាត់បង់សមត្ថភាពអចិន្ត្រៃយ៍មួយជីវិត និងប្រាក់ឧបត្ថម្ភអំឡុងពេលព្យាបាលរបួស។

ក្រសួងក្រើនរំលឹកដល់ម្ចាស់សិប្បកម្មផលិតឥដ្ឋ សហគ្រាស គ្រឹះស្ថានទាំងអស់យ៉ាងដូច្នេះថា៖ «ការប្រើប្រាស់កម្លាំងពលកម្មកុមារ គឺត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមប្រកាសលេខ៣០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌការងារ និងជីវភាពរស់នៅក្នុងសហគ្រាសឡឥដ្ឋ។ ការប្រើប្រាស់កុមារអាយុក្រោម១២ឆ្នាំ គឺជាបទល្មើសព្រហ្មទណ្ឌ។ ទន្ទឹមនឹងនេះ ការប្រើប្រាស់ពលកម្មកុមារអាយុក្រោម១៨ឆ្នាំនៅតាមមណ្ឌលហប់ ទីខ្ពស់ និងកន្លែងដែលមានប្រើប្រាស់សាធាតុគីមីត្រូវហាមឃាត់។ ក្រសួងនឹងចាត់វិធានការតឹងរ៉ឹងទាំងផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌចំពោះសិប្បកម្មឡឥដ្ឋ សហគ្រាស គ្រឹះស្ថានដែលល្មើសនឹងករណីខាងលើ»៕

## លោក ឡុង ឌីម៉ង់៖ មួយឆ្នាំៗពលករខ្មែរនៅកូរ៉េ នាំចំណូលប្រមាណ៦០០លានដុល្លារ ចូលមកស្រុកកំណើត

http://www.freshnewsasia.com/i 2019-03-12

**(ភ្នំពេញ)៖** នៅក្នុងបទសម្ភាសន៍ជាមួយអង្គភាពព័ត៌មាន Fresh News នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩នេះ លោក ឡុង ឌីម៉ង់ ឯកអគ្គរាជទូតខ្មែរវិសាមញ្ញ និងពេញសមត្ថភាពប្រចាំកូរ៉េខាងត្បូង បានលើកឡើងថា ពលករខ្មែរ ដែលបម្រើការងារនៅសាធារណរដ្ឋកូរ៉េ ខាងត្បូងប្រមាណ៥ម៉ឺននាក់ បានផ្ញើថវិកាខ្ទង់៦០០លានដុល្លារអាមេរិក មកស្រុកកំណើត នៅក្នុងមួយឆ្នាំៗ ទាំងនេះ គឺជាផ្នែកមួយចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។ លោក ឡុង ឌីម៉ង់ បានថ្លែងថា ជាមួយការភ្ជាប់ទំនាក់ទំនងការទូត ប្រទេសទាំងពីរ បានផ្តល់ផលប្រយោជន៍ជាច្រើន ជាពិសេសលើវិស័យសេដ្ឋកិច្ច វិស័យការងារ ហើយភាពជាក់ស្តែង ប្រជាពលរដ្ឋខ្មែរ និងបងប្អូនពលករបច្ចុប្បន្នមានជាង៦ម៉ឺននាក់នៅកូរ៉េ ក្នុងនោះកម្ពុជាបាននាំពលករ ដែលមិនជំនាញឲ្យទៅបម្រើការងារនៅកូរ៉េ ដោយទទួលបាននូវវគ្គបំប៉នផ្សេងៗ ពីអ្នកជំនាញកូរ៉េ ទើបធ្វើឱ្យពលខ្មែរ ដែលបញ្ជូនទៅនោះទទួលបានចំណេះដឹងលើវិស័យជាច្រើនពីកូរ៉េខាងត្បូង ហើយពលករទាំងនោះ ទទួលបានប្រាក់ខែខ្ពស់ ដើម្បីសន្សំផ្ញើមកប្រទេសកម្ពុជា។

ឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េរូបនេះ បានថ្លែងយ៉ាងដូច្នេះ៖ **«យើងបានខិតខំចរចាជាមួយភាគីប្រទេសជាមិត្ត ជាពិសេសជាមួយសាធារណរដ្ឋកូរ៉េនេះ ក្នុងការបើកទីផ្សារការងារ ជូនបងប្អូនខ្មែរ ឲ្យមកទទួលនូវជំនាញវិជ្ជាជីវៈផង មានការងារធ្វើផង និងមានប្រាក់ខែខ្ពស់ផ្ញើមកក្រុមគ្រួសារ ហើយបងប្អូនខ្មែរ ដែលទៅធ្វើការនៅប្រទេសកូរ៉េ គ្រាន់តែផ្ញើប្រាក់ទៅប្រទេសកម្ពុជា មិនក្រោម៦០០លានដុល្លារ ដូច្នេះជាចំនួនថវិកាមួយដ៏ធំ»**។ រាជរដ្ឋាភិបាលកម្ពុជា ដែលដឹកនាំដោយសម្តេចតេជោ ហ៊ុន សែន បានខិតខំរៀបចំខ្សែបន្ទាត់នយោបាយ និងទស្សនៈវែងឆ្ងាយលើវិស័យការងារនានា នៅក្នុងប្រទេសកម្ពុជា និងខិតខំធ្វើកិច្ចសហ ប្រតិបត្តិការ ជាមួយបណ្តាប្រទេសជាមិត្ត ដើម្បីបង្កភាពងាយស្រួលបង្កើនការចាប់អារម្មណ៍លើការដាក់វិនិយោគបរទេសនៅកម្ពុជា និងបញ្ជូនពលករគ្មានជំនាញធ្វើការនៅបរទេស ដើម្បីនាំជំនាញមកប្រទេស ព្រមទាំងថវិកាជាច្រើនត្រឡប់កម្ពុជាវិញផងដែរ។ នេះជាការបញ្ជាក់បន្ថែមពីលោក ឌីម៉ង់។

លោកបានថ្លែងបន្ថែមទៀតថា សហគមន៍ខ្មែរនៅប្រទេសកូរ៉េ មានចំនួនជាង៦ម៉ឺននាក់ ក្នុងនោះបងប្អូនប្រជាពលករមានជាង៥,០០០០ម៉ឺននាក់ ស្ត្រីខ្មែរដែលរៀបការជាមួយជនជាតិកូរ៉េ មានចំនួនជាង៧ពាន់នាក់ និងមាននិស្សិតខ្មែរជាង៤០០នាក់ ដែលកំពុងរៀននៅប្រទេសកូរ៉េ។ លោក ឡុង ឌីម៉ង់ បានបញ្ជាក់ថា នៅក្នុងចំណោមជាតិសាសន៍ចំនួន១៦ ដែលបម្រើការងារនៅប្រទេសកូរ៉េខាងត្បូង ពលករដែលជាជនជាតិខ្មែរយើង ទទួលបានកេរ្តិ៍ឈ្មោះបោះសំលេង ជាងជនជាតិដទៃទៀត គឺថៅកែជនជាតិកូរ៉េ តែងតែកោតសសើរមិនដាច់ពីមាត់ថា ពួកគេមានភាពអត់ធ្មត់នឹងការងារ មានភាពស្មោះត្រង់ បេះគោរពស្រឡាញ់អ្នកបម្រើការងារជាមួយគ្នា និងសហការល្អជាមួយគ្នាសម្រាប់កិច្ចការងារជាក្រុមផងដែរ៕

## ជនជាតិខ្មែរជាង៣ម៉ឺននាក់បញ្ជូនមកវិញ ពីប្រទេស១៨

https://kohsantepheapdaily.com.kh/ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៩ ម៉ោង ០៩:១៨ រ័ត្ន ធីយ៉ា

របាយការណ៍គួរទុកចិត្តបានរបស់នាយកដ្ឋានអន្តោប្រវេសន៍បានអោយដឹងថា ជនជាតិខ្មែរចំនួន ៣១.០០០នាក់ ត្រូវបានត្រឡប់មកកម្ពុជាវិញ កាលពីឆ្នាំ២០១៨ ។ របាយការណ៍នោះបានអោយដឹងទៀតថា ពួកគេភាគច្រើនគឺបញ្ជូនមកពីប្រទេសថៃ ដែលមានចំនួន៣ម៉ឺននាក់ ។ បន្ទាប់មកទៀតនោះ គឺបញ្ជូនមកពីកូរ៉េខាងត្បូងចំនួន២៧០នាក់ ពីម៉ាឡេស៊ីចំនួន១៧២នាក់ ពីចិន ១៥៦នាក់ ពីជប៉ុនចំនួន៩២នាក់ និងពីវៀតណាមចំនួន៨៤នាក់ ។ ប្រជាពលរដ្ឋខ្មែរទាំងនោះបញ្ជូនមកកាន់ប្រទេសកម្ពុជាវិញ ដោយសារតែពួកគេធ្វើការងារឬស្នាក់នៅខុសច្បាប់នៅក្នុងប្រទេសទាំងនោះ។ របាយការណ៍ដដែលនោះក៏បានអោយដឹងថា ពលករកម្ពុជាបានចេញទៅធ្វើការក្រៅប្រទេសដោយស្របច្បាប់តាមរយៈក្រុមហ៊ុនចំនួន៤២ និងមានចំនួនជាង១០ម៉ឺននាក់ ដោយទៅធ្វើការច្រើនជាងគេនៅប្រទេសថៃ ចំនួនរហូតដល់ជាង៩៩០០០នាក់ កូរ៉េខាងត្បូងចំនួនជាង៣៥០០នាក់ និងជប៉ុន១១២១នាក់ ។

## នារីមានស្រុកកំណើតនៅខេត្តស្ទឹងត្រែងម្នាក់ ចាញ់បោកមេខ្យល់ត្រូវគេយកទៅលក់នៅប្រទេសចិន បានស្រែកជន្ល៊ើយហៅអោយលោកK01 ជួយនាង ដើម្បីអោយបានត្រលប់មកប្រទេសកម្ពុជាវិញ

https://k01.news/article/ By K 01 March 11, 2019

ក្ដៅៗ! នារីម្នាក់ឈ្មោះ រ៉ានី បានចេញវីដេអូ ចេញពីទីក្រុងមួយនៃប្រទេសចិន ស្រែកអោយលោកK01 ជួយអន្តរាគមន៍ ដោយនាងបានចាញ់បោកមេខ្យល់អោយទៅធ្វើការនៅប្រទេសចិន ដោយប្រាប់ថាមានការងារធ្វើ និងមានប្រាក់ចំណូលអាចផ្គត់ផ្គង់គ្រួសារ បែជាចាញ់បោកគេ ត្រូវគេយកទៅបង្ខាំងទុកក្នុងផ្ទះមិនអោយចេញទៅណា ដោយការរៀបរាប់នោះ គឺនាងមានស្រុកកំណើតនៅឯខេត្តស្ទឹងត្រែង ហើយនាងចង់ត្រលប់មកប្រទេសកម្ពុជាវិញខ្លាំងណាស់។ ក្រោយបានឃើញវីដេអូ នេះលោកK01 ក៏បានសំណូមពរទៅដល់ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសចិត្តជួយដោះស្រាយរឿងនេះ ដើម្បីស្វែងរកយុត្តិធម៌ជូនប្អូនរងគ្រោះផងដែរ។

## ថៃបញ្ជូនពលករខ្មែរ ២០នាក់ មកឲ្យកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI 11-03-2019

បន្ទាយមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែតនាវេលាម៉ោង១៥,០០នាទី ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរ២០នាក់ ក្នុងនោះស្រី០៧នាក់ និងកុមារ០៥នាក់ ដែលអាជ្ញាធរថៃបញ្ជូនមក៕

# ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩

## ប្រសាសន៍សំខាន់ៗរបស់សម្តេចតេជោ ហ៊ុន សែន ក្នុងឱកាសអញ្ជើញសំណេះសំណាលជាមួយកម្មករ នៅខេត្តកោះកុងជាង ១ម៉ឺននាក់

http://www.freshnewsasia.com/ 2019-03-13

**(ភ្នំពេញ)៖** នៅព្រឹកថ្ងៃពុធ ៨កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩នេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា បានអញ្ជើញជួបសំណេះសំណាលជាមួយកម្មករនិយោជិតប្រមាណ១៣,៨៦៦នាក់ មកពីរោងចក្រ សហគ្រាសចំនួន៧ នៅក្នុងខេត្តកោះកុង។ ពិធីសំណេះសំណាល

នេះ នឹងប្រារព្ធធ្វើឡើងនៅតំបន់សេដ្ឋកិច្ចពិសេសកោះកុង ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង។

**ខាងក្រោមនេះជាប្រសាសន៍សំខាន់ៗរបស់សម្តេចតេជោ ហ៊ុន សែន៖**

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា សម្តេចរីករាយណាស់ដែលបានជួបសំណេះសំណាលជាមួយកម្មករ កម្មការិនីនៅក្នុងខេត្តកោះកុង។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងរោងចក្រនៅក្នុងខេត្តកោះកុង មានរោងចក្រខ្លះផលិតផលិតផលសកលដូចជាក្បាលរថយន្តជាដើម ដែលមិនមែនជាការបំពេញតម្រូវការក្នុងស្រុកនោះឡើយ។

* សម្តេចតេជោនាយករដ្ឋមន្ត្រី បន្ថែមថា រោងចក្រនៅក្នុងខេត្តកោះកុងនេះ ក៏មានរោងចក្រផលិតបាល់ ដែលជាតម្រូវការរបស់ពិភពលោកផងដែរ។

* សម្តេចតេជោ ហ៊ុន សែន បានចោទសួរថា តើមានមូលហេតុអ្វីខ្លះ ដែលនាំឲ្យខេត្តកោះកុងមានការអភិវឌ្ឍន៍ដូចពេលបច្ចុប្បន្ន? សម្តេចតេជោ បានលើកឡើងថា ខេត្តកោះកុងជាខេត្តមួយ ដែលមានប្រវត្តិអាណោចអាធមខ្លាំងណាស់ ដែលក្នុងនោះសូម្បីតែរដ្ឋមន្ត្រីក្រសួងការពារជាតិ សម្តេចពិជ័យសេនា ទៀ បាញ់ ក៏មានប្រវត្តិឈឺចាប់ផងដែរ ពោលជាឥស្សរជនខ្មែរមួយរូបដែលបានរួចផុតពីការដែលគេសម្លាប់។

* សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងថា សម្តេចបានយកខ្លួនមកពាំង និងដោះស្រាយការលំបាករបស់អ្នកកោះកុង។ សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា អ្នកខេត្តកោះកុងកម្សត់កម្រខ្លាំងណាស់ ទម្រាំបានដូចពេលបច្ចុប្បន្ននេះ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការវិវឌ្ឍន៍របស់កោះកុងមកដូចពេលបច្ចុប្បន្ននេះ គឺដោយសារនយោបាយឈ្នះ-ឈ្នះ ដែលជារឿងសំខាន់។

* សម្តេចតេជោប្រមុខរាជរដ្ឋាភិបាល បានលើកឡើងថា បើគ្មានសន្តិភាពទេ គ្មានអ្នកវិនិយោគណាមកវិនិយោគរកស៊ីនៅកម្ពុជានោះទេ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ចំណុចសំខាន់មួយទៀតដែលនាំឲ្យកោះកុងវិវឌ្ឍន៍មកស្ថានភាពដូចពេលបច្ចុប្បន្ននេះ គឺការអនុវត្តន៍ដោយជោគជ័យ នូវយុទ្ធសាស្ត្រពីរយ៉ាង។ ១. ការប្រែក្លាយតំបន់អតីតសមរភូមិទាំងអស់ឲ្យទៅជាតំបន់អភិវឌ្ឍន៍ និងទីផ្សារ និងទី២. ការប្រែក្លាយតំបន់ព្រំដែនរបស់កម្ពុជា ជាមួយប្រទេសជិតខាងឲ្យទៅជាតំបន់សន្តិភាព និងកិច្ចសហប្រតិបត្តិការ។

* សម្តេចតេជោប្រមុខរាជរដ្ឋាភិបាល បានថ្លែងថា សម្តេចប្រឹងប្រែងណាស់ក្នុងការធ្វើការងារជាមយយប្រទេសថៃ វៀតណាម និងឡាវ ដើម្បីកសាងសន្តិភាពតាមខ្សែព្រំដែន។ សម្តេចតេជោ បានលើកឡើងថា បើតំបន់ព្រំដែនគ្មានសន្តិភាព ស្ថេរភាពទេនោះ នឹងគ្មានការវិនិយោគមកតំបន់ព្រំដែននោះឡើយ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សម្តេចបានប្រឹងធ្វើការជាមួយនាយករដ្ឋមន្ត្រីថៃ ដើម្បីបង្កើតតំបន់សេដ្ឋកិច្ចពិសេសបន្ថែមទៀត ដូចជាតំបន់សេដ្ឋកិច្ចពិសេសអូរនៀង ក្នុងខេត្តបន្ទាយមានជ័យជាដើម។

* សម្តេចតេជោនាយករដ្ឋមន្ត្រី បានថ្លែងថា ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងថៃ បានកើនឡើងរហូតដល់ទៅប្រមាណ៧ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ដែលជាទំហំពាណិជ្ជកម្មមួយដ៏ធំ។

* សម្តេចតេជោ ក៏បានថ្លែងផងដែរថា បច្ចុប្បន្នតំបន់ព្រំដែនរវាងកម្ពុជា និងវៀតណាម ដែលធ្លាប់ជាកន្លែងដាក់កាំភ្លើងបាញ់គ្នានោះ ក៏កំពុងមានការអភិវឌ្ឍដោយបង្កើត ជាតំបន់សេដ្ឋកិច្ចពិសេសជាដើម។

* សម្តេចតេជោបានថ្លែងថា ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងឡាវក៏បាននិងកំពុងពង្រឹងនិងពង្រីកបន្តិចម្តងៗផងដែរ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា គោលនយោបាយតភ្ជាប់ ក៏ជាជោគជ័យសម្រាប់ការអភិវឌ្ឍនៅខេត្តកោះកុងផងដែរ។ ក្នុងនោះសម្តេចបានស្នើសុំដោយ ផ្ទាល់ទៅភាគីថៃឲ្យជួយសាងសង់ផ្លូវជាតិលេខ៤៨។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ពីអតីតកាលប្រទេសជិតខាងគេបិទដង្ហើមសេដ្ឋកិច្ចកម្ពុជាជារឿងមួយ ហើយក្នុងនោះក៏មានការចង់បិទដង្ហើមសេដ្ឋកិច្ចខ្លួនឯងថែមទៀត ដោយមិនឲ្យមានការរកស៊ីជាមួយថៃ។ សម្តេចតេជោបានបញ្ជាក់ថា សម្តេចមិនគាំទ្រឡើយចំពោះការរារាំងមិនឲ្យរកស៊ីជាមួយថៃ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ផ្លូវជាតិលេខ៤៨ នឹងក្លាយទៅជាផ្លូវហាយវេនាពេលអនាគត ក្រោមហិរញ្ញប្បទានរបស់កូរ៉េខាងត្បូង។

* សម្តេចតេជោ ហ៊ុន សែន ថ្លែងថា មហិច្ឆតារបស់សម្តេចមិនត្រឹមតែតភ្ជាប់ខេត្តកោះកុង ទៅ ព្រះសីហនុ នឹងទៅភ្នំពេញនោះ គឺនឹងសាងសង់ផ្លូវតភ្ជាប់កោះកុង ទៅតំបន់ថ្មដានៅខេត្តពោធិ៍សាត់ នឹងទៅខេត្តបាត់ដំបង និងប៉ៃលិនផងដែរ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា នៅជុំវិញបាងកក ប្រទេសថៃ និងបណ្តាប្រទេសនានា គ្មានផ្លូវណាមិនយកលុយនោះទេ។ ពេលគេយកលុយពីអ្នកជិះយកមក វិនិយោគសាងសង់ផ្លូវ។ តែសម្រាប់កម្ពុជា យកលុយតែក្នុងអន្តរកាលប៉ុណ្ណោះ ពេលមានលទ្ធភាពនឹងទិញយកផ្លូវនោះមកវិញ មិនឲ្យប្រជាពលរដ្ឋលំបាកក្នុងការបង់លុយថ្លៃផ្លូវនោះឡើយ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងបន្តថា ភាពជោគជ័យលើការតភ្ជាប់មួយទៀតរបស់រាជរដ្ឋាភិបាលក្រៅពីការតភ្ជាប់ផ្លូវហើយនោះ គឺការតភ្ជាប់បណ្តាញអគ្គិសនី ដែលពីមុនអគ្គិសនីនៅក្នុងខេត្តកោះកុងទិញមកពីប្រទេសថៃ។ តែបច្ចុប្បន្នខេត្តកោះកុង បានក្លាយជាធុងអាគុយមួយសម្រាប់ផ្គត់ផ្គង់ថាមពលអគ្គិសនីទៅរាជធានីភ្នំពេញ និងបណ្តាខេត្តផ្សេងទៀត។

* សម្តេចតេជោ បានថ្លែងថា កម្ពុជា និងថៃ បានឯកភាពថា ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកទៅធ្វើការខុសច្បាប់ក្នុងប្រទេសថៃ គឺត្រូវបង្កើតរោងចក្រនៅតាមបណ្តោយព្រំដែនក្នុងប្រទេសកម្ពុជា ដោយមិនចាំបាច់ឲ្យពលរដ្ឋកម្ពុជាចូលទៅធ្វើការនៅក្នុងប្រទេសថៃនោះទេ។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា រាជរដ្ឋាភិបាលបានសម្រេចឲ្យឧកញ៉ា លី យ៉ុងផាត់ សាងសង់កន្លែងផ្គត់ផ្គង់ទឹកសម្រាប់រយៈពេលវែងនៅក្នុងខេត្តកោះកុងនេះ។ សម្តេចតេជោ ក៏បានឲ្យដឹងផងដែរថា ដើម្បីដោះស្រាយបញ្ហាខ្វះទឹកនាពេលបច្ចុប្បន្ន កម្ពុជាបានទាក់ទងជាមួយខេត្តត្រាតរបស់ថៃ ជួយផ្គត់ផ្គង់ទឹកនៅក្នុងខេត្តកោះកុង។

* សម្តេចតេជោ ហ៊ុន សែន ប្រកាសថា ថ្ងៃស្អែកប្រធានាធិបតីកូរ៉េខាងត្បូង លោក មូន ចែអ៊ីន និងភរិយា នឹងអញ្ជើញបំពេញទស្សនកិច្ចនៅកម្ពុជា ហើយសម្តេចត្រូវមានការងារជាច្រើនត្រូវធ្វើក្នុងកំលុងបំពេញទស្សនកិច្ចនេះ។

* សម្តេចតេជោ ហ៊ុន សែន បានបង្ហើបថា សម្តេចកំពុងឲ្យក្រុមមេធាវីសិក្សាប្តឹងអ្នកប្រមាថសម្តេចនៅតាម Facebook ។ សម្តេចតេជោ បានថ្លែងថា សារប្រមាថរបស់សម្តេចនោះមានមិនតិចជាង ៣០នោះទេ។ សម្តេចតេជោថា សម្តេចនឹងប្តឹងទារសំណងជំងឺចិត្តមិនតិចជាង ២លានដុល្លារនោះទេ។ សម្តេចតេជោថា បើទោះបីអ្នកប្រមាថនោះនៅក្រៅស្រុក តែទ្រព្យសម្បត្តិគេនៅក្នុងស្រុកទាំងអស់។ សម្តេចនឹងរឹបអូសយកទ្រព្យសម្បត្តិនោះទៅលក់យកលុយជួយកុមារកំព្រា។

* សម្តេចតេជោ បានថ្លែងថា បញ្ហាទឹកនៅខេត្តព្រះសីហនុមិនចោទជាបញ្ហាទេ ព្រោះមានប្រភពទឹកពីក្បាលឆាយ។ ប៉ុន្តែអ្វីដែលចោទជាបញ្ហានោះ គឺទុយោចាស់ៗ។

* សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណដល់ភាគីថៃ ដែលបានជួយផ្គត់ផ្គង់ទឹកមកកាន់ប្រទេសកម្ពុជា។

* សម្តេចតេជោ ហ៊ុន សែន បានថ្លែងទៅកាន់កម្មករ កម្មការិនីថា ដរាបណានៅមានការងារធ្វើ ទទួលបានប្រាក់ឈ្នួល កុំខ្វាយខ្វល់នឹងការនិយាយបំផុសបំផុលផ្សេងៗ។ ការថ្លែងបែបនេះរបស់សម្តេចតេជោ គឺឆ្លើយតបទៅនឹងអតីតក្រុមសមាជិក និងថ្នាក់ដឹកនាំអតីតបក្សប្រឆាំង ដែលប្រឹងបំផុសបំផុលថា បញ្ហា EBA នឹងធ្វើឲ្យកម្មករ កម្មការិនីលែងមានការងារធ្វើ។

* សម្ដេចតេជោនាយករដ្ឋមន្ត្រី ក៏មិនភ្លេចផងដែរថា នូវការថ្លែងអំណរគុណដល់កម្មករ កម្មការិនី និងក្រុមគ្រួសាររបស់ពួកគេ ដែលបានចេញទៅបោះឆ្នោត និងបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជាកាលពីឆ្នាំ២០១៨កន្លងទៅនេះ។ សម្ដេចតេជោ បានថ្លែងថា ការចេញទៅបោះឆ្នោតនេះ ជាការវាយបំបាក់អំនួតរបស់ក្រុមដេកផ្ទះឈ្នះឯង និងជាការសម្រេចគាំទ្រនូវសុខសន្តិភាពនៅកម្ពុជា។

* សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា បើគ្មានសន្តិភាពគ្មានការវិនិយោគ និងគ្មានការងារធ្វើនោះទេ។ ក្នុងន័យនេះ សម្ដេចតេជោ បានអំពាវនាវដល់កម្មករ កម្មការិនី និងគណបក្សនយោបាយផ្សេងៗទៀត រួមគ្នាថែរក្សានូវសុខសន្តិភាពមួយនេះ។

* សម្ដេចតេជោ ហ៊ុន សែន បន្តអំពាវនាវដល់រោងចក្រ សហគ្រាសទាំងអស់យកចិត្តទុកដាក់ក្នុងរក្សាសុខុមាលភាពរបស់កម្មករ កម្មការិនី។ សម្ដេចតេជោ ហ៊ុន សែន បន្តអំពាវនាវកុំឲ្យមានបងតូចបងធំនៅតាមរោងចក្រ និងកុំឲ្យមានការជួញដូរ និងប្រើប្រាស់គ្រឿងញៀននៅតាមរោងចក្រ។

* សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា ក្នុងជំនួបជាមួយប្រតិភូវិនិយោគិនជប៉ុននៅថ្ងៃម្សិលមិញនេះ សម្ដេចបានស្នើឲ្យជប៉ុន ពង្រីកសាខារោងចក្ររបស់ខ្លួនមកកាន់ប្រទេសកម្ពុជា។

* សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា រាជរដ្ឋាភិបាលកំពុងប្រឹងប្រែងធ្វើឲ្យកម្មករ កម្មការិនីទទួលបានប្រាក់ឈ្នួលបានកាន់តែខ្ពស់ ហើយការចំណាយផ្សេងៗរបស់ពួកគេទាំងកន្លែងស្នាក់នៅ ថ្លៃអគ្គិសនី ថ្លៃអាហារ និងថ្លៃប្រើប្រាស់ផ្សេងៗទៀតចុះទាប ដើម្បីលើកកម្ពស់ជីវភាពរបស់កម្មករ កម្មការិនី។

* សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា រដ្ឋធម្មនុញ្ញកម្ពុជាបានកំណត់ថា បើអត់មាននាយករដ្ឋមន្ត្រី គណៈរដ្ឋក៏ត្រូវរលាយ ពោលសូម្បីតែនាយករដ្ឋមន្ត្រីស្ដីទីក៏មិនមានផងដែរ ព្រោះគ្មានអ្នកណាតែងតាំងនាយករដ្ឋមន្ត្រីស្ដីទីទេ។

* សម្ដេចតេជោ ហ៊ុន សែន បានថ្លែងថា រដ្ឋមន្ត្រីកុំបន់ឲ្យសម្ដេចស្លាប់ ដើម្បីបានតំណែងរបស់សម្ដេច តែការបន់ឲ្យសម្ដេចស្លាប់ ស្មើនឹងរលាយខ្លួនឯងដែរ ព្រោះត្រូវរលាយគណៈរដ្ឋមន្ត្រីទាំងមូល។

* សម្ដេចតេជោ ហ៊ុន សែន បានបញ្ចប់ការថ្លែងសុន្ទរកថានៅវេលាម៉ោង ៩៖២៧នាទីព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩, សូមអរគុណចំពោះការទស្សនាផ្សាយផ្ទាល់តាមរយៈទូរទស្សន៍ព័ត៌មាន Fresh News.៕

## ស្នងការៈ ករណីក្មេងដាច់ដៃនៅឡឥដ្ឋ មិនមែនការជួញដូរពលកម្មកុមារទេ

https://m.postkhmer.com/ 12 March 2019 | 12:00 ICT

**កណ្ដាលៈ** ខណៈមានក្មេងស្រីអាយុ ៩ ឆ្នាំម្នាក់ បានដាច់ដៃ ដោយសារម៉ាស៊ីនធ្វើឥដ្ឋ នៅក្នុងសិប្បកម្មធ្វើឥដ្ឋមួយនៅក្នុងស្រុកខ្សាច់កណ្ដាល ស្នងការខេត្តកណ្ដាល បានអះអាងថា នេះពុំមែនជាករណីជួញដូរពលកម្មកុមារ ឲ្យមកធ្វើការនៅក្នុងសិប្បកម្មឡឥដ្ឋនោះទេ។ កាលពីថ្ងៃទី ០៩ មីនា ម៉ាស៊ីនធ្វើឥដ្ឋ នៅក្នុងសិប្បកម្មផលិតឥដ្ឋមួយកន្លែងស្ថិតនៅក្នុងខេត្តកណ្ដាល បានធ្វើឱ្យកុមារីអាយុ ៩ ឆ្នាំម្នាក់ ឈ្មោះ ឆេង ស្រីភ័ក្រ បានរងគ្រោះថ្នាក់ដាច់ដៃខាងស្ដាំ ហើយក្រោយកើតហេតុ ត្រូវបានក្រុមគ្រួសារបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ។ កុមារីរងគ្រោះ ឆេង ស្រីភ័ក្របានចាកចេញពីស្រុកកំណើត នៅឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាមតាមឪពុកឈ្មោះ ឆេង ប៊ុនហំ និងម្ដាយឈ្មោះ ឃឹម ចាន់ណា បានមករស់នៅ និងធ្វើជាកម្មករស៊ីឈ្នួលនៅក្នុងសិប្បកម្មឡឥដ្ឋមួយកន្លែងដែលមានថៅកែឈ្មោះ លាង ស្រ៊ុន ស្ថិតក្នុងភូមិព្រះប្រសប់ ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល អស់រយៈពេល ៦ ឆ្នាំមកហើយ។ នេះបើតាមការលើកឡើងនៅក្នុងទំព័រហ្វេសប៊ុករបស់ស្នងការដ្ឋាននគរបាលខេត្តកណ្ដាលនៅថ្ងៃទី ១០ មីនា។

ស្នងការដ្ឋានខេត្តកណ្ដាលបន្តថា នៅថ្ងៃទី ០៩ មីនា ឪពុកឈ្មោះ ឆេង ប៊ុនហំ បានធ្វើការជាអ្នកចាក់ដីចូលម៉ាស៊ីន ហើយកុមារី ឆេង ស្រីភ័ក្រ និងម្ដាយរបស់នាង មានតួនាទីជាអ្នកចាំកាត់ឥដ្ឋចេញពីម៉ាស៊ីន និងរៀបចំដាក់លើរទេះ សម្រាប់ឱ្យឪពុកអូសយកទៅហាលថ្ងៃ សម្រាប់សម្ងួត។ នៅវេលាម៉ោង ៩ និង ៣០ នាទីព្រឹក នៅពេលលោក ប៊ុនហំ កំពុងលើកដុំឥដ្ឋចេញពីរទេះដាក់ហាល ក៏ស្រាប់តែឃើញកូនស្រីចូលដៃនៅក្នុងម៉ាស៊ីនហើយក៏បានរត់ស្ទុះស្ទាទៅបិទ

ម៉ាស៊ីនដើម្បីជួយសង្គ្រោះ ប៉ុន្តែកូនស្រីបានដាច់ដៃខាងស្តាំរួចទៅហើយ ហើយភ្លាមៗនោះ ក្រុមគ្រួសារក៏បានបញ្ជូននាងទៅសង្គ្រោះនៅមន្ទីរពេទ្យបង្អែកស្រុក តែត្រូវគេបញ្ជូនបន្តមកព្យាបាលនៅរាជធានីភ្នំពេញ។

លោក អ៊ាវ ចំរើន ស្នងការនគរបាលខេត្តកណ្តាល បានប្រាប់ភ្នំពេញប៉ុស្តិ៍ពីម្សិលមិញថា តាមការស៊ើបអង្កេតបឋមពីអាជ្ញាធរ មូលហេតុនាំឱ្យកុមារីមានគ្រោះថ្នាក់នៅកន្លែងឡឥដ្ឋបែបនេះ ព្រោះជាទម្លាប់កូនៗ តែងទៅតាមនិងលេងនៅកន្លែងការងារឪពុក ម្តាយនិងមិនមែនជាករណីជួលពលកម្មកុមារឡើយ។ លោកថ្លែងថា៖ «យើងនៅតែស៊ើបអង្កេតអ៊ីចឹង ប៉ុន្តែយើងមិនទាន់រកឃើញថា វាជាការជួលពលកម្មកុមារ គឺវាមិនមែន វាជាទម្លាប់នៅតាមឡឥដ្ឋជាទូទៅណ៎ា ឪពុកម្តាយទៅណា កូនវានៅតាមនៅហ្នឹង ដល់ហើយក្មេងៗអត់មានអីលេង ពេលម៉ែឪធ្វើការ មិនមកតាមម៉ែតាមឪ»។ លោក ចំរើន អះអាងថា ប្រសិនការស៊ើបអង្កេតបន្ត ហើយរកឃើញមានករណីរំលោភពលកម្មកុមារ អាជ្ញាធរនឹងប្រើវិធានការច្បាប់។

ទោះយ៉ាងណានៅក្នុងរបាយការណ៍ស្តីពី «ការអភិវឌ្ឍលើទាសភាព៖ ការបញ្ចាំខ្លួនដោះបំណុល និងពលកម្មកុមារក្នុងសិប្បកម្មផលិតឥដ្ឋនៅកម្ពុជា» របស់អង្គការលីកាដូ កាលពីឆ្នាំ ២០១៦ បានឲ្យដឹងថា ម្ចាស់សិប្បកម្មផលិតឥដ្ឋ បានប្រើមធ្យោបាយជ្រើសរើសកម្មករ ដោយផ្តល់ប្រាក់កម្ចី និងផ្តល់កន្លែងស្នាក់នៅ សម្រាប់គ្រួសារទីទាល់ក្រ ហើយតម្រូវឱ្យគ្រួសារទាំងនោះ ត្រូវធ្វើការជាកម្មករឡឥដ្ឋរហូតអាចទូទាត់សងបំណុលវិញគ្រប់ចំនួន។ ប៉ុន្តែយ៉ាងណាក្តីក្រុមគ្រួសារទីទាល់ក្រមិនអាចមានលទ្ធភាពសងបំណុលរួចឡើយ ទោះជាត្រូវសងអស់ ៣ជំនាន់ក្តី និងមានតែជំពាក់បំណុលជំនាន់បន្ថែមទៀត ដោយសារប្រាក់ឈ្នួលទទួលបាន ក្នុងសិប្បកម្មឡឥដ្ឋ មានចំនួនទាបពេក។ របាយការណ៍នេះបានចេញ បន្ទាប់ពីអង្គការលីកាដូ បានចុះទៅស្រាវជ្រាវសិប្បកម្មផលិតឥដ្ឋជាង ១០០ មានកម្មកររាប់ពាន់នាក់ដែលមានទីតាំងនៅក្បែររាជធានីភ្នំពេញ ហើយបានសម្ភាសកម្មករផ្ទាល់ចំនួន ៥០ នាក់ ដែលជាមនុស្សពេញវ័យ និងកុមារ។ អង្គការលីកាដូបញ្ជាក់ថា ឪពុក ម្តាយស្ទើរតែទាំងអស់ បាននិយាយថា កូនៗពួកគេ ដែលជាកុមារ បានជួយធ្វើការងារនៅឡឥដ្ឋ ព្រោះការចូលរួមជួយធ្វើការងារពីសមាជិកគ្រួសារ នឹងធ្វើឱ្យចំនួនផលិតឥដ្ឋកើនឡើងហើយនឹងធ្វើឱ្យប្រាក់ចំណូលសម្រាប់គ្រួសារពួកគេ ក៏កើនឡើងដែរ។ ប៉ុន្តែកាលនោះ ក្រសួងការងារ បានបដិសេធការរកឃើញនេះ និងបញ្ជាក់ថា ក្រសួងមិនអនុញ្ញាតឲ្យកុមារធ្វើការងារនៅឡឥដ្ឋទេ។

លោក អំ សំអាត អ្នកគ្រប់គ្រងការិយាល័យឃ្លាំមើលសិទ្ធិមនុស្សនៃអង្គការលីកាដូ ប្រាប់ភ្នំពេញប៉ុស្តិ៍កាលពីម្សិលមិញថា តាមអ្វីដែលអង្គការលីកាដូរកឃើញកន្លងមក គឺករណីគ្រោះថ្នាក់នៅឡឥដ្ឋមានខ្លះធ្វើឱ្យកុមារដាច់ដៃ និងខ្លះទៀតធ្វើឱ្យកុមារបាត់បង់ជីវិតតែម្តង។ លោកបន្តថា បើអាជ្ញាធរ បានចុះធ្វើអធិការកិច្ចផ្ទាល់ជាមួយម្ចាស់ឡឥដ្ឋ ហើយបានដាក់ចេញលក្ខខណ្ឌតឹងរឹង ឬកិច្ចសន្យាជាមួយថៅកែឡឥដ្ឋ កុំឱ្យទទួលយកកុមារមកធ្វើការនៅឡឥដ្ឋ ឬមានការតម្រូវណាមួយឱ្យម្ចាស់ឡឥដ្ឋ ព្រមានបញ្ឈប់កម្មករដែលនាំកូនៗមកជួយកម្លាំងពលកម្មនៅឡឥដ្ឋ ហើយនៅតែមានករណីគ្រោះថ្នាក់បែបនេះ គឺម្ចាស់ឡឥដ្ឋត្រូវប្រឈមនឹងច្បាប់។ លោកថា៖ «ដើម្បីចៀសវាង បើសិនក្មេងអត់កន្លែងលេង ត្រូវបង្កើតកន្លែងមួយសម្រាប់ក្មេងលេងនៅអំឡុងពេលឪពុកម្តាយកំពុងធ្វើការ ដើម្បីកុំឱ្យក្មេងទៅជិតកន្លែងឡឥដ្ឋហ្នឹង ប៉ុន្តែកន្លងមកយើងឃើញថា ឪពុកម្តាយខ្លះដើម្បីឱ្យបានកម្រៃច្រើនបានយកកូនឱ្យជួយធ្វើនេះធ្វើនោះ ហើយទាំងអស់នេះ បើថៅកែឡឥដ្ឋឆ្លើយថា អត់ដឹង វាអត់ត្រូវទេ ព្រោះវាជាការគ្រប់គ្រងរបស់គាត់ ហើយត្រូវតែមានវិធានការ ហើយបើនៅតែឆ្លើយអ៊ីចឹងទៀត កុមារនឹងកាន់តែបន្តរងគ្រោះបន្ថែមទៀតហើយ»។

ភ្នំពេញប៉ុស្តិ៍ មិនអាចសុំការបកស្រាយ ពីលោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទេកាលពីម្សិលមិញដោយទូរស័ព្ទលោកពុំមានអ្នកទទួល។

ចំណែកលោក លឹម សារ៉ុម ប្រធានមន្ទីរការងារខេត្តកណ្តាលថ្លែងថា លោកជាប់ប្រជុំមិនអាចធ្វើអធិប្បាយលើបញ្ហានេះបានទេ៕

# សមត្ថកិច្ចថៃចាប់កម្មករខ្មែរ៣នាក់ ក្រុមគ្រួសារមកសុំឲ្យអាជ្ញាធរខេត្តជួយ

https://news.kohsantepheapdaily.com.kh/ By mony koh March 12, 2019

ខេត្តកោះកុង ៖ នៅព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ មានពលរដ្ឋប្រមាណ៣០នាក់ បានមកជួបជុំគ្នា នៅមុខសាលាខត្តកោះកុង ក្នុងបំណងទទួចសុំឲ្យអាជ្ញាធរខេត្ត ធ្វើការសម្របសម្រួលជាមួយសមត្ថកិច្ចថៃ ខេត្តត្រាត ឲ្យមានការដោះលែងកូនក្មួយរបស់ពួកគាត់ចំនួន៣នាក់ ដែលចេញទៅនេសាទលក្ខណៈ គ្រួសារ ក្នុងដែនសមុទ្រកោះកុង ហើយត្រូវបានកងទាហានជើងទឹកថៃ ចាប់ខ្លួនកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៩ កន្លងទៅ។ ប៉ុន្តែការទន្ទឹងរង់ចាំនេះវាបានអូសបន្លាយពេលអស់ជាច្រើនខែកន្លងមក ហើយអាជ្ញាខេត្តក៏មិនព្រងើយកន្តើយក្នុងការជួយរកដំណោះស្រាយលើករណីនេះដែរ និងកំពុងបន្តនីតិវិធីយ៉ាងយកចិត្តទុកដាក់ថែមទៀតផង។ ពួកគាត់បានរៀបរាប់ថា បន្ទាប់ពីសមត្ថកិច្ចថៃចាប់ខ្លួនទាំងទូកទាំងមនុស្សចំនួន៣នាក់នោះភ្លាម ពួកគាត់បានមករាយការណ៍ និងសុំឲ្យអាជ្ញាធរខេត្តជួយអន្តរាគមន៍ឲ្យមានការដោះលែង។

ប៉ុន្តែបន្ទាប់ពីអាជ្ញាធរខេត្ត បានចាត់តាំង លោក សុវណ្ណ ប៊ុនធឿន ប្រធានស្នាក់ការច្រកទ្វារអន្តរជាតិចាំយាម ចូលទៅធ្វើការសម្របសម្រួល ជាមួយភាគីថៃ សំណុំរឿងខាងលើនេះត្រូវបានសមត្ថកិច្ចថៃបញ្ជូនឡើងតុលាការបាត់ទៅហើយ ជាហេតុធ្វើឲ្យដំណោះស្រាយត្រូវអូសបន្លាយពេលដើម្បីរង់ចាំនីតិវិធីតុលាការថៃទៅវិញ។ លោក សុវណ្ណ ប៊ុនធឿន បានប្រាប់កោះសន្តិភាពតាមទូរស័ព្ទកាលពីព្រឹកថ្ងៃទី១១ មីនាថា កម្មករទូកនេសាទទាំង៣នាក់ នោះគឺ១-ឈ្មោះ ហេង លេងប្រុស អាយុ២៥ឆ្នាំ ជាកម្មករ ២-ឈ្មោះ សេង ម៉េងឡាយ ភេទប្រុស អាយុ២៥ឆ្នាំ ជាកម្មករ ៣-ឈ្មោះ អ៊ូច ណាក់ ភេទប្រុស អាយុ២៧ឆ្នាំ ជាតៃកុងទូក ទាំង៣នាក់ មានទីលំនៅក្នុងភូមិ២ សង្កាត់ដងទង់ ក្រុងខេមរៈភូមិន្ទ ខេត្តកោះកុង។ លោក សុវណ្ណ ប៊ុនធឿន បានបញ្ជាក់ទៀតថា បន្ទាប់ពីសមត្ថកិច្ចថៃចាប់ខ្លួនបាន កម្មករនេសាទទាំង៣នាក់ ត្រូវបានចោទប្រកាន់ លើកំហុសឆ្លងផ្លូវច្បាប់ជាច្រើនអន្លើ ដូចជាការប្រើឧបករណ៍ត្រីវិស័យ ភ្លើងហ្វាបំភ្លឺ រំលោភបូរណៈភាព ទឹកដី និងកំហុសផ្សេងៗទៀតជាច្រើន និងត្រូវបានសាមីខ្លួនផ្តិតស្នាមមេដៃទទួលកំហុសទាំងអស់នោះ។

ប៉ុន្តែក្រោយពីមានការសម្របសម្រួលរវាងអាជ្ញាធរខេត្តទាំង២រួចមក តុលាការខេត្តត្រាតបានទម្លាក់ចោល ការចោទប្រកាន់ស្ទើរតែទាំងអស់ នៅមានកំហុសឆ្លងតែ១គត់គឺរំលោភបូរណៈភាពទឹកដី ហើយត្រូវបាន តុលាការវិនិច្ឆ័យទោសកាលពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩ ពិន័យជាប្រាក់ចំពោះកម្មករទូកម្នាក់ៗ ចំនួន៥ម៉ឺនបាត រីឯតៃកុងទូកត្រូវពិន័យជាប្រាក់ ចំនួន១០ម៉ឺនបាត។ ក្នុងករណីមិនមានប្រាក់ បង់ថ្លៃផាកពិន័យនេះទេ សាមីខ្លួនត្រូវជាប់ទោសសងក្នុង១ថ្ងៃ៥០០បាត ចាប់ពីថ្ងៃប្រកាសសាលក្រម នេះតទៅ (ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩) រហូតទាល់តែគ្រប់ចំនួនប្រាក់ដែលសាមីខ្លួនត្រូវបង់ទើបអាចរួចទោសហើយត្រូវបានដោះលែង។ លោក សុវណ្ណ ប៊ុនធឿន បានបញ្ជាក់ទៀតថា ពេលនេះអាជ្ញាធរខេត្តកំពុងរិះរកដំណោះស្រាយ ឲ្យអស់ពី លទ្ធភាពសហការជាមួយក្រុមគ្រួសារជនរងគ្រោះ ដើម្បីបន្ធូបន្ថយរាល់ការចំណាយទាំងនេះ អោយមានកម្រិតទាបបំផុត។

ក្រុមគ្រួសារកម្មករនេសាទទាំង៣រូប បានរៀបរាប់ថា ពួកគាត់សុទ្ធតែមានជីវភាពក្រីក្រ ហេតុនេះទើបសុខចិត្តប្រើកូនក្មួយឲ្យចេញទៅនេសាទកាត់ព្យុះ កាត់រលកប្តូរជិវិតនឹងគ្រោះថ្នាក់ មិនបានរៀនសូត្រជ្រៅជ្រះព្រោះតែជីវភាពខ្វះខាត ឥឡូវត្រូវសមត្ថកិច្ចថៃចាប់ខ្លួនរាប់ខែបែបនេះ ពួកគាត់ពិតជារងទុក្ខវេទនាខ្លាំងណាស់ ពួកគាត់ធ្វើនេសាទលក្ខណៈគ្រួសារតែប៉ុណ្ណោះចេញនេសាទតែក្នុងដែនសមុទ្រកោះកុង ក្បែរៗកោះយ៉ះនេះឯង តែគេចោទថារំលោភចូលដែនសមុទ្រថៃ ចុះទូកនេសាទថៃខ្នាតយក្ស រាប់សិបគ្រឿងក្នុងមួយថ្ងៃៗចូលមកដល់ក្បែរៗកោះស្តេច ម្តេចក៏សមត្ថកិច្ចខ្មែរមិនចាប់។ ពេលនេះពួកគាត់សំណូមពរដល់សម្តេចប្រមុខរាជរដ្ឋាភិបាលមេត្តាជួយរកយុត្តិធម៌ឲ្យពួកគាត់ដែលត្រូវសមត្ថកិច្ចថៃចាប់ដាក់គុកយ៉ាងអយុត្តិធម៌នេះផង៕ ដោយ ៖ ម៉ៅ គឹមហេង

# អ្នកជំនាញថា ពលករខ្មែរនៅតែធ្វើចំណាកស្រុកទៅក្រៅប្រទេសដោយភាពប្រថុយប្រថាននៅឡើយ

https://www.rfa.org/khmer/ ដោយ សុ ជីវី 2019-03-12

កម្ពុជាជាប្រទេសសម្បូរដោយកម្លាំងពលកម្ម ដែលពលរដ្ឋគ្រប់អាយុធ្វើការមានប្រមាណជិត ១០ លាននាក់។ ក្រសួងការងារអះអាង ថា ក្នុងចំណោមកម្លាំងពលកម្មទាំងនេះ ប្រមាណជា ជាង ១ លាននាក់ កំពុងធ្វើការនៅក្រៅប្រទេស និងបានផ្ញើប្រាក់មកឱ្យគ្រួសាររបស់ពួកគេជាង ២ ពាន់លានដុល្លារអាមេរិក ក្នុងមួយឆ្នាំ។ អ្នកការពារសិទ្ធិពលករចំណាកស្រុកអះអាងថា ថវិកាទាំងនេះមិនមែនជារឿងគួរឱ្យមានមោទនភាពនោះឡើយ ពីព្រោះពលករចំណាកស្រុកនៅតែប្រឈមបញ្ហាជាច្រើន ដែលតម្រូវឱ្យរបបក្រុងភ្នំពេញជួយដល់ពួកគេបន្ថែមទៀត។ អ្នកជំនាញផ្នែកសិទ្ធិការងារអះអាងថា ពលរដ្ឋខ្មែរនៅតែធ្វើចំណាកស្រុកដោយភាពប្រថុយប្រថាននៅឡើយ ពោលគឺមានន័យថា បើពួកគេធ្វើការចំកន្លែងដែលនិយោជកគោរពសិទ្ធិការងារ ពួកគេទទួលបានអត្ថប្រយោជន៍ច្រើន ប៉ុន្តែបើប៉ះចំនិយោជកមិនល្អ ពួកគេត្រូវរងការរំលោភបំពានសិទ្ធិ និងទទួលបានផលប្រយោជន៍តិចតួចពីការងាររបស់ខ្លួន។

មន្ត្រីកម្មវិធីនៃមជ្ឈមណ្ឌលសម្ពន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) លោក ឌី ថេហូយ៉ា ថ្លែងថា បើប្រៀបធៀបនឹងប្រទេសក្នុងតំបន់ ដូចជា វៀតណាម ថៃ និងហ្វីលីពីន ជាដើម ពលករចំណាកស្រុកខ្មែរមានជំនាញទាបជាងគេ។ លោកប៉ាន់ស្មានថា ចន្លោះពី ៨០% ទៅ ៩០% នៃកម្មករចំណាកស្រុករបស់កម្ពុជា គឺជាប្រភេទកម្មករគ្មានជំនាញ និងមានជំនាញតិចតួច ដែលធ្វើឱ្យពួកគេងាយប្រឈមនឹងការរំលោភសិទ្ធិការងារ និងការជួញដូរកម្លាំងពលកម្ម។ លោកមើលឃើញថា មូលហេតុដែលពលករខ្មែរភាគច្រើន មិនមានជំនាញ និងមានជំនាញទាបបែបនេះ ដោយសារតែពួកគេមិនទទួលបានការបណ្ដុះបណ្ដាលជំនាញបច្ចេកទេសឱ្យបានច្បាស់លាស់ មុននឹងចេញទៅធ្វើការនៅបរទេស៖ «ដោយសារអត់មានការងារធ្វើនៅកន្លែងនេះ អ៊ីចឹងគាត់ទៅរកការងារធ្វើដោយប្រើប្រាស់កម្លាំងសុទ្ធសាធ ដែលមិនបានឆ្លងកាត់វគ្គបណ្ដុះបណ្ដាល ឬមានសាលាវិជ្ជាជីវៈដូចនៅស្រុកគេទេ។ ដូច្នេះហើយកម្មករដែលគ្មានជំនាញនេះ មានបញ្ហាច្រើន បើប្រៀបធៀបនឹងកម្មករជំនាញ។ ទីមួយគាត់ចំណាកស្រុកដោយមិនមានឯកសារ ទៅច្រកដែលមិនផ្លូវការ។ គាត់ប្រឈមនឹងការចាញ់បោកគេ។ គាត់ទៅដល់កន្លែងធ្វើការហើយ គេធ្វើបាបគាត់ គាបសង្កត់គាត់ មិនបើកប្រាក់ខែឱ្យគាត់ ឬមួយគាត់អាចប្រឈមនឹងការលក់ដូរ ជួញដូរចុះទូក (នេសាទ) ជាដើម»។

តួលេខរបស់ក្រសួងការងារបង្ហាញថា ពលករចំណាកស្រុកដែលកំពុងធ្វើការនៅបរទេសមានជាង ១ លាន ២ សែននាក់ ក្នុងនោះស្រីមានជិត ៥០ ម៉ឺននាក់។ ប្រទេសថៃមានពលករខ្មែរធ្វើការច្រើនជាងគេ គឺជាង ១ លាន ១ សែននាក់ ខណៈកូរ៉េខាងត្បូង មានប្រមាណជាជិត ៥ ម៉ឺននាក់។ ចំណែកនៅប្រទេសម៉ាឡេស៊ីវិញ ពលករខ្មែរមានចំនួនជាង ៣ ម៉ឺននាក់ ខណៈប្រទេសជប៉ុនមានជិត ១ ម៉ឺននាក់ និងសិង្ហបុរីជាង ៨ រយនាក់។ រីឯនៅហុងកុងវិញ ពលករខ្មែរមានជាង ៥០ នាក់ និងនៅអារ៉ាប់ប៊ីសាអូឌីតចំនួន ១៦ នាក់។ ក្រៅពីនេះ របបក្រុងភ្នំពេញក៏គ្រោងបញ្ជូនពលកររាប់ពាន់នាក់ផ្សេងទៀតទៅប្រទេសប នៅតំបន់មជ្ឈិមបូព៌ាផងដែរ រួមមានប្រទេសកាតា (Qatar) គុយវ៉ែត (Kuwait) និងប្រទេសលីបង់ (Lebanon)។

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លោក អ៊ិត សំហេង បានអះអាងថ្មីៗនេះថា ពលករខ្មែរនៅបរទេសទទួលបានកិច្ចគាំពារតាមផ្លូវច្បាប់ និងការអន្តរាគមន៍ជួយសង្គ្រោះ នៅពេលមានបញ្ហាកើតឡើង ជាពិសេសពួកគេទទួលបានការអនុគ្រោះ មិនបង់ថ្លៃលើលិខិតធ្វើដំណើរ។ លោកឱ្យដឹងទៀតថា ក្នុងឆ្នាំ២០១៨ កន្លងទៅ ពលរដ្ឋខ្មែរដែលធ្វើការនៅបរទេស បានផ្ញើថវិកាមកឱ្យក្រុមគ្រួសាររបស់ពួកគេ បានជាង ២ ពាន់ ៣ រយលានដុល្លារអាមេរិក និងទទួលបានមុខជំនាញវិជ្ជាជីវៈបន្ថែម ដើម្បីរួមចំណែកអភិវឌ្ឍជាតិ នៅពេលពួកគេត្រឡប់មកវិញផងដែរ។

ទោះជាយ៉ាងណា អ្នកការពារសិទ្ធិពលករចំណាកស្រុកអះអាងថា ក្នុងចំណោមពលករចំណាកស្រុក មានតែកម្មករនៅប្រទេសកូរ៉េខាងត្បូងមួយប៉ុណ្ណោះ ដែលទទួលបានការបំពាក់បំប៉នជំនាញបន្ថែម និងបានធ្វើការក្នុងរោង

ចក្រឧស្សាហកម្ម ក្រៅពីនេះពលករខ្មែរបន្តធ្វើការដោយប្រើកម្លាំងសុទ្ធសាធ។ លើសពីនេះ ពលករខ្មែរត្រូវចំណាយប្រាក់ផ្ទាល់ខ្លួនជាច្រើន ទៅឱ្យភ្នាក់ងារបញ្ជូនពលករ និងការចំណាយលើឯកសារផ្លូវច្បាប់នានា ទម្រាំបានចេញទៅធ្វើការនៅក្រៅប្រទេស។

យុវជន ឯក ចេស្តា អាយុ២៦ ឆ្នាំ គឺជាពលករចំណាកស្រុកម្នាក់ដែលកំពុងធ្វើការឱ្យរោងចក្រឧស្សាហកម្មមួយនៅប្រទេសកូរ៉េខាងត្បូង។ លោកថ្លែងប្រាប់អាស៊ីសេរីថា មុននឹងបានមកធ្វើការនេះ លោកត្រូវចំណាយថវិកាអស់ជាង ៣ពាន់ដុល្លារអាមេរិក ចំណែកមិត្តភ័ក្តិរបស់លោកវិញ ចំណាយអស់ចន្លោះពី ៧ ទៅ ៨ ពាន់ដុល្លារ ដោយសារពួកគេឱ្យភ្នាក់ងារបញ្ជូនពលករជាអ្នករៀបចំឱ្យ។ លោកឱ្យដឹងទៀតថា ពលករម្នាក់ៗជាអ្នករ៉ាប់រងការចំណាយដោយខ្លួនឯង ហើយពួកគាត់ត្រូវខ្ចីបុលគេដើម្បីបង្គ្រប់ការចំណាយ។ លោកថ្លែងទៀតថា មុនចាកចេញពីកម្ពុជា ពួកលោកបានទទួលការអប់រំពីមន្ត្រីខ្មែរតែទៅលើរឿងរបៀបរបប និងសីលធម៌រស់នៅក្នុងប្រទេសគេប៉ុណ្ណោះ ដោយឡែកខាងជំនាញបច្ចេកទេសវិញ គ្មានការបង្រៀននោះឡើយ ទាល់តែពូកលោក ទៅដល់ប្រទេសកូរ៉េខាងត្បូង ទើបភាគីក្រុមហ៊ុនបានបណ្តុះបណ្តាលពួកលោក។ ពលកររូបនេះបញ្ជាក់ថា រយៈពេលជិតពីរឆ្នាំដែលលោកបានធ្វើការនៅប្រទេសកូរ៉េខាងត្បូង មិនដែលឃើញមន្ត្រីខ្មែរណាម្នាក់ចុះទៅសួរសុខទុក្ខពួកលោកឡើយ លុះត្រាណាតែមានកម្មវិធីរបស់បក្សទើបមានការកៀរគរឱ្យពលករចូលរួម៖ «ធ្វើការនៅស្រុកខ្មែរបានប្រាក់ខែតិច មិនអាចទូទាត់ថ្លៃការចំណាយផ្សេងៗប្រចាំថ្ងៃ សរុបដល់ខែក៏អស់លុយ។ ទាំងគេ ទាំងខ្ញុំទទួលយកមិនបាន ដោយសារប្រាក់ខែវាតិចពេក ហើយតម្លៃទីផ្សារវាឡើងថ្លៃជារៀងរាល់ឆ្នាំ។ មិនដឹងថាដល់កុងត្រា ឬមួយក៏អត់នោះទេ ព្រោះខ្ញុំត្រូវចាកចេញទៅមាតុភូមិវិញ ព្រោះអត់ដែលមានគិតថា ចង់នៅធ្វើអន្តោប្រវេសន៍នៅប្រទេសគេទេ។ យើងចង់ទៅរស់នៅប្រទេសកំណើតរបស់យើង យកចំណេះជំនាញដែលយើងធ្លាប់ទទួលបានបទពិសោធន៍នៅប្រទេសកូរ៉េទៅអភិវឌ្ឍខ្លួននៅប្រទេសកំណើតវិញ»។ ពលករចំណាកស្រុកដែលធ្វើនៅប្រទេសកូរ៉េខាងត្បូងទទួលបានប្រាក់ខែអប្បបរមាជាង ១ ពាន់ ៣ រយដុល្លារអាមេរិក ក្នុងមួយខែ ខណៈប្រទេសថៃដែលមានពលករខ្មែរច្រើនជាងគេនោះវិញ ទទួលបានចំណូល ប្រមាណ ៣ រយដុល្លារអាមេរិក ក្នុងមួយខែ។

អាស៊ីសេរីបានព្យាយាមទាក់ទងអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ ជាច្រើនដង តាំងពីថ្ងៃទី០៦ មីនា ដើម្បីសុំប្រតិកម្មជុំវិញរឿងនេះ ក៏ប៉ុន្តែលោកមិនដែលទទួលទូរស័ព្ទ។ អាស៊ីសេរីក៏ព្យាយាមសុំការឆ្លើយតបរឿងនេះពីអ្នកនាំពាក្យរបបក្រុងភ្នំពេញលោក ផៃ ស៊ីផាន ដែរ នៅថ្ងៃទី១១ និង ១២ មីនា តែលោកមិនលើកទូរស័ព្ទដូចគ្នា។

ចំណែកអ្នកនាំពាក្យគណបក្សកាន់អំណាច លោក សុខ ឥសាន វិញ ថ្លែងដោយមោទនភាពថា ចំនួនពលរដ្ឋខ្មែរដែលចេញទៅធ្វើការនៅបរទេសនេះ គឺដោយសារតែស្រុកទេសមានសន្តិភាព។ លោកបន្តថា ការធ្វើចំណាកស្រុកផ្តល់ផលប្រយោជន៍ដល់ប្រទេសជាតិ និងដល់ពលករខ្លួនឯងផ្ទាល់។ លោកថា ផលប្រយោជន៍នោះ គឺពលករបានប្រាក់ចំណូលផ្គត់ផ្គង់ និងលើកកម្ពស់ជីវភាពគ្រួសារ ដែលនេះជាការរួមចំណែកដល់សេដ្ឋកិច្ចជាតិ។ លោកបន្ថែមថា ការបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេសនេះ គឺជាគោលនយោបាយជួយរកការងារធ្វើឱ្យប្រជាពលរដ្ឋ ក៏ប៉ុន្តែអ្នកនាំពាក្យរូបនេះមិនបកស្រាយឡើយពីបញ្ហាប្រឈមទាំងឡាយរបស់ពលករចំណាកស្រុក និងថាតើកម្ពុជាគួរធ្វើយ៉ាងណាបង្កើតការងារដែលមានប្រាក់ខែសមរម្យឱ្យបានច្រើនដើម្បីកាត់បន្ថយពលករចំណាកស្រុកនោះទេ។

ចំណែកអ្នកការពារសិទ្ធិពលករចំណាកស្រុក លោក ឌី ថេហូយ៉ា វិញថ្លែងថា មិនមែនជារឿងដែលរដ្ឋាភិបាលគួរមានមោទនភាពនោះទេ នៅពេលពលរដ្ឋរបស់ខ្លួន ក្លាយជាកម្មករចំណាកស្រុកដែលគ្មានជំនាញ និងមានជំនាញទាបបែបនេះ។ ផ្ទុយទៅវិញ នេះជារឿងដែលរដ្ឋាភិបាលត្រូវគិតគូរដោះស្រាយ។ ម្យ៉ាងវិញទៀត លោកថា រដ្ឋាភិបាលត្រូវពង្រឹងយន្តការជួយការពារសិទ្ធិពលករចំណាកស្រុក ដោយកុំរង់ចាំពួកគេមករាយការណ៍ប្រាប់ដល់ទីកន្លែង៖ «បើគាត់ចំណាកស្រុកក្នុងន័យប្រថុយប្រថានទៅទេ គាត់ជួបមនុស្សល្អ ក៏ល្អ គាត់ជួបមនុស្សអាក្រក់ គេធ្វើបាបគាត់ អត់មានយន្តការរដ្ឋណាធានាទេ អាហ្នឹងវាមិនមែនជារឿងដែលគួរមោទនភាពទេ។ ប្រាក់ចំណូលជាផ្នែកមួយហើយ ប៉ុន្តែ

បើយើងឱ្យស៊ីជម្រៅ មោទនភាពរបស់យើង គឺពលរដ្ឋយើងទៅបម្រើការងារគេដោយសេចក្ដីថ្លៃថ្នូរ មិនត្រូវបានគេរំលោភសិទ្ធិ ហើយពលករខ្មែរយើងត្រូវបានគ្រប់គ្រង ការពារដោយរដ្ឋ មានបញ្ហាអ្វី រដ្ឋចុះជួយទប់ស្កាត់បានទាន់ពេលវេលា»។ តាមការប៉ាន់ស្មានក្រៅផ្លូវការរបស់អង្គការសង់ត្រាល់ (CENTRAL) ចំនួនពលករខ្មែរដែលកំពុងធ្វើការនៅបរទេស មានជាង២ លាននាក់ ដែលក្នុងនោះចន្លោះពី ១ លាន ៨ សែន ទៅ ២ លាននាក់ កំពុងធ្វើការងារនៅប្រទេសថៃ ទាំងស្របច្បាប់ និងមិនស្របច្បាប់។ អ្នកសិក្សាស្រាវជ្រាវអះអាងថា កត្តាដែលធ្វើឱ្យពលរដ្ឋខ្មែរបន្តធ្វើចំណាកស្រុក គឺការទៅធ្វើការងារតាមគ្នា កង្វះខាតព័ត៌មានទីផ្សារការងារនៅក្នុងស្រុក ការរំពឹងថានឹងទទួលបានប្រាក់ចំណូលខ្ពស់ បញ្ហាបំណុល និងភាពក្រីក្រ ជាដើម។

អ្នកជំនាញខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោក ង៉ែត ជូ ថ្លែងថា ជាច្រើនឆ្នាំមកនេះ ពលករខ្មែរដែលចេញទៅធ្វើការនៅក្រៅប្រទេស នៅតែជាកម្លាំងពលកម្មដែលគ្មានជំនាញ ឬមានជំនាញទាបដដែល ដោយមិនទាន់ឃើញមានការផ្លាស់ប្ដូរទៅរកភាពប្រសើរឡើងនៅឡើយ។ ហេតុដូច្នេះលោកថា ក្ដីរំពឹងដែលថា កម្លាំងពលកម្មទាំងនោះនឹងត្រឡប់មកវិញជាមួយនឹងជំនាញបច្ចេកទេសក្នុងការជួយអភិវឌ្ឍជាតិនោះ ទំនងជាមិនអាចទៅរួចឡើយ។ លោកកត់សម្គាល់ថា នៅពេលផុតកិច្ចសន្យាការងារ កម្មករចំណាកស្រុកបានត្រឡប់មកកម្ពុជាវិញ រួចអ្នកខ្លះក៏រកការងារធ្វើនៅក្នុងស្រុក ក៏ប៉ុន្តែមួយចំនួនធំបានត្រឡប់ទៅធ្វើការជាពលករនៅក្រៅប្រទេសវិញដដែល៖ «ធម្មតាយើងទៅបំពាក់ជំនាញដែលនឹងអាចជួយអភិវឌ្ឍប្រទេសជាតិបាន លុះត្រាតែមុននឹងចេញទៅ យើងមានវគ្គបំពាក់បំប៉នជំនាញមូលដ្ឋានសិន។ ជារួមយើងអត់មានទេ។ បើគាត់ត្រូវទៅថៃ គាត់ទៅផៅតែម្ដង អត់មានការបណ្ដុះបណ្ដាល អត់មានអីទេ។ ទៅកូរ៉េអ៊ីចឹងយើងរៀនភាសាកូរ៉េតិចតួច ហើយយើងទៅធ្វើការដូចជាកម្មករខាងវេចខ្ចប់ ផ្នែកខាងកសិកម្ម ផ្នែកឧស្សាហកម្មមានដូចជា ការលើកដាក់ វាយកេះ ជាដើម។ អ៊ីចឹងវាមិនមែនជាជំនាញបច្ចេកទេសដែលអាចត្រឡប់មកវិញ ជួយកសាងសង្គមជាតិឱ្យបានដូចអ្វីដែលជាអ្នកជំនាញបច្ចេកទេសរឹងមាំនោះ គឺអត់ទេ»។ អ្នកជំនាញរូបនេះបន្តថា អនាគតកូនចៅពលករចំណាកស្រុកក៏ជារឿងសំខាន់ដែលរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ផងដែរ។ លោកថា ក្រៅតែពីប្រព័ន្ធអប់រំនៅសាលារដ្ឋ មិនឃើញមានការដាក់ចេញនូវគោលនយោបាយគាំពារថ្នាក់ជាតិដល់កូនចៅជនចំណាកស្រុកឡើយ ខណៈពួកគេខ្លះបានបោះបង់ចោលការសិក្សា និងខ្លះទៀតធ្វើចំណាកស្រុកទៅតាមឪពុកម្ដាយ។ លោកបន្ថែមថា បើបញ្ហានេះមិនត្រូវបានគិតគូរទេ វានឹងក្លាយជាបន្ទុកដ៏ធ្ងន់សម្រាប់រដ្ឋាភិបាលទៅថ្ងៃអនាគត ដោយសារកូនចៅជនចំណាកស្រុកទាំងនោះ នឹងក្លាយជាកម្លាំងពលកម្មដែលខ្វះជំនាញ ក្នុងបរិបទនៃការប្រកួតប្រជែងខាងសេដ្ឋកិច្ច និងការអភិវឌ្ឍតាមបែបបច្ចេកវិទ្យា៖ «ការផ្ទេរសាច់ប្រាក់ក្នុងមួយឆ្នាំជាង ២ ពាន់លាននេះ បើយើងមើលទៅ គឺស្មើនឹង ១០% នៃទំហំសេដ្ឋកិច្ចរបស់កម្ពុជា ២០ ពាន់លាន អ៊ីចឹងវាធំដែរ យើងទទួលស្គាល់។ ប៉ុន្តែមិនមែនជាមធ្យោបាយ និងជាដំណោះស្រាយដែលអាចឱ្យកម្ពុជាមានភាពប្រកួតប្រជែងនៅក្នុងតំបន់នាពេលអនាគតនោះទេ ពីព្រោះរយៈពេលវែង គឺយើងមានការខាតបង់សេដ្ឋកិច្ចច្រើន។ កម្លាំងពលកម្មរបស់គេ គេធ្វើការងារដែលមានតម្លៃខ្ពស់ ចំណែកឯយើងគ្រាន់តែជាអ្នកជួយការងារដែលមានតម្លៃទាប អ៊ីចឹងយើងហាក់បីដូចជា រុញច្រានសមត្ថភាពប្រកួតប្រជែងរបស់គេឱ្យកាន់តែឡើងខ្ពស់ ហើយសមត្ថភាពប្រកួតប្រជែងរបស់យើងហ្នឹងមិនសូវខ្ពស់នោះទេ»។ អ្នកជំនាញផ្ដល់យោបល់ថា ក្នុងរយៈពេលខ្លី រដ្ឋាភិបាលត្រូវពង្រឹងយន្តការគាំពារ និងជំនួយផ្នែកច្បាប់បន្ថែមទៀតដល់ពលករចំណាកស្រុកនៅគ្រប់ប្រទេសទាំងអស់ចំណែកក្នុងរយៈពេលវែងវិញរដ្ឋាភិបាលត្រូវខិតខំបណ្ដុះបណ្ដាលជំនាញបច្ចេកទេសដល់ពលរដ្ឋ និងបង្កើតការងារក្នុងស្រុកឱ្យបានច្រើនបន្ថែមទៀត ដើម្បីស្រូបយកកម្លាំងពលកម្មដែលបន្តកើនឡើងជាលំដាប់៕

## នគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិដាំ ទទួលពលរដ្ឋខ្មែរ ៤នាក់ ពីភាគីថៃ

https://www.facebook.com/ General Department of Immigration - GDI 12-03-2019

ឧត្តរមានជ័យ៖ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរ ៤នាក់ឲ្យមកកម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិដាំពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃដែលចេញតាមច្រកអូរស្មាច់ស្រុកត្រពាំងប្រាសាទខេត្តឧត្តរមានជ័យ៕

## ថៃបញ្ជូនពលករខ្មែរ ៤៨នាក់ មកឲ្យកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI 12-03-2019

បន្ទាយមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត នាវេលាម៉ោង ១៥និង០០នាទី ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរ ៤៨នាក់ ក្នុងនោះស្រី១៦នាក់ ដែលអាជ្ញាធរថៃបញ្ជូនមក៕

# ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩

## ឧទ្ធរណ៍បន្ថយទោសស្ត្រីម្នាក់ រឿងឲ្យសាច់ញាតិដើរសុំទាន

https://www.postkhmer.com/ គឹម សារុំ | Publication date 13 March 2019 | 14:41 ICT

**ភ្នំពេញ៖** ចៅក្រមសាលាឧទ្ធរណ៍កាលពីម្សិលមិញបានប្រកាសសាលដីកាដោយបន្ថយទោសស្ត្រីចំណាស់ម្នាក់ពីជាប់ពន្ធនាគារ ៨ ឆ្នាំមកនៅ ១ ឆ្នាំវិញ បន្ទាប់ពីបើកសវនាការជំនុំជម្រះកាលពីថ្ងៃទី ២៦ កុម្ភៈ ឆ្នាំ ២០១៩ ពាក់ព័ន្ធនឹងការបង្ខំឲ្យក្មួយនិងចៅប្រុសស្រីរបស់ខ្លួនដើរសុំទាននៅតាមផ្លូវនៅក្នុងក្រុងភ្នំពេញកាលពីឆ្នាំ ២០១៧។ ខណៈមានវត្តមានរបស់ជនជាប់ចោទនៅក្នុងបន្ទប់សវនាការដែរនោះលោកចៅក្រម ចាយ ច័ន្ទតារាវណ្ណ បានអានសាលដីកានៅចំពោះមុខស្ត្រីជាប់ចោទថា សំណុំរឿងនេះមានស្ត្រីជាប់ចោទឈ្មោះ ក្លូងចាន់នី អាយុ ៥៣ ឆ្នាំ ដែលកាលពីថ្ងៃបើកសវនាការស្ត្រីជាប់ចោទរូបនេះថា គាត់បានឲ្យចៅប្រុស-ស្រី របស់គាត់ដើរសុំទានអស់រយៈពេល ៧ ឆ្នាំមកហើយមុនសមត្ថកិច្ចចាប់ខ្លួន។ ស្ត្រីជាប់ចោទថាគាត់មានគំនិតឲ្យក្មួយនិងចៅដើរសុំទានគេនោះគឺដើម្បីយកលុយមកទិញទឹកដោះគោឲ្យចៅគាត់បៅ និងយកមកទិញបាយទឹកហូបប្រចាំថ្ងៃ ពីព្រោះម្តាយរបស់ពួកគេទៅរកស៊ីឆ្ងាយ។

លោកចៅក្រម បានអានសាលដីកាបន្តថា រឿងនេះស្ត្រីជាប់ចោទត្រូវសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសដាក់ពន្ធនាគារ ៨ ឆ្នាំ និងចោទពីបទជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចតាមបញ្ញត្តិមាត្រា ១២ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស។ បើយោងតាមមាត្រា ១២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះបានចែងថា ជនណាជ្រើសរើសជនដទៃដោយមិនស្របច្បាប់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ ឆ្នាំទៅ ១៥ ឆ្នាំ។

ប៉ុន្តែទោះជាយ៉ាងណា លោកចៅក្រមបានថ្លែងថា៖ «អ៊ុំស្រីជាប់ចោទគាត់មិនមែនជ្រើសរើសអ្នកដទៃមកឲ្យដើរសុំទានទេ តែក្មេងៗទាំងនោះជាក្មួយ និងជាចៅរបស់គាត់។ ដូច្នេះការដែលតុលាការថ្នាក់ក្រោមយកមាត្រា ១២ មកផ្តន្ទាទោសគាត់ គឺមិនត្រឹមត្រូវតាមច្បាប់ទេ។ សាលាឧទ្ធរណ៍សម្រេចបន្ថយទោសគាត់ពីជាប់ពន្ធនាគារ ៨ ឆ្នាំមកជាប់ពន្ធនាគារ ១ឆ្នាំវិញ ហើយកែប្រែបទចោទពីជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ចមកជាបទញុះញង់អនីតិជនឲ្យសុំទានតាមបញ្ញត្តិមាត្រា ៣៤៤ នៃក្រមព្រហ្មទណ្ឌវិញ»។ បើយោងតាមមាត្រា ៣៤៤ នៃក្រមព្រហ្មទណ្ឌនេះចែងថាជនណាញុះញង់ឲ្យអនីតិជនសុំទានត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែទៅ ១ ឆ្នាំ និងពិន័យជាប្រាក់ពី ១ សែនរៀលទៅ ២ លានរៀល។

តាមអង្គហេតុស្ត្រីជាប់ចោទឈ្មោះភួង ចាន់នី បានប្រើក្មួយនិងចៅប្រុសស្រីរបស់គាត់ដែលមានអាយុចន្លោះពី ៦ ឆ្នាំទៅ ១២ ឆ្នាំចំនួន ៧ នាក់ឲ្យដើរសុំទានចាប់ពីម្តុំវត្តភ្នំទៅដល់វត្តដំដែកក្នុងសង្កាត់វត្តភ្នំ រាជធានីភ្នំពេញ។ បន្ទាប់មកគាត់ត្រូវបាននគរបាលប្រឆាំងការជួញដូរមនុស្សរាជធានីភ្នំពេញចាប់ខ្លួននៅក្នុងអំឡុងឆ្នាំ ២០១៧៕

## កម្ពុជា និងថៃឯកភាពគ្នាបង្កើតរោងចក្រក្នុងទឹកដីកម្ពុជា ដើម្បីកាត់បន្ថយពលករចំណាកស្រុកខុសច្បាប់នៅប្រទេសថៃ

https://www.rfa.org/khmer/news/ ដោយ ម៉ៅ សុធានី 2019-03-13

មេដឹកនាំរបបក្រុងភ្នំពេញលោក ហ៊ុន សែន ថ្លែងនៅថ្ងៃទី១៣ ខែមីនាថា កម្ពុជា និងថៃឯកភាពគ្នាបង្កើតរោងចក្រក្នុងទឹកដីកម្ពុជា ដើម្បីកាត់បន្ថយការធ្វើចំណាកស្រុកខុសច្បាប់របស់ពលរដ្ឋខ្មែរទៅធ្វើការនៅប្រទេសថៃ។ ការបញ្ជាក់របស់លោក ហ៊ុន សែន នេះធ្វើឡើងនៅពេលជួបសំណេះសំណាលជាមួយកម្មករ កម្មការិនីជាង ១ម៉ឺននាក់នៅខេត្តកោះកុង។ លោក ហ៊ុន សែន បញ្ជាក់ថា ដើម្បីលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋខ្មែរនៅតាមបណ្ដោយព្រំដែននិងកាត់បន្ថយគ្រោះថ្នាក់នៃការធ្វើចំណាកស្រុកកម្ពុជានិងថៃសម្រេចបង្កើតរោងចក្រក្នុងទឹកដីកម្ពុជា៖ «យើងបានសិក្សារួមគ្នាថា ដើម្បីកាត់បន្ថយចំណាក់ស្រុកចូលទៅធ្វើការខុសច្បាប់ក្នុងប្រទេសថៃភាពចាំបាច់ត្រូវរួមគ្នាដើម្បីបង្កើតនូវរោងចក្រក្នុងទឹកដីកម្ពុជាជាតំបន់សេដ្ឋកិច្ចពិសេសតាមតំបន់បណ្ដោយព្រំដែនកម្ពុជា-ថៃ ដើម្បីឱ្យប្រជាជនកម្ពុជាមានការងារធ្វើនៅក្នុងទឹកដីរបស់ខ្លួនដោយមិនចាំបាច់ឆ្លងកាត់នៅក្នុងប្រទេសថៃនោះទេ»។ លោកហ៊ុន សែន ថា ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះលោកបានធ្វើការជាមួយនាយករដ្ឋមន្ត្រីថៃ ដើម្បីពិភាក្សាស្ដីពីការបង្កើតតំបន់សេដ្ឋកិច្ចពិសេសតាមបណ្ដោយព្រំដែនក្នុងគោលដៅបង្កើនទំនាក់ទំនងពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា-ថៃឱ្យបានកើនដល់ ៧ ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារអះអាងថា កាលពីឆ្នាំ២០១៨ របបក្រុងភ្នំពេញបានផ្ដល់ឱកាសការងារនៅក្រៅប្រទេសជូនប្រជាពលរដ្ឋចំនួនជាង ១លាន ២សែននាក់ ក្នុងនោះស្ត្រីមានជិត ៥០ម៉ឺននាក់។ ចំណែកនៅក្នុងប្រទេសថៃវិញ មានពលករខ្មែរធ្វើការប្រមាណ ១លាន ១សែននាក់ ដោយទទួលបានប្រាក់ឈ្នួល ៣០០ដុល្លារអាមេរិក ក្នុងមួយខែ។ ប៉ុន្តែប្រធានអង្គការសម្ព័ន្ធភាពការងារនិងសិទ្ធិមនុស្សលោក មឿន តុលា បញ្ជាក់ថាតាមការប៉ាន់ប្រមាណរបស់អង្គការលោកបច្ចុប្បន្ននៅប្រទេសថៃមានពលករខ្មែរចំណាកស្រុកជិត ២លាននាក់ ក្នុងនោះ ៨០% ជាពលករស្របច្បាប់។ ទោះបីយ៉ាងណា សង្គមស៊ីវិលអះអាងថា ប្រាក់ចំណូលដែលកម្មករខ្មែរនៅក្រៅប្រទេសរកបានភាគច្រើនមិនចំណេញដល់សេដ្ឋកិច្ចកម្ពុជានោះទេ ពីព្រោះលុយទាំងនោះភាគច្រើន កម្មករត្រូវផ្ញើមកសងបំណុលគេ ហើយកម្មករខ្លះ ក៏រងគ្រោះនៃការរំលោភបំពានសិទ្ធិ និងរាងកាយនៅបរទេសទៀតផង៕

## ការខិតខំរកដំណោះស្រាយជូនពលករខ្មែរ ដោយក្រុមការងារទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ

https://www.facebook.com/Pheaktra2019/ ពលករកម្ពុជាបំរើការងារក្នុងប្រទេសថៃ 13-03-2019

ថ្ងៃពុធ ៨កើត ខែផល្គុន ឆ្នាំច ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ បានចុះមកខេត្តឈុនបុរី ដើម្បីដោះស្រាយបញ្ហារបស់ពលករ ដែលនិយោជកបានកាត់ប្រាក់សម្រាប់ដំណើរការឯកសារស្របច្បាប់ហើយ ប៉ុន្តែមិនបានដំណើរការអោយពួកគាត់ ថៃមទាំងបញ្ឈប់ពីការងារដោយមិនបើកប្រាក់ឈ្នួលអោយថែមទៀត ដោយមានពលករសរុប ចំនួន៥២នាក់។ លទ្ធផលដែលទទួលបានមានដូចខាងក្រោម៖

-និយោជកយល់ព្រមសងប្រាក់ដែលបានកាត់សម្រាប់ដំណើរការធ្វើឯកសារជូនពលករវិញ ដោយនឹងប្រគល់ជូននៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩។

-រៀបចំធ្វើលិខិតបណ្តឹងចេញដែលអនុញ្ញាតអោយពលករអាចប្តូរនិយោជកបានក្នុងកំឡុងពេល១៥ថ្ងៃ ។

-និយោជកយល់ព្រមបើកប្រាក់ឈ្នួលដែលនៅសេសសល់ជូនពលករមិនអោយលើសពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

-និយោជកយល់ព្រមប្រគល់ឯកសាររបស់ពលករជូនពលករវិញទាំងអស់។

-នៅក្នុងអំឡុងពេលរង់ចាំទទួលប្រាក់ថ្លៃដំណើរការឯកសារត្រឡប់មកវិញ និយោជកនឹងបើកប្រាក់សំណាងជូនពលករក្នុង១ថ្ងៃ ៣០០បាត ដោយគិតចាប់ពីថ្ងៃទី១៣ ខែមីនាឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ មិនរួមបញ្ចូលថ្ងៃឈប់សំរាកការងារ(សៅរ៍ អាទិត្យ) ។

## ក្រឡាប់ រថយន្ត ឈ្នួល ដឹក ពលករ នៅ ព្រំដែន ស្លាប់ ០១នាក់ របួសធ្ងន់ ០៦នាក់

https://www.facebook.com/Pheaktra2019/ ពលករកម្ពុជាបំរើការងារក្នុងប្រទេសថៃ 13-03-2019

ប្រទេស ថៃ ៖យោង តាម របាយការណ៍ ពី ភ្នាក់ងារសង្គ្រោះ ខេត្តឆាក់ឈើងសៅ បានអោយដឹងថា កាលពីម៉ោង០៦ព្រឹក ថ្ងៃពុធ ទី១៣ ខែមីនា ឆ្នាំ២០១៩ នេះមានករណីគ្រោះថ្នាក់ក្រឡាប់រថយន្តឈ្នួលដឹកពលករខ្មែរចំនួន ១០ នាក់ មកពីតំបន់ប្រាំមសង ទៅព្រំដែនកើតគ្រោះថ្នាក់ក្រឡាប់ធ្លាក់ផ្លូវនៅលើផ្លូវជាតិ៣០៤ ត្រង់ចំណុចគីឡូម៉ែត្រ លេខ ៨៥-៨៦ ស្ថិតនៅក្នុងស្រុកមហាសារ៉ាខាម ខេត្តឆាក់ឈើងសៅ ប្រទេសថៃ។

ក្នុងហេតុការណ៍គ្រោះថ្នាក់ក្រឡាប់រថយន្តនេះ បានបណ្តាលឲ្យនារីពលករខ្មែរម្នាក់ ឈ្មោះ លៀង សៃណាយ អាយុ ២២ឆ្នាំ សញ្ជាតិខ្មែរស្លាប់ភ្លាមៗ នៅកន្លែងកើតហេតុ និងពលករចំនួន ០៥នាក់ ទៀតរងរបួសធ្ងន់ ក្រោយពេលកើតហេតុ ជនរងគ្រោះទាំងអស់ត្រូវបានសមត្ថកិច្ចថៃបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យបាងក្លាវ ខេត្តឆាក់ឈើងសៅ ។ ចំណែកឯមូលដែលបង្កឲ្យកើតគ្រោះថ្នាក់ក្រឡាប់រថយន្តនេះ សមត្ថកិច្ចថៃកំពុងធ្វើការសាកសួរអ្នកបើករថយន្តខាង ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

## សាកសពពលករខ្មែរ៣នាក់នៅ ប្រទេសថៃ ត្រូវបញ្ជូនមកឲ្យសាច់ញាតិ ធ្វើបុណ្យ

http://nokorwatnews.com/ 13-03-2019

ប៉ោយប៉ែត៖ គួរឲ្យសង្វេគសពពលករខ្មែរ៣ នាក់ស្លាប់នៅប្រទេថៃ បញ្ជូន ឲ្យសាច់ញាតិក្នុងពេលតែមួយតាមច្រកទ្វារអន្តជាតិប៉ោយប៉ែត កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ នៅក្នុងវត្តបាលិលេយ្យ ឋិតក្នុងភូមិក្បាលស្ពាន១ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីធ្វើបុណ្យនៅស្រុកកំណើត ។

សពរងគ្រោះទី១ ឈ្មោះ សួន ស៊ីចិន ភេទប្រុស អាយុជាង២០ឆ្នាំ រស់នៅភូមិសំរោង ឃុំធ្មេញត្រី ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ សាច់ញាតិបញ្ជាក់ថា សពរងគ្រោះជួបគ្រោះថ្នាក់ ចរាចរណ៍នៅប្រទេសថៃកាល ពីយប់ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ នៅក្នុងខេត្តឆាក់ធឹងសៅ ដោយសពរងគ្រោះត្រូវរថយន្តធុនតូចពីរគ្រឿងដែងគ្នា ជ្រុលចង្កូតមកបុកគ្រាដែលសព រងគ្រោះជិះម៉ូតូបត់ចូលផ្លូវលំសំដៅមកបន្ទប់ស្នាក់នៅ ។ ចំណែករថយន្តបង្កត្រូវសមត្ថកិច្ចថៃចាប់បានបន្ទាប់ពីបង្កហេតុ ។

សពរងគ្រោះទី២ មានឈ្មោះ ឌុយ តឿ ហៅឡា ភេទប្រុស អាយុ២៣ឆ្នាំ ជាកម្មកររោងចក្រដែក នៅប្រទេសថៃ មានទីលំនៅភូមិចម្លាក់ ឃុំចក ស្រុកអូររាំងឳ ខេត្តត្បូងឃ្មុំ ។ ឳពុកកជនរងគ្រោះឈ្មោះ ឌុយ ឡឿក អាយុ៥២ឆ្នាំ ប្រាប់ថា កូនប្រុសរបស់គាត់បានស្លាប់ ដោយសាររបូតគ្រីបដែក ធ្លាក់ពីរថយន្តសង្កត់ កាលពីព្រឹក ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ ពេលបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យសាមុទ្របាកាន ។

សពរងគ្រោះទី៣ មានឈ្មោះ លៀង សៃណាយ ភេទស្រី អាយុ២២ឆ្នាំ រស់នៅឃុំកំពងក្តី ស្រុកជីក្រែង ខេត្តសៀមរាប ជាកម្មករនៅប្រទេសថៃ ។ សាច់ញាតិប្រាប់ថា ស្ត្រីរងគ្រោះបានស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍កាលពីថ្ងៃទី

១២ ខែមីនា ឆ្នាំ២០១៩ នៅកំណាត់ផ្លូវជាតិលេខ៣០៤ ឋិតក្នុងស្រុកមហាវ៉ាខាម ខេត្តឆាកធឹងសៅ (ថៃ) ដោយរថយន្តថៃដឹកពលករខ្មែរ ក្រឡាប់ធ្លាក់ផ្លូវ ។

គួររំលឹកថាៈ ពលករខ្មែរស្លាប់១នាក់ របួសធ្ងន់៦នាក់ ក្នុងករណីក្រឡាប់រថយន្ត កាលពីម៉ោង ០៦ព្រឹក ថ្ងៃពុធ ទី១៣ ខែមីនា ឆ្នាំ២០១៩ ។ រថយន្តឈ្នួល ដឹកពលករខ្មែរ ចំនួន ១០នាក់ មកពីតំបន់ ប្រាំមសង ទៅព្រំដែនប្រទេសកម្ពុជា បានជួបគ្រោះថ្នាក់ចរាចរណ៍ ក្រឡាប់រថយន្តធ្លាក់ផ្លូវ នៅលើផ្លូវជាតិ ៣០៤ ត្រង់ចំណុចគីឡូម៉ែត្រ លេខ៨៥-៨៦ស្ថិតនៅក្នុងស្រុកមហាសារ៉ាខាម ខេត្តឆាក់ឈើងសៅ ប្រទេសថៃ ។ ក្នុងហេតុការណ៍គ្រោះថ្នាក់ចរាចរណ៍ក្រឡាប់រថយន្តខាងលើនេះ បណ្ដាលឲ្យស្ត្រីជាពលករខ្មែរម្នាក់ ឈ្មោះ លៀង សៃណយ អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរ ស្លាប់ភ្លាមៗនៅកន្លែងកើតហេតុ និងពលករចំនួន០៥នាក់ទៀតរងរបួសធ្ងន់ ក្រោយពេលកើតហេតុជនរងគ្រោះទាំងអស់ត្រូវបានសមត្ថកិច្ចថៃបញ្ជូនយកទៅព្យាបាលនៅមន្ទីរពេទ្យបាងក្លាវ ខេត្តឆាក់ឈើងសៅ ។ ចំណែកឯមូលដែលបង្កឲ្យកើតគ្រោះថ្នាក់ក្រឡាប់រថយន្តនេះ សមត្ថកិច្ចថៃកំពុងធ្វើការសាកសួរអ្នកបើករថយន្តខាងដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ៕ វណ្ណា

## កូរ៉េខាងត្បូង បានសន្យាបង្កើនកូតា ការងារសម្រាប់ពលករកម្ពុជា ទៅធ្វើការក្នុងប្រទេសរបស់ខ្លួន

http://bayontv.com.kh/ 14/03/2019

ភ្នំពេញ ៖ ឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសកូរ៉េខាងត្បូង បានលើកឡើងថា រដ្ឋាភិបាលកូរ៉េខាងត្បូង បានសន្យាបង្កើនកូតាការងារដល់ពលករកម្ពុជា ដែលនឹងចាកចេញទៅបម្រើការងារ ដោយ អះអាងថា ពលករកម្ពុជា មិនបង្កផលលំបាកពេលបំពេញការងារ។ ឯកឧត្តម ឡុង ឌីម៉ង់ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសកូរ៉េខាងត្បូងក្នុងកិច្ចសម្ភាសន៍ផ្ទាល់ជាមួយBTV បានបញ្ជាក់ថា ក្រោមកិច្ចសហប្រតិបត្តិការល្អ រវាងរដ្ឋាភិបាលកូរ៉េខាងត្បូង និងរដ្ឋាភិបាលកម្ពុជា ប្រទេសកូរ៉េខាងត្បូង បានសន្យា នឹងទទួលយកចំនួនពលករកម្ពុជាចូលទៅបម្រើការបន្ថែមទៀត ទោះបីជាសព្វថ្ងៃមានពលករកើនដល់ ១៦ជាតិសាសន៍ កំពុងបម្រើការក្នុងប្រទេសកូរ៉េខាងត្បូងក្តី។ ឯកឧត្តម ឡុង ឌីម៉ង់ បញ្ជាក់ថា សព្វថ្ងៃពលករកម្ពុជាប្រមាណ ជាង ៥ម៉ឺននាក់កំពុងបម្រើការងារ ក្នុងប្រទេសកូរ៉េខាងត្បូង។ការងារសំខាន់ៗដែលពលករកម្ពុជា បម្រើការ រួមមាន ៣វិស័យសំខាន់ៗ គឺវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសំណង់។

ឯកឧត្តម បន្តថា សម្រាប់ពលករកម្ពុជាដែលចេញទៅបម្រើការក្នុងប្រទេសកូរ៉េខាង ទទួលបានប្រាក់ខែខ្ពស់ជាងគេ ធៀបនឹងពលករកម្ពុជាដែលចេញទៅបំពេញការងារនៅប្រទេសដទៃ។ ក្នុងនោះ សម្រាប់ពលករបំពេញការងារក្នុងវិស័យ កសិកម្ម អាចទទួលបានប្រាក់ចន្លោះពី ១៥០០ ដុល្លារទៅ ១៨០០ ដុល្លារ រីឯពលករបំពេញការងារក្នុងវិស័យឧស្សាហកម្ម អាចទទួលបានប្រាក់ចន្លោះពី ១៨០០ ទៅ២៥០០ ដុល្លារ និងពលករដែលបំពេញកិច្ចការក្នុងវិស័យសំណង់ អាចទទួលបានចំណូលខ្ពស់ជាងគេ ដោយពួកគេអាចទទួលបានចន្លោះពី ២៨០០ ដុល្លារទៅដល់ ៣០០០ ដុល្លារ។សម្រាប់ពលករធ្វើការក្នុងវិស័យសំណង់ដែលមានលទ្ធភាព ម៉ៅការធ្វើដោយខ្លួនឯង អាចរកចំណូលបានរហូតដល់ប្រមាណ ៤០០០ ដុល្លារ ទៅ ៥០០០ដុល្លារក្នុងមួយខែ។ សព្វថ្ងៃមានពលករកម្ពុជាជាង ៥ម៉ឺននាក់កំពុងបម្រើការងារនៅក្នុងប្រទេសកូរ៉េខាងត្បូង ខណៈដែល ពលករកម្ពុជាចេញទៅបម្រើការនៅប្រទេស កូរ៉េខាងត្បូងប្រមាណ ៧ពាន់ទៅ៨ពាន់ នាក់ក្នុងមួយឆ្នាំ និង បានផ្ញើថវិកាមកកម្ពុជាវិញ មិនតិចជាង៦០០លានដុល្លារក្នុងមួយឆ្នាំនោះទេ៕

## សមត្ថកិច្ចចុះបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍ខាងជនបរទេស នឹងនារីខ្មែរ

http://nokorwatnews.com/ 16-03-2019

ខេត្តឧត្តរមានជ័យ៖ រៀបអាពាហ៍ពិពាហ៍អត់ច្បាប់ និងគ្មានការអនុញ្ញាត ពីអាជ្ញាធររវាងបុរសជាជនជាតិថៃ នឹងនារីខ្មែរ ត្រូវបានសមត្ថកិច្ចចុះទប់ស្កាត់ និងបញ្ឈប់នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ស្ថិតនៅភូមិពពេល ឃុំពពេល ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។ កម្លាំងសមត្ថកិច្ចចុះហាមឃាត់ និងបញ្ឈប់កម្មវិធីការរៀបអាពាហ៍ពិពាហ៍គ្មានច្បាប់អនុញ្ញាត ដោយមានកម្លាំងសហការរួមមាន ការិយាល័យស៊ើបអង្កេត និងអនុវត្តនីតិវិធី ផែនការងារអន្តោប្រវេសន៍ សហការជាមួយកម្លាំងជំនាញអធិការស្រុកត្រពាំងប្រាសាទ លោកមេឃុំផ្អាវ លោកមេឃុំពពេល រវាងជនបរទេស និងពលរដ្ឋខ្មែរនៅភូមិពពេល ឃុំផ្អាវ ស្រុកត្រពាំងប្រាសាទ។ សមត្ថកិច្ចបានឲ្យដឹងថា ជនជាតិថៃ ឈ្មោះ ប្រីឆា ប្រាក់ឌីតស៊ីល ភេទប្រុស អាយុ៣៧ឆ្នាំ និងពលរដ្ឋខ្មែរ ឈ្មោះ លុយ សំបូរ ភេទស្រី អាយុ៣៤ឆ្នាំ គ្រោងរៀបការនៅថ្ងៃទី១៦-១៧ ខែមីនា ឆ្នាំ២០១៩ ហើយត្រូវកម្លាំងសមត្ថកិច្ចជំនាញ បានណែនាំ និងឲ្យធ្វើកិច្ចសន្យាដល់អាណាព្យាបាល និងសាម៉ីខ្លួនឲ្យបញ្ឈប់ការរៀបអាពាហ៍ពិពាហ៍ដោយខុសច្បាប់ ៕ ប៉ែន នួន

## រថយន្ត១បាំងកន្លះ ពលករខ្មែរខំជិះប្រជ្រៀតគ្នា ១០នាក់ នៅតែគេចមិនរួចពីភ្នែកប៉ូលិសថៃ

https://kbn.news/archives/ March 16, 2019

**ថៃ៖** កាលពីប៉ុន្មានថ្ងៃមុននេះ សមត្ថកិច្ចបានឃាត់ខ្លួនពលករខ្មែរឆ្លងដែលខុសច្បាប់ បានចំនួន ១០នាក់ ក្នុងនោះមានជនជាតិថៃម្នាក់ ឈ្មោះ វិធៃ ខុមថង អាយុ ៤៨ឆ្នាំ ព្រមទាំងរថយន្តមួយបាំងកន្លះមួយគ្រឿង ។ ការឃាត់ខ្លួននេះបានធ្វើឡើងនៅចំណុចព្រំប្រទល់ថៃ-ខ្មែរ ស្រុកអារ៉ញប្រះថេត ។ តាមសម្តីរបស់តៃកុងរថយន្តឈ្មោះ ថៃតាយ ជនជាតិថៃបានឲ្យដឹងថា ខ្លួនបានដឹកពលករទាំង ១០នាក់នេះ មកពីទីក្រុងបាងកក ឆ្ពោះទៅកាន់ខេត្តស្រះកែវ ដែលជាព្រំប្រទល់ខ្មែរ-ថៃ ។ បើតាមសម្តីពលករខ្មែរម្នាក់បានឲ្យដឹងថា ពួកគេបានត្រឡប់មកពីទីក្រុងបាងកក ដើម្បីវិលត្រឡប់ទៅកាន់ប្រទេសកំណើតវិញ ហើយពេលទៅដល់ព្រំដែន គេនឹងធ្វើដំណើរទៅតាមច្រកលួចលាក់ នៃបន្ទាត់ព្រំដែន ។ ក្រោយមក សមត្ថកិច្ចបានឃាត់ខ្លួមពលករទាំងនោះ ព្រមទាំងតៃកុងរថយន្តយកទៅដោះស្រាយតាមច្បាប់ មុននឹងបញ្ជូនខ្លួនមកកាន់ប្រទេសកំណើតវិញ ៕ **សហការី** KBN

## ថៃបញ្ជូនពលករខ្មែរ ១៨នាក់ មកឲ្យកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI March 16 at 3:03 PM

បន្ទាយមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត នាវេលាម៉ោង ១៥និង០០នាទី ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរ១៨នាក់ ក្នុងនោះស្រី០២នាក់ និងកុមារ ០១នាក់ ដែលអាជ្ញាធរថៃបញ្ជូនមក៕

## នគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ ទទួលពលរដ្ឋខ្មែរ២នាក់ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/ **General Department of Immigration - GDI** March 15 at 3:44 PM

ឧត្តរមានជ័យ៖ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរ០២នាក់ ឲ្យមកនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃដែលចេញតាមច្រកភ្នំខ្មោចខេត្តព្រះវិហារ៕

## ថៃបញ្ជូនពលករខ្មែរ ០៩នាក់ មកឲ្យកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration - GDI **March 15 at 2:56 PM**

បន្ទាយមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត នាវេលាម៉ោង ១៥និង០០នាទី ថ្ងៃទី១៥ ខែមីនា ឆ្នាំ ២០១៩ បានទទួលពលករខ្មែរ ០៩នាក់ ក្នុងនោះស្រី ០២នាក់ ដែលអាជ្ញាធរថៃបញ្ជូនមក៕

## ពលករខ្មែរចំនួន២នាក់ បានរងរបួស និងស្លាប់ ខណៈដែលកំពុងបើកជញ្ជាំងរថយន្តដើម្បី ទម្លាក់សម្ភារៈចុះ ក៏ស្រាប់តែមានដុំដែករមូរបានរមៀលធ្លាក់ពីលើរថយន្តមកសង្កត់តែម្តង

https://www.facebook.com/OfficialPheaktra/ March 15 at 7:40 PM

របាយការណ៍ដែលកម្ពុជាថ្មីទទួលបាន គឺហេតុការណ៍នេះបានកើតឡើងកាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ ២០១៩ វេលាម៉ោង១២និង៣០នាទីថ្ងៃត្រង់ នៅក្នុងរោងចក្រផលិតបន្ទះដែក និង ស័ង្កសី មួយកន្លែង ក្នុងឃុំបាងយ៉ាព្រែក ស្រុកព្រះប្រាក់ដែង ខេត្តសមុទ្រប្រាកាន ប្រទេសថៃ។ របាយការណ៍បានបន្តថា រថយន្តដែលបង្កហេតុនោះម៉ាក អ៊ីស៊ុយស៊ុយ ពណ៌ស ជាប្រភេទរថយន្តសណ្តោង កង់១៨ បើកបរដោយឈ្មោះ ស៊ុំឆាយ ដាវដែរ៉ាំ ដោយគេបានរៀបរាប់ថា នៅមុនពេលកើតហេតុ ខ្លួនបានដឹកដែកបន្ទះ និងដុំដែករមូរ ពីខេត្តឈុនបុរី ឆ្ពោះមកកាន់រោងចក្រនេះ ហើយក៏បានឈប់សំចតក្នុងទីតាំងរោងចក្រ ដើម្បីឲ្យកម្មករមកទម្លាក់សម្ភារៈទាំងនេះ។ លោកក៏បានបន្តថា ភ្លាមៗនោះ លោកសង្កេតឃើញមានកម្មករចំនួន៤នាក់ បានដើរមកបើកគន្លឹះជញ្ជាំងរថយន្ត ផ្នែកកន្ទុយសណ្តោង លុះជញ្ជាំងចំនួន២ផ្ទាំង បានរបើកឡើង ក៏ស្រាប់តែដុំដែករមូរចំនួន២ដុំ បានរមៀលធ្លាក់មក ហើយក៏បានសង្កត់ទៅលើកម្មករចំនួន២នាក់ ដោយម្នាក់ស្លាប់ និងម្នាក់ទៀតរងរបួស។

ពលករខ្មែរទាំង២នាក់នោះ គឺ អ្នកដែលស្លាប់មានឈ្មោះ សុន ភេទប្រុស អាយុ២៣ឆ្នាំ និងអ្នករបួសមានឈ្មោះ វី ភេទប្រុស អាយុ២៤ឆ្នាំ ដោយបានបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្ត សមុទ្រប្រាកានហើយ។ បច្ចុប្បន្នក្រោយពេលកើតហេតុ សមត្ថកិច្ចថៃក៏បានចុះពិនិត្យ ដើម្បីរៀបចំប្រគល់សពទៅឲ្យសាច់ញាតិ ដោយឡែករថយន្ត និងអ្នកបើកបរ កំពុងសាកសួរតាមផ្លូវច្បាប់៕

# ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩

## សម្តេចតេជោ ដាក់ចេញអនុសាសន៍ សំខាន់ៗ១០ចំណុច ដើម្បីជំរុញ ការអនុវត្តការងារ ឲ្យមានប្រសិទ្ធភាព (មានវីដេអូ)

https://www.dap-news.com/ ByID:112 Posted on 20 March 2019 | 11:30

ភ្នំពេញ ៖ ក្នុងឱកាសអញ្ជើញ ជួបសំណេះសំណាល ជាមួយកម្មករ កម្មការិនីប្រមាណ១ម៉ឺននាក់ មកពីរោងចក្រ សហគ្រាសចំនួន៦ នៅខេត្តពោធិ៍សាត់ នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ នេះ សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា បានដាក់ចេញនូវអនុសាសន៍ សំខាន់ៗ១០ចំណុច ដើម្បីជំរុញការអនុវត្តការងារឲ្យមានប្រសិទ្ធភាពខ្ពស់ ។

**អនុសាសន៍សំខាន់ៗទាំង១០ចំណុចនោះរួមមាន៖**

១- ត្រូវអនុវត្តបើកប្រាក់ខែ អប្បបរិមាដល់កម្មករក្នុងឆ្នាំ២០១៩ គឺ១៨២ ដុល្លារ បើក្រុមហ៊ុនផ្តល់ជូនកម្មករលើសនេះ គឺរឹតតែល្អប្រសើរ និងបើកប្រាក់ខែ២ដង ក្នុងមួយខែ។

២- ត្រូវអនុវត្តការចុះពិនិត្យ នៅតាមមន្ទីរពេទ្យរដ្ឋ ចំពោះការពិនិត្យសុខភាព និងការព្យាបាលកម្មករ-កម្មការិនី រោងចក្រ រួមទាំងកីឡាករ-កីឡាការិនី ក្រុមប្រឹក្សាភូមិ-ឃុំ ក៏ត្រូវបានអនុវត្តដូចគ្នាជា ពិសេសរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងក្រសួងការងារត្រូវធ្វើឲ្យបានម៉ត់ចត់។

៣- ត្រូវអនុវត្តចំពោះស្ត្រីមានផ្ទៃ ពោះសំរាលកូន នឹងទទួលបានពេលវេលាឈប់សម្រាក ពីការងាររយៈ ពេល ៣ខែ ហើយទទួលបានប្រាក់ខែ១២០% (៥០% ដោយក្រុមហ៊ុន និង៧០%ដោយបេឡាជាតិ) ក្រសួងពាក់ព័ន្ធត្រូវ តាមដានការងារឲ្យបានជិតដល់ ចំពោះការអនុវត្តសកម្មភាពនេះ ។

៤- ត្រូវអនុវត្តចំពោះកម្មការិនី សម្រាលបានកូន (១) ទទួលថវិកា៤០ម៉ឺនរៀល និងពិនិត្យផ្ទៃពោះដោយឥត គិតថ្លៃ។ បើសម្រាលបានកូនភ្លោះ (២) គឺទទួលបានថវិកា៨០ម៉ឺនរៀល។ បើសម្រាលបានកូន (៣) គឺទទួលបាន ថវិកា១លាន២សែនរៀល ហើយបូកប្រាក់ឧបត្ថម្ភចំនួន៥លានរៀលទៀតពីសម្តេចតេជោ ។ នៅពេលខាងមុខនេះ ចំពោះកម្មការិនីក្រីក្របំផុតនោះ គឺនឹងទទួលបានប្រាក់ឧបត្ថម្ភប្រមាណ៧៦០,០០០៛ (១៩០ដុល្លារ)។

៥- អនុវត្តចំពោះរបបសន្តិសុខសង្គម ដោយចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ កម្មករ-កម្មការិនី មិនចាំបាច់ បង់ទៀតទេ គឺម្ចាស់ក្រុមហ៊ុនជាអ្នកបង់ជំនួស ១០០%។

៦- អនុវត្តតាមដានមើលបញ្ហា ទឹក ភ្លើង គត្រូវខិតខំបន្ត តទឹក តភ្លើងដល់ផ្ទះរបស់កម្មករ។

៧- អនុវត្តប្រាក់សោធននិវត្តន៍ចាប់ពីឆ្នាំ២០១៩ កម្មករនឹងទទួលបានប្រាក់ចូលនិវត្តន៍(ប្រាក់រីត្រែត)ហើយ។

៨- អនុវត្តចូលរួមបន្តយកចិត្តទុកដាក់ និងដោះស្រាយបញ្ហាផ្សេងៗដែលពលករទៅក្រៅប្រទេស ជួយសម្រួល បែបបទលិខិតបទដ្ឋានផ្លូវច្បាប់នានា និងដើម្បីទទួលបាននូវលក្ខខណ្ឌការងារល្អប្រសើរ។

៩- ក្រសួងការងារ ត្រូវចុះអនុវត្តតាមដានភ្លាមៗ ឲ្យបានជិតដល់ និងចូលរួមដោះស្រាយបញ្ហាប្រឈមនានា ចំពោះកម្មករនៅពេលដែលម្ចាស់រោងចក្ររត់ចោល។

១០- ត្រូវបន្តដោះស្រាយជួយពលករដែលកំពុងធ្វើការនៅក្រៅប្រទេសធ្វើយ៉ាងណាឲ្យកម្មករធ្វើការបានស្រប ច្បាប់៕ **ដោយ៖ នឿត សម្ផស្ស**

## នគរបាលជំនាញខេត្តកណ្តាល បង្ក្រាបឃាត់ខ្លួនបុរសម្នាក់ជាម្ចាស់ទីតាំងកោសជប់ម៉ាស្សាម្នាក់ ក្រោយពីមានបង្កប់សេវាកម្មផ្លូវភេទ

http://cambodiapolice.com/policekh/ 10:51 am 20 មីនា 2019

កណ្តាល៖ សមត្ថកិច្ចនគរបាលការិយាល័យជួញដូរ និងការពារអនិតិជន នៃស្នងការដ្ឋាននគរបាលខេត្តកណ្តា ល សហការជាមួយកម្លាំងសមត្ថកិច្ចក្រុងតាខ្មៅ និងប៉ុស្តិ៍តាខ្មៅ ចុះធ្វើការឃាត់ខ្លួន ម្ចាស់ទីតាំងកោសជប់ម៉ាស្សាយីហោដៃប្រសប់១៦៨មួយកន្លែង ក្រោយពីទទួលបានព័ត៌មានថា មានបង្កប់សេវាកម្មផ្លូវភេទ ។ ប្រតិបត្តិការខាងលើនេះ ធ្វើឡើងនៅថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១៩ វេលាម៉ោង២០និង៣០នាទី ស្ថិយក្នុងភូមិព្រែកសំរោង១ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល ។

មន្ត្រីនគរបាលការិយាល័យជួញដូរផ្លូវភេទនិងការពារអនិតិជន នៃស្នងការដ្ឋាននគរបាលខេត្តកណ្តាលបានឲ្យដឹងថា បុរសសង្ស័យជាម្ចាស់ទីតាំងឈ្មោះ កាន់ កាឌី អាយុ៥១ឆ្នាំ បច្ចុប្បន្នស្នាក់នៅកន្លែងកើតហេតុខាងលើ ។ រីឯស្ត្រីរងគ្រោះមានគ្នា៣នាក់ ក្នុងនោះក្មេងស្រីអាយុ១៦ឆ្នាំមានម្នាក់ ។

ប្រភពដដែលបន្តថា ក្រោយពីកម្លាំងសមត្ថកិច្ចជំនាញការិយាល័យជំនាញទទួលបានព័ត៌មានករណីខាងលើរួចមក ភ្លាមនោះកម្លាំងជំនាញខេត្តបាន ធ្វើការសហការជាមួយកំលាំងព្រហ្មទណ្ឌក្រុងតាខ្មៅ និងនគរបាលប៉ុស្តិ៍តាខ្មៅ និងអាជ្ញាធរភូមិសង្កាត់ ចុះធ្វើការបង្ក្រាប ដែលដឹកនាំដោយលោកវរសេនិយ៍ឯក រស់ សារិន ប្រធានការិយាល័យនិងអង្គការមេត្រីអន្តរជាតិ បានធ្វើការឆែកឆេររកឃើញវត្ថុតាងស្រោមអនាម័យមួយចំនួន ឈានដល់ឃាត់ខ្លួនជនសង្ស័យជាម្ចាស់ទីតាំងខាងលើ យកមកស្នងការដ្ឋាននគរបាលខេត្ត ដើម្បីចាត់ការតាមនិតិវិធី ។

## ថៃបញ្ជូនពលករខ្មែរ ១៣នាក់ មកឲ្យកម្ពុជាវិញ

https://www.facebook.com/ General Department of Immigration – GDI 18-03-2019

បន្ទាយមានជ័យ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិប៉ោយប៉ែត នាវេលាម៉ោង ១៥និង០០នាទី ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរ ១៣នាក់ ក្នុងនោះស្រី ០៦នាក់ ដែលអាជ្ញាធរថៃបញ្ជូនមក៕

# ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩

## ថៃបញ្ជូនពលករខ្មែរ ៤៥នាក់ មកឲ្យកម្ពុជាវិញ តាមច្រកទ្វារអន្តរជាតិ ប៉ោយប៉ែត

https://www.dap-news.com/ ByID:112 Posted on 20 March 2019 | 16:46

ភ្នំពេញ៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិ ប៉ោយប៉ែត នាវេលាម៉ោង ១៥ និង០០នាទី ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរ ៤៥នាក់ ក្នុងនោះស្រី ១៤នាក់ និងកុមារ ០៥នាក់ ដែលអាជ្ញាធរថៃបញ្ជូនមក ។ នេះបើយោងតាមអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ៕

## ឃាត់ ខ្លួន លករ ខ្មែរខុសច្បាប់ ០៦នាក់ ចុះទៅយកប៉ាស្ព័រធ្វើការ MOU នៅព្រំដែន

https://www.facebook.com/ By Pheaktra Prak 20/03/2019

ប្រទេស ថៃ ៖យោងតាមរបាយការណ៍ពីកម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ ប្រចាំច្រកទ្វាព្រំដែនអន្តរជាតិខ្លងឡឹក ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ បានអោយដឹងថា កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ កន្លងទៅកម្លាំងអន្តោប្រវេសន៍ បានធ្វើការឃាត់ខ្លួនពលករខ្មែរខុសច្បាប់ចំនួន០៦នាក់ ខណៈពេលកំពុងឈរវេងចាំអ្វីម្យ៉ាងក្នុងអាគារច្រកចេញចូលព្រំដែនអន្តរជាតិខាងថៃ សមត្ថកិច្ចថៃបានចូលទៅសាកសួរអំពីលិខិតឆ្លងដែន និងប័ណ្ណអនុញ្ញាតធ្វើការនៅក្នុងប្រទេសថៃ ប៉ុន្តែពលករទាំងអស់មិនមានសមត្ថកិច្ចថៃ បាននាំពលករទាំងអស់យកទៅធ្វើការសាកសួរនៅអធិការដ្ឋានតម្រួតអន្តោប្រវេសន៍ ទើបដឹងថាពលករទាំងអស់ជាពលករខុសច្បាប់ ។

តាមចម្លើយសារភាពរបស់ពលករទាំងអស់បានប្រាប់អោយដឹងថា ពួកគេបានឆ្លងដែនខុសច្បាប់ចូលមកធ្វើការក្នុងប្រទេសថៃ អស់រយៈពេលជាច្រើនខែមកហើយ ដោយបានទំនាក់ទំនងក្រុមហ៊ុនរត់ការធ្វើឯកសារMOUខាង ខ្មែរ ធ្វើឯកសារស្របច្បាប់ អោយហើយខាងក្រុមហ៊ុនបានណាត់ពួកគាត់អោយមកទទួលប៉ាស្ព័រនៅកន្លែងណាត់ខាងលើ តែក៏ត្រូវសម្ថកិច្ចថៃឃាត់ខ្លួនបានមុនទទួលប៉ាស្ព័រ ។

បច្ចុប្បន្នពលករខុសច្បាប់ទាំងអស់ត្រូវបានសមត្ថកិច្ចថៃ កសាងសំណុំរឿងដើម្បីចាត់វិធានការណ៍តាមនិតិវិធីច្បាប់ ។

## វៀតណាមបញ្ជូនពលរដ្ឋខ្មែរ ១៥នាក់ មកឲ្យកម្ពុជាវិញ ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/ **General Department of Immigration - GDI 20-03-2019**

ស្វាយរៀង៖ កម្លាំងស្នងការដ្ឋាននគរបាលខេត្ត ផែនអន្តោប្រវេសន៍ នារសៀលថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ បានសហការជាមួយកម្លាំងអធិការដ្ឋាននគរបាលស្រុកកំពង់រោទិ៍ មន្ទីរសង្គមកិច្ចខេត្ត និងកម្លាំងនគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រៃវល្លិ៍ បានទៅទទួលប្រជាពលរដ្ឋខ្មែរ ០៨គ្រួសារ មនុស្សចំនួន ១៥នាក់ ស្រី ១៣នាក់ ដែលឆ្លងដែនខុសច្បាប់ ទៅរកស៊ីលក់ឆ្នោតនៅប្រទេសវៀតណាម ហើយត្រូវភាគីវៀតណាម ចាប់បញ្ជូនមកកម្ពុជាវិញ។ កម្លាំងការិយាល័យជំនាញ បានធ្វើការអប់រំ ដោយមានកិច្ចសន្យា និងឲ្យត្រឡប់ទៅផ្ទះវិញរៀងៗខ្លួន៕

## ពលករខ្មែរ ស្លាប់នៅថៃ គ្មានលុយដឹកសពមកធ្វើបុណ្យនៅប្រទេសកំណើត

http://www.cambodiawikinews.com/archives/ March 20, 2019 Cambodiawikinews

ពាក្យថាពលករ គឺពិតជាមិនមានភាពងាយស្រួលនោះទេ ដោយសារតែតម្រូវឲ្យយើងត្រូវឃ្លាតចាកឆ្ងាយពីប្រទេសកំណើត ទៅធ្វើការនៅឯក្រៅប្រទេស មួយវិញទៀតនោះ សូម្បីតែការទំនាក់ទំនងគ្នា ក៏មានការពិបាក ទាំងការរស់នៅ និងការធ្វើដំណើរ ដើម្បីតស៊ូប្រឹងប្រែងរកលុយ ជួយដល់គ្រួសារផងនោះ។ដោយឡែក កាលពីពេលថ្មីៗនេះ ពលករនៅប្រទេសថៃម្នាក់ បានស្លាប់បាត់បង់ជីវិត ដោយសារតែមានជំងឺខួរឆ្អឹងធ្ងន់ធ្ងរ គ្មានលុយធ្វើការព្យាបាល និងដឹកសពមកស្រុកកំណើតវិញនោះទេ។ ដែលនេះគឺជាការទទួលបានតាមរយៈគណនីហ្វេសបុកផេកឈ្មោះ CWC Media សហគមន៍ពលករ បានធ្វើការរៀបរាប់ថា៖ ពលករខ្មែរ ស្លាប់នៅថៃ គ្មានលុយដឹកសពធ្វើបុណ្យនៅស្រុក តាមការបង្ហោះពី មិត្តភក្តិរបស់សព ម្សិលមិញបានអោយដឹងថា ពលកររូបនេះ មានជំងឺខួរឆ្អឹងធ្ងន់ធ្ងរ គ្មានជានារ៉ាប់រង ថ្លៃវះកាត់រាប់សែនបាត បានស្លាប់ និងសពយកធ្វើបុណ្យនៅវត្តផាតាយ៉ា ។

## ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩

## បញ្ជូនម្ចាស់ហាងម៉ាស្សា បង្កប់សេវាផ្លូវភេទទៅតុលាការ

https://m.postkhmer.com/ គឹម សារុំ 22 March 2019 | 07:44 ICT

**កណ្ដាល:** ជនសង្ស័យម្នាក់ដែលបើកទីតាំងម៉ាស្សាបង្កប់សេវាផ្លូវភេទ ត្រូវនគរបាលប្រឆាំងការជួញដូរមនុស្សខេត្តកណ្ដាលបញ្ជូនទៅសាលាដំបូងខេត្តកាលពីម្សិលមិញបន្ទាប់ពីឃាត់ខ្លួននៅភូមិព្រែកសំរោង សង្កាត់-ក្រុងតាខ្មៅ ខេត្តកណ្ដាលកាលពីថ្ងៃទី ១៩ មីនា។

លោកស្រី ឈឹម វណ្ណនី ស្នងការ រងទទួលផែនប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តកណ្ដាលបានប្រាប់ភ្នំពេញប៉ុស្ដិ៍ពីម្សិលមិញថា ករណីជនសង្ស័យម្នាក់ឈ្មោះ កាន់ កាឌី អាយុ ៥១ ឆ្នាំ និងជាម្ចាស់ទីតាំងម៉ាស្សានោះសមត្ថកិច្ចជំនាញរបស់លោកស្រីបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តកណ្ដាលនៅថ្ងៃ (ថ្ងៃទី ២១ មីនា) នេះ។ លោកស្រី បានឲ្យដឹងថា ការបញ្ជូនជនសង្ស័យទៅតុលាការដើម្បីប្រឈមនឹងច្បាប់នេះគឺក្រោយពីសមត្ថកិច្ចបានសាកសួររួចហើយករណីនេះជនសង្ស័យបានសារភាពថា បានពាក់ព័ន្ធនឹងសកម្មភាពនេះ។ លោកស្រីបញ្ជាក់ថា៖ «ក្នុងអំពើជួញដូរនេះគឺមានតែជនសង្ស័យម្នាក់ទេ រីឯនារីរងគ្រោះ ៦ នាក់មានអ្នកខ្លះអាយុក្រោម ១៨ ឆ្នាំនិងអ្នកខ្លះលើស ១៨ ឆ្នាំយើងបានបំពេញនីតិវិធីប្រគល់ពួកគេឲ្យខាងមន្ទីរសង្គមកិច្ចខេត្តកណ្ដាលហើយ»។ លោកស្រី ឈឹម វណ្ណនី បានរំឭកប្រាប់ថា កាលពីថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៩ នៅវេលាម៉ោងប្រមាណ ៨ កន្លះយប់ កម្លាំងសមត្ថកិច្ចរបស់ស្នងការដ្ឋាននគរបាលខេត្តកណ្ដាលផែនបង្ក្រាបបទល្មើសជួញដូរបានចុះប្រតិបត្តិការបង្ក្រាបទីតាំងម៉ាស្សាកោសជប៉ុនមួយកន្លែងដែលមានឃីហោថាម៉ាស្សាដៃប្រសប់ ១៦៨ ស្ថិតក្នុងភូមិកើតហេតុខាងលើ។

ក្នុងប្រតិបត្តិការនោះសមត្ថកិច្ចបានឆែកឆេរក្នុងផ្ទះម៉ាស្សានិងប្រមូលបាននារីរងគ្រោះចំនួន ៦ នាក់ជាមួយវត្ថុតាងស្រោមអនាម័យប្រើរួចនិងមិនទាន់ប្រើបានមួយចំនួន និងឃាត់ខ្លួនបុរសសង្ស័យដែលជាម្ចាស់ទីតាំងម៉ាស្សាបានម្នាក់៕

# មិនគួរឡើយ! ម្តាយនិងកូនរួមគំនិតគ្នាប្រើល្បិចលើនារីម្នាក់ឱ្យនៅជាមួយភ្ញៀវបន្តបន្ទាប់

https://kohsantepheapdaily.com.kh/article/ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៩ ម៉ោង ០៩:៤១ ប៊ឹង ធដា

ខេត្តកណ្តាល ៖ ជនសង្ស័យ២នាក់ម្តាយ និងកូនបានរួមគំនិតគ្នាល្បួងនារីម្នាក់ឱ្យទៅធ្វើការនៅផ្ទះខ្លួន រួចប្រើល្បិចហៅភ្ញៀវមករួមភេទជាមួយនារីរងគ្រោះ ហើយបន្តល្បួងនារីរងគ្រោះយកទៅដើរឱ្យដេកជាមួយភ្ញៀវតាមខេត្តទើបបែកធ្លាយត្រូវនគរបាលស្រុកកៀនស្វាយចាប់ខ្លួន។ ហេតុការណ៍នេះកើតឡើងកាលពីម៉ោង៧យប់ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ នៅចំណុចភូមិស្ពានដែក ឃុំព្រែកទន្លាប់ ស្រុកលើកដែក ខេត្តកណ្តាល ។

ជនសង្ស័យ២នាក់ម្តាយកូនខាងលើ ១-ឈ្មោះ អួន សារ៉ន ភេទស្រី អាយុ៦១ឆ្នាំ មុខរបរគ្រូទាយ មានទីលំនៅភូមិស្ពានដែក ឃុំព្រែកទន្លាប់ ស្រុកលើកដែក ខេត្តកណ្តាល ២-ឈ្មោះ ឡេង សាវន ភេទស្រី អាយុ៣១ឆ្នាំ មុខរបរកម្មករតុការ មានទីលំនៅភូមិស្ពានដែក ឃុំព្រែកទម្លាប់ ស្រុកលើកដែក ខេត្តកណ្តាល ចំណែកនារីរងគ្រោះអាយុ២៨ឆ្នាំជាអ្នកលក់ដូ មានទីលំនៅក្នុងស្រុកកៀនស្វាយ។

នគរបាលស្រុកកៀនស្វាយឱ្យដឹងថា នៅថ្ងៃទី១៨ មីនា ម៉ោង៨និង១៥នាទីព្រឹកស្ត្រីជនសង្ស័យជាគ្រូទស្សន៍ទាយអាយុ៦១ឆ្នាំបានជិះឡានតាក់ស៊ីមកទស្សន៍ទាយឲ្យនារីរងគ្រោះថា ចុងខែ៣ដើមខែ៤នេះមានគ្រោះថ្នាក់ដល់ខ្លួនបើចង់ផុតគ្រោះគេចខ្លួនចេញពីផ្ទះសិនទៅ បើចង់ធ្វើការងារអ៊ំទុកលេខទូរស័ព្ទឲ្យទាក់ទង ។ ក្រោយពីទស្សន៍ទាយរួចរាល់ស្ត្រីនោះក៏ជិះឡានតាក់ស៊ីត្រឡប់ទៅផ្ទះវិញ។ លុះដល់ថ្ងៃទី១៩ មីនា ម៉ោង៣និង២៥នាទីរសៀល នារីរងគ្រោះបានជិះឡានឈ្នួលទៅស្នាក់នៅផ្ទះរបស់ស្ត្រីសង្ស័យជាគ្រូទាយ។ នគរបាលស្រុកបន្តថា លុះដល់ម៉ោង៧យប់ស្ត្រីដែលត្រូវជាកូនស្រីរបស់ស្ត្រីជាគ្រូទាយបានទូរស័ព្ទហៅប្រុសម្នាក់ឲ្យមកដេកជាមួយនារីរងគ្រោះនៅផ្ទះស្ត្រីជនសង្ស័យនោះតែម្តង ដោយបុរសនោះឲ្យប្រាក់ទៅនារីរងគ្រោះចំនួន៥០.០០០រៀលជាថ្លៃដេករួមភេទ រួចបុរសនោះក៏ចេញទៅបាត់ទៅ ។ លុះដល់ថ្ងៃទី២០ មីនា ម៉ោង៦និង៣០នាទីព្រឹកស្ត្រីជនសង្ស័យជាគ្រូទាយបានជិះឡានឈ្នួលនាំនារីរងគ្រោះទៅដេករួមភេទជាមួយតាចាស់ម្នាក់នៅផ្ទះសំណាក់ ផ្លូវបំបែកគោដេកបី ទីរួមខេត្តស្វាយរៀង ប៉ុន្តែពេលនោះតានោះសួរថា «អ្ហែងធ្លាប់រកស៊ីអញ្ចឹងអត់» នារីរងគ្រោះឆ្លើយថា «ខ្ញុំមិនធ្លាប់រកស៊ីអញ្ចឹងទេ» រួចតានោះមិនដេកជាមួយនារីរងគ្រោះឡើយ ដោយឲ្យប្រាក់ចំនួន១០០.០០០រៀលទៅនារីរងគ្រោះត្រលប់ទៅផ្ទះវិញ។

នគរបាលស្រុកបន្តទៀតថា ពេលនោះនារីរងគ្រោះឲ្យលុយចំនួនពីរម៉ឺនរៀលទៅស្ត្រីសង្ស័យជាគ្រូទាយ រួចក៏នាំនារីរងគ្រោះជិះឡានឈ្នួលត្រលប់មកផ្ទះខ្លួនវិញ ។ លុះដល់ម៉ោង១០និង១០នាទីយប់ ស្ត្រីជាកូនស្ត្រីគ្រូទាយនិយាយថា « ថ្ងៃនេះគ្មានលុយបង់អង្គការទេអញ រកម៉ូយឲ្យដេកជាមួយនារីរងគ្រោះ ដើម្បីយកលុយបង់អង្គការ ។ ពេលនោះនារីរងគ្រោះបានតេទូរស័ព្ទប្រាប់បងជីដូនមួយ២នាក់ឲ្យមកយកខ្លួនចេញពីផ្ទះស្ត្រីជាគ្រូទាយត្រលប់មកផ្ទះវិញ ។ នគរបាលបន្តថា លុះដល់ថ្ងៃទី២១ មីនា ម៉ោង១១និង៣០នាទីព្រឹក នារីរងគ្រោះបានមកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលរដ្ឋបាលសំរោងធំ ក្រោយពីទទួលបានពាក្យបណ្តឹងកម្លាំងប៉ុស្តិ៍សហការជាមួយផ្នែកជំនាញ និងកម្លាំងនគរបាលស្រុកលើកដែក នាំខ្លួនជនសង្ស័យទាំង២នាក់ខាងលើមកអធិការដ្ឋាននគរបាលស្រុកកៀនស្វាយ ដើម្បីបន្តចាត់ការតាមនីតិវិធី៕

# ពលករខ្មែរធ្វើការរោងចក្រក្នុងខេត្តឈុនបុរីជាង ៥០នាក់ បណ្តឹងស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ឲ្យជួយអន្តរាគមន៍

http://www.pheaktraofficial.com/ 2019/03/22 By Pheaktra Prak

ប្រទេសថៃះបន្ទាប់ពីទទួលបានយពាក្យបណ្តឹងពីពលករខ្មែរចំនួន ៥២នាក់និងកូមាចំនួន ៤៤នាក់ កំពុងធ្វើការនៅក្នុងរោងចក្រTatungរបស់ក្រោមការគ្រប់ពីក្រុមហ៊ុន ABM Group and Supply Co. , Ltd បានរាយការណ៍មក

កាន់ស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ កាលពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩ កកន្លងទៅមន្រ្តីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ ធ្វើការបានចុះអន្តរាគមន៍ ដដល់រោងចក្រកន្លែងហេតុភ្លាមៗ ។ក្នុងប្រតិបត្តិការ ចុះអុះអន្តរាគមន៍តាមពាក្យបណ្តឹងពីពលករខ្មែរធ្វើការក្នុងរោងចក្រខាងលើនេះ មន្រ្តីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជា បបបានបានធ្វើការចរចាររកដំណោះស្រាយជាមួយភាគីខាងក្រុមហ៊ុនABMGroup and Supply Co. , Ltd. ដោយខាងភាគីក្រុមហ៊ុនABMGroup and Supply Co. , Ltd. បាបានយល់តាមសំណើររបស់មន្រ្តីទីប្រឹក្សាពលករនិងតំណាងពលករ ដោយព្រមបើកប្រាក់ឈ្នួលដែលពលករបានធ្វើការទាំងអស់ជូននៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ និងប្រាក់ដែលក្រុមហ៊ុនកាតថ្លៃដំណើរការនីតិវិធីអោយស្របច្បាប់ក្នុងម្នាក់ៗ៨០០០បាត-១០០០០បាត នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៩ខាងមុខនៅក្នុងក្រុមហ៊ុនខាងលើ។ លុះដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ ខាងភាគីក្រុមហ៊ុន ABMGroup and Supply Co. , Ltd. បានបងបានបង្វែរកន្លែងបើកប្រាក់ឈ្នួលជូនពលករទាំងអស់ នៅទីស្នាក់ការពន្លត់អគ្គិភ័យ ម៉ុំគីឡូម៉ែត្រ ១៤ក្នុងខេត្តឈុនបុរី ដោយមិនបានជូនដំណឹងដល់ក្រុមមន្រ្តីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ និងពលករដែលមកចូលដោះស្រាយរឿងនេះអោយដឹងមុនឡើយ ក្នុងក្នុងការបើកប្រាក់ឈ្នួលជូនពលករតាមសន្យានេះ របស់ក្រុមហ៊ុនABMGroup and Supply Co. , Ltd. ននេះនៅពេលបើកប្រាក់ជូនពលករក្រុមហ៊ុន គ្មានវិក្កយបត្របញ្ជាក់អំពីទឹកប្រាក់ ដែលពលករត្រូវបានរូវបានទទួលយ៉ាងច្បាស់លាស់ឲ្យពលករដឹងនោះទេ ព្រមព្រមទាំងគ្មានការចូលរួមពីសង្កេតការណ៍សំណាក់អាជ្ញាធរមានសមត្ថកមត្ថកិច្ចក្នុងមូលដ្ឋានដែលមកចូលចរចារទៀតផង។

ជាងនេះទៅទៀតមានពលករខ្លះទទួលបានប្រាក់ឈ្នួល តាមតែក្រុមហ៊ុនអោយ ខ្លះ៥០០បាត ខ្លះទៀត ១០០០បាត ហើយសម្រាប់ពលករដែលមានគណនីធនាគារ ខាងក្រុមហ៊ុនបានប្រាប់ថា ខាងក្រុមហ៊ុនផ្ទេរប្រាក់តាមគណនីធនាគារទៅហើយ តែនៅពេលពលករទៅឆែកនៅទូATMបែរជាគ្មានទឹកប្រាក់ចូលក្នុងគណនីរបស់ពួកគេទៅវិញ ដោយខាងក្រុមហ៊ុនអាងលុយចូលនៅថ្ងៃស្អែកវិញ។ លើសពីនោះទៅទៀតមានពលករខ្លះរងការគំរាមកំហែងដដែលគេអាងនិងថាបណ្តឹងតម្រួតអន្តោប្រវេសន៍ អោយចាប់ខ្លួនផងដែរ ។ បនបន្ទាប់មកទៀតខាងភាគីក្រុមហ៊ុន ABMGroup and Supply Co. , Ltd.បាននរឺលែត្រឡប់ចេញពីកន្លែងបើកប្រាក់ឈ្នួលជូនពលករ យ៉ាងលឿនបមកទាន់ឃើញមន្រ្តីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ មកដល់កន្លែងបើកលុយដោយគ្មានការចរាចរណាមួយរវាងប្រាក់ដែលត្រូវបើកជូនពលករនៅចុងខែមុខទៀតនោះឡើយ បន្ទាប់ពីបានឃើញហេតុការណ៍មិនប្រក្រតីដូច្នេះ មន្រ្តីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ បានធ្វើការទំនាក់ទំនងទៅសមត្ថកិច្ចតម្រួតខេត្តឈុនបុរី អោយជួយអន្តរាគមន៍ធ្វើជាសាក្សី ក្នុងការបើកប្រាក់ឈ្នួលអោយពលករលើកនេះ ភ្លាមៗនោះសមត្ថកិច្ចតម្រួតមូលដ្ឋានក្នុងខេត្តឈុនបុរី បានមកដល់កន្លែងកើតហេតុ ព្រមទាំងអញ្ជើញមន្រ្តីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ និងតំណាងពលករកម្ពុជាព្រមទាំងភូមាទៅកាន់អធិការដ្ឋាស្នងការតម្រួតខេត្ត ដើម្បីរកវិធានការដោះស្រាយនិងចរចានៅវគ្គបើកលុយលើកក្រោយទៀត ដោយខាងសមត្ថកិច្ចតម្រួតខេត្តឈុនបុរី បានធ្វើការទំនាក់ទំនងកោះហៅតាមទូរស័ព្ទកោះហៅខាងភាគីខាងក្រុមហ៊ុន ABMGroup and Supply Co. , Ltd.ជាច្រើនលើក តែខាងភាគីក្រុមហ៊ុន មិនព្រមចូលខ្លួនមកដោះស្រាយសោះ។ បន្ទាប់មកទៀតខាងសមត្ថកិច្ចតម្រួតស្នងការខេត្តឈុនបុរី បានណែនាំនីតិវិធីបន្តឲ្យ មន្រ្តីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ ទៅដាក់ពាក្យបណ្តឹងនៅអធិការដ្ឋានស្នងការតម្រួត ជនហ្លួរក្នុងតំបន់កើតហេតុ បន្ទាប់ពីបានទទួលការងារណែនាំពីសំណាក់អាជ្ញាធរស្នងការតម្រួតខេត្តឈុនបុរី មន្រ្តីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ បាននាំតំណាងពលករកម្ពុជានិងភូមាបន្តដំណើរទៅដាក់ពាក្យបណ្តឹងនៅអធិការដ្ឋានស្នងការតម្រួតជនហ្លួរឡ ទាំងយប់ ដើម្បីសុវត្ថិភាពរបស់ពលករទាំងអស់ ។

បន្ទាប់ពីដាក់ពាក្យបណ្តឹងរួចរាល់អាជ្ញាធរតម្រួតស្នងការជនហ្លួរឡ បានប្រគល់លិខិតពាក្យបណ្តឹងចំនួនពីរច្បាប់ដល់តំណាងពលករ និងមន្រ្តីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ ដើម្បីធ្វើជាភស្តុតាង។ លុះដល់ព្រឹកថ្ងៃទី២១ខែមីនា ឆ្នាំ២០១៩ មន្រ្តីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ បានទទួលដំណឹងពីពលករ

ថាមានសមត្ថកិច្ចអន្តោប្រវេសន៍ ក្នុងខេត្តឈុនបុរី បានឃាត់ខ្លួនពលករខ្មែរចំនួន០២នាក់ ក្នុងចំណោមពលករ៥២នាក់ យកទៅអធិការដ្ឋានស្នងការតម្រួតអន្តោប្រវេសន៍ ស្រុកស៊ីពាធា ខេត្តឈុនបុរី ។ បន្ទាប់ពីបានទទួលដំណឹងពីពលករ ក្រុមមន្ត្រីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ បានចុះអន្តរាគមន៍ដល់អធិការដ្ឋានស្នងការតម្រួតអន្តោប្រវេសន៍ស្រុកស៊ីពាធាខេត្តឈុនបុរី ព្រមទាំងសារព័ត៌មានថៃ ដែលមកចូលរួមសង្កេតការផងដែរ បន្ទាប់មកទៀតមន្ត្រីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ តំណាងអោយឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ បានធ្វើការចរាចរជាមួយសមត្ថកិច្ចតម្រួតអន្តោប្រវេសន៍ស្រុកស៊ីពាធា ដើម្បីសុំខ្លួនពលករដែលត្រូវអាជ្ញាធរអន្តោប្រវេសន៍ ចាប់ខ្លួនកាលពីព្រឹកមិញនោះ យកទៅធ្វើការដោះស្រាយដើម្បីទាមទារប្រាក់ឈ្នួលដែលនៅសេសសល់ពីខាងភាគីក្រុមហ៊ុន ABMGroup and Supply Co. , Ltd.អោយរួចរាល់សិន និងជំរុញឲ្យពលករវិលត្រឡប់ទៅស្រុកកំណើតវិញ។ ក្នុងនោះមន្ត្រីទីប្រឹក្សាទទួលបន្ទុកពលករកម្ពុជាប្រចាំប្រទេសថៃ តំណាងអោយឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃ លោក May Canvisal បានផ្តល់បទសម្ភាសន៍ដល់សារព័ត៌មានថៃដែលមកចូលសង្កេតការណ៍លើកនេះ ព្រមទាំងសង្កត់ធ្ងន់ៗថា លោកនិងលើកបញ្ហាដែលក្រុមហ៊ុន ABMGroup and Supply Co. , Ltd. កេងប្រវ័ញ្ចប្រាក់ឈ្នួលពលករខ្មែរលើកនេះ ទៅពិក្សានៅក្នុងកិច្ចប្រជុំកំពូលជាមួយក្រសួងការងារថៃ ដើម្បីទប់ស្កាត់បញ្ហាដែលកើតមានឡើងដូចក្រុមហ៊ុនខាងលើនេះខាងតទៅទៀត។

## ថៃបញ្ជូនពលរដ្ឋខ្មែរម្នាក់ មកឲ្យកម្ពុជា ពីបទឆ្លងដែនខុសច្បាប់

https://www.facebook.com/ **General Department of Immigration - GDI 22-03-2019**

ឧត្តរមានជ័យ៖ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ខាងភាគីថៃបានបញ្ជូនពលរដ្ឋខ្មែរម្នាក់ មកឲ្យកម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារអន្តរជាតិជាំ ពីបទឆ្លងដែនខុសច្បាប់ទៅកាប់ឈើនៅប្រទេសថៃ ដែលចេញតាមច្រកអូរស្មាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕

## ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩

## សូមសម្តេចក្រឡា ហោម សរខេង មេត្តាជួយពិនិត្យមើលផង មេឈ្មួញឈើឆ្លងដែននៅតំបន់នគរបាលវរៈការពារព្រំដែន៧០២ បង្ករឡើងដោយឈ្មោះឈឿងសក្ក័ ពលរដ្ឋរងគ្រោះឥតល្ហែ

https://www.facebook.com/ksnwebnews/ សារព័ត៌មាននិស្សិតខ្មែរ March 23 at 12:38 PM

ខេត្តឧត្តរមានជ័យ: នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩នេះមានសេចក្តីរាយការណ៍ពីសង្កាត់អូរស្មាច់ក្រុងសំរោង ខេត្តឧត្តរមានជ័យមកថា មេឈ្មួញឈើប្រណិត និងគៀគពលករឆ្លងដែនផ្តាច់មុខនៅតំបន់នគរបាលវរ:ការពារព្រំដែនគោកលេខ៧០២ ឈ្មោះ ឈឿង សក្ក័ នៅតែបន្តរធ្វើសកម្មភាពយ៉ាងអនាធិបតេយ្យ។

កាលពីខែកុម្ភៈកន្លងទៅថ្មី នេះមានពលករប្រមាណជិត១០នាក់ ត្រូវបានសម្តកិច្ចថៃចាប់ឃាត់ខ្លួន យកទៅផ្តន្ទាទោសតាមច្បាប់ប្រទេសថៃ។ ដែលពលករឆ្លងដែនកាប់ឈើប្រណិតទាំងនោះ ដែលសមត្ថកិច្ចថៃចាប់ខ្លួន សុទ្ធសឹងតែជាប់ពាក់ពន្ធ័និងសាជាតុញាន ដែលបង្ខក់ដោយមេឈ្មួញឈើទុច្ចរិតមួយចំនួន ដែលកំពុងតែរកស៊ី នៅតំបន់នគរបាលវរ:ការពារព្រំដែនគោក៧០២ គ្រប់គ្រងដោយ លោក វរ:សេនីយ៍ឯក គង់សុខាន់។ ទោះជាមេឈ្មួញឈ្មោះ ឈឿង ស័ក្ក ជាដើមហេតុនិងជាមូលហេតុ នៃការចាប់ខ្លួនពលករឆ្លងដែន ពីសំណាក់អាជ្ញាធរថៃយ៉ាងណាក៏ដោយ ក៏កងកំលាំងនគរបាលវរ:ការពារព្រំដែនគោកលេខ៧០២ លោកវរសេនីយ៍ឯក គង់ សុខាន់ នៅតែមិនអាចរារាំងរឺក៏បង្អាក់សកម្មភាពបទល្មើសឈើឆ្លងដែន ឈ្មោះ ឈឿង សក្ក័ បានដែ សង្ស័យត្រូវដងត្រូវផ្លែគ្នាហើយមើលទៅ។ ដោយសារតែបទល្មើសកើតឡើងអត់ឈប់ឈរ និងពលរដ្ឋរងគ្រោះត្រូវបានយោធាថៃចាប់ខ្លួន និងទទួលរងគ្រោះដោយបង្ខក់ប្រើប្រាស់គ្រឿងញានផងនោះ។

ពលរដ្ឋសូមអំពាវនាវ ទៅដល់ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃសម្តេចក្រឡាហោម សរ ខេង អោយជួយមេត្តាពិនិត្យមើលនិងចាត់វិធានការផងទាន? ព្រោះមន្ត្រីថ្នាក់ក្រោមអសកម្មអស់ហើយ មិនបានការពារសន្តិសុខជូនប្រជាពលរដ្ឋ ទេការពារតែប្រយោជន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ បើសម្តេចមិនជួយលុបបំបាត់បទល្មើសឈើឈ្មោះ ឈឿង សក្តិ អោយបានទាន់ពេលវេលាទេនោះមិនដឹងថានិងមានពលរដ្ឋប៉ុន្មាននាក់ទៀតនិងត្រូវរងគ្រោះនោះទេ បើពឹងផ្អែកលើមន្ត្រីគ្រប់ល្ពៅ ប្រជារាស្ត្រនិងទទួលរងគ្រោះជាបន្តបន្ទាប់ហើយ៕

## កម្ពុជា-ជប៉ុន ចុះអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ បញ្ជូនពលករជំនាញ

http://www.mlvt.gov.kh/ Monday, 25 March 2019 20:07

(តូក្យូ-ជប៉ុន)៖ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកឧត្តម Takashi YAMASHITA រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃប្រទេសជប៉ុន អញ្ជើញជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈស្តីពីកិច្ចសហប្រតិបត្តិការបញ្ជូនពលករជំនាញ រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ នៅក្រសួងយុត្តិធម៌ ប្រទេសជប៉ុន។ ពិធីចុះហត្ថលេខានេះ ធ្វើឡើងរវាងឯកឧត្តម សេង សក្កា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងលោកជំទាវ Shoko SASAKI អគ្គនាយកអន្តោប្រវេសន៍ជប៉ុន។ ឯកឧត្តម Takashi YAMASHITA រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃប្រទេសជប៉ុន បានលើកឡើងថា កាលពីឆ្នាំកន្លងទៅ កម្ពុជា-ជប៉ុន បានប្រារព្ធពិធីអបអរសាទរខួបលើកទី៦៥នៃទំនាក់ទំនងការទូតកម្ពុជាជប៉ុន ហើយការចុះអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការស្តីពីពលករជំនាញនាថ្ងៃនេះ ជាភស្តុតាងបញ្ជាក់យ៉ាងច្បាស់ ពីទំនាក់ទំនងដ៏ស្អិតរមួត រវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំថែមទៀត ។ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង បានសម្តែងនូវការកោតសរសើរ ចំពោះក្រុមការងារបច្ចេកទេសនៃប្រទេសទាំងពីរ កម្ពុជា-ជប៉ុន ដែលបានខិតខំសហការគ្នា ប្រកបដោយការទទួលខុសត្រូវខ្ពស់ នាពេលកន្លងមករហូតឈានដល់ការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ។ ឯកឧត្តមរដ្ឋមន្ត្រី អ៊ិត សំហេង មានប្រសាសន៍លើកឡើងថា បច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជាកំពុងរស់នៅ សិក្សា និងធ្វើការនៅប្រទេសជប៉ុនមានចំនួនប្រមាណ១ម៉ឺន១ពាន់នាក់ ក្នុងនោះកម្មសិក្សាការីមានប្រមាណជិត៧ពាន់នាក់។

តាមរយៈអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការនេឯកឧត្តមបញ្ជាក់ថា ពលករជំនាញកម្ពុជានឹងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចាប់យកឱកាសមាសនេះ ដើម្បីជាផលប្រយោជន៍សម្រាប់ខ្លួនឯងផង សម្រាប់កម្ពុជាផង ក៏ដូចជាចូលរួមចំណែកដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មរបស់ជប៉ុន ជាពិសេសសម្រេចឱ្យបាននូវចក្ខុវិស័យគ្រប់ជ្រុងជ្រោយជាយុទ្ធសាស្ត្រនៃប្រទេសទាំងពីរ។ រដ្ឋាភិបាលជប៉ុនបានធ្វើវិសោធនកម្មច្បាប់ស្តីពីការទទួលជនភៀសខ្លួន និងការគ្រប់គ្រងជនអន្តោប្រវេសន៍ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៨ ដោយបង្កើតទិដ្ឋាកាការងារថ្មីចំនួន២ប្រភេទគឺ "ពលករជំនាញ១" និង "ពលករជំនាញ២"។ ច្បាប់នេះនឹងចាប់ផ្តើមអនុវត្តនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩។

ដោយឡែកប្រព័ន្ធបញ្ជូនកម្មសិក្សាការីនៅអនុវត្តដដែល។ ជប៉ុនគ្រោងទទួលយកពលករជំនាញទាំង ២ ប្រភេទ ពីប្រទេសចំនួន៨ រួមមាន កម្ពុជា ចិន វៀតណាម ហ្វីលីពីន ឥណ្ឌូនេស៊ី ថៃ មីយ៉ាន់ម៉ា និងនេប៉ាល់ ចំនួន៣៤៥,១៥០នាក់ ក្នុងរយៈពេល៥ឆ្នាំដំបូងក្នុងនោះ៖ ពលករជំនាញសម្រាប់ការងារចំនួន១៤ប្រភេទ រួមមានផ្នែកថែទាំមនុស្សចាស់ ការសំអាតអាគារ ការផលិតគ្រឿងបន្លាស់ ការផលិតគ្រឿងម៉ាស៊ីន ការផលិតគ្រឿងអគ្គិសនី និងគ្រឿងអេឡិចត្រូនិច ការងារសំណង់ ការផលិតនាវា ការជួសជុល និងតម្លើងរថយន្ត ការងារអាកាសចរណ៍ ការរៀបចំបន្ទប់ស្នាក់នៅ កសិកម្ម នេសាទ និងវារីវប្បកម្ម ការផលិតអាហារនិងភេសជ្ជៈ និងការងារនៅភោនីយដ្ឋាន។ សូមបញ្ជាក់ថា កម្ពុជាជាប្រទេសទី២ ដែលបានចុះអនុស្សរណៈនេះនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ បន្ទាប់ពីហ្វីលីពីនដែលបានចុះនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩៕

## ប្រទេសទាំងពីរ និងគាំទ្រ ការជ្រើសរើស កម្មសិក្សាការីខ្មែរកាន់តែច្រើន

https://www.dap-news.com/ ByID:115 Posted on 25 March 2019 | 17:18

ភ្នំពេញ៖ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើដល់ជប៉ុនបន្តពង្រឹងកិច្ចសហការល្អរវាងប្រទេសទាំងពីរ និងគាំទ្រដល់ការបណ្តុះបណ្តាល និងជ្រើសរើសកម្មសិក្សាការីខ្មែរមកជប៉ុនបានកាន់តែច្រើនថែមទៀត ព្រមទាំងជួយក្រសួងក្នុងការរៀបចំបែបបទផ្សេងៗ ស្របតាមនីតិវិធីនៃច្បាប់ថ្មី។នេះបើយោងតាមហ្វេសប៊ុក ក្រសួងការងារ។

ក្នុងជំនួបពិភាក្សាការងារជាមួយលោក SUZUKI ប្រធានអង្គការសម្រាប់កម្មវិធីបណ្តុះបណ្តាលបច្ចេកទេសហៅកាត់ថា (OTIT) នៅទីក្រុងតូក្យូ ប្រទេសជប៉ុនថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩លោកអុិត សំហេងបានលើកឡើងថា“សូមស្នើសុំឱ្យមានការបន្តពង្រឹងកិច្ចសហការល្អរវាងប្រទេសទាំងពីរ និងគាំទ្រដល់ ការបណ្តុះបណ្តាល និងជ្រើសរើសកម្មសិក្សាការីខ្មែរមកជប៉ុនបានកាន់តែច្រើនថែមទៀត ព្រមទាំងជួយក្រសួងក្នុងការរៀបចំ បែបបទផ្សេងៗស្របតាមនីតិវិធីនៃច្បាប់ថ្មី និងផ្តល់ជំនួយបច្ចេកទេសលើការបណ្តុះបណ្តាលជំនាញបច្ចេកទេសដល់កម្មសិក្សាការីខ្មែរឱ្យស្របតាមតម្រូវការទីផ្សារការងារ នៅប្រទេសជប៉ុន”។ លោកបន្ថែមថា ស្នើជប៉ុនជួយផ្សព្វផ្សាយ និងណែនាំដល់សមាគមនាំពលករពីកម្ពុជា បានដឹងពីនីតិវិធីថ្មីៗ ស្របតាមច្បាប់របស់ប្រទេសជប៉ុន ។

ជាការឆ្លើយតបលោក SUZUKI បានឲ្យដឹងថា អង្គការលោក មានសាខាជាច្រើននៅទូទាំងប្រទេសជប៉ុន ដើម្បីផ្តល់សេវាគាំពារ ប្រឹក្សាយោបល់ និងជួយគាំទ្រដល់កម្មសិក្សាការីខ្មែរ ដែលកំពុងធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន និងរៀបចំ បែបបទថ្មីសម្រាប់ការទទួល កម្មសិក្សាការីពីប្រទេសផ្សេងៗ ស្របតាមច្បាប់ ផងដែរ៕ ដោយ នឿត សម្ផស្ស

## ពលករខ្មែរនៅទីក្រុងបាងកកតាមដានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅថៃ

https://www.rfa.org/khmer/news/ ដោយ ទីន ហ្សាការីយ៉ា 2019-03-25

ពលករខ្មែរធ្វើការនៅទីក្រុងបាងកក ប្រទេសថៃ តាមដានយ៉ាងចិត្តទុកដាក់លើការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកដំបូងគិតពីឆ្នាំ២០១៤ មកក្រោយពីរបបយោធាធ្វើរដ្ឋប្រហារទម្លាក់លោកស្រី យីងឡាក់ ស៊ីណាវ៉ាត់ (Yingluck Shinawatra) ដែលប្រព្រឹត្តនៅថ្ងៃអាទិត្យទី២៤ មីនា។ ពួកគេរំពឹងថា គណបក្សដែលជាប់ឆ្នោតថ្មីនឹងជួយសម្រួលដល់ពលករ នឹងអាចជួយឲ្យជីវិតរស់នៅរបស់ពួកគេមានសិទ្ធិសេរីភាពបានប្រសើរជាងពេលបច្ចុប្បន្ន។ លទ្ធផលឆ្នោតបឋមក្រោយពេលបិទបញ្ចប់នៃការបោះឆ្នោតនៅរសៀលថ្ងៃអាទិត្យ ទី២៤ មីនា បង្ហាញថាគណបក្ស ភឿថៃ (Pheu Thai) របស់លោក ថាក់ស៊ីន ស៊ីណាវ៉ាត់ (Thaksin Shinawatra) នាំមុខ ទទួលបាន ១៧៣អាសនៈ នៃអាសនៈសរុបចំនួន ៥០០អាសនៈនៅសភា។ គណបក្ស ផះឡាំងប្រះឆារ៉ាត់ (Palang Pracharak) របស់លោកនាយករដ្ឋមន្ត្រីចាំផ្ទះ ប្រាយុទ្ធ ចាន់អូចា (Prayut Chan-O-Cha) ទទួលបានអាសនៈ៩៦ គណបក្សប្រជាធិបតេយ្យ (Prachathipat)) របស់លោក អភិសិទ្ធ វេទជាឈីវ៉ាក់ (Abhisit Vejjajiva) បាន ៨៨អាសនៈ និងគណបក្សអនាគតថ្មី និងគណបក្សចំនួន៧ ផ្សេងទៀត ទទួលបានអាសនៈចាប់ពី ១ ទៅ ៤០អាសនៈ។ ទោះបីជាគណបក្ស ភឿថៃ (Pheu Thai) ទទួលបានអាសនៈច្រើនជាងគេក៏ដោយក៏មិនអាចបង្កើតរដ្ឋាភិបាលបានដែរ ប្រសិនបើមិនមានគណបក្សផ្សេងទៀតចូលរួមបង្កើតរដ្ឋាភិបាលនោះ ព្រោះគណបក្សរបស់លោក ប្រាយុទ្ធ ចាន់អូចា ដោយមានសមាជិកព្រឹទ្ធសភា ២៥០នាក់ ដែលបង្កើតឡើងដោយ ការកែរដ្ឋធម្មនុញ្ញថ្មីនោះ អាចជួយគាត់ធ្វើជាធ្វើនាយករដ្ឋមន្ត្រីបានដែរ។ មន្ត្រីគណៈកម្មការរៀបចំការបោះឆ្នោតថៃលើកឡើងថា ការបោះឆ្នោតនៅថ្ងៃទី២៤ មីនា ជាប្រវត្តិសាស្ត្រប្រព្រឹត្តទៅបានល្អប្រសើរ ដែលមានប្រជាពលរដ្ឋទៅបោះឆ្នោតយ៉ាងច្រើនកុះករ គឺមិនតិចជាង ៨០ភាគរយនោះទេ។

ពលករខ្មែរធ្វើនៅទីក្រុងបាងកក លោក ស៊ុន សីហា ថ្លែងប្រាប់អាស៊ីសេរីថា ពួកគាត់តាមដានការបោះឆ្នោតនេះយ៉ាងយកចិត្តទុកដាក់ ហើយសង្ឃឹមគណបក្សដែលជាប់ឆ្នោតថ្មីនឹងជួយសម្រួលដល់សិទ្ធិសេរីភាពរបស់ពលករធ្វើការនៅប្រទេសថៃបានល្អជាងមុន ព្រោះមេដឹកនាំដែលចេញពីការបោះឆ្នោតពីប្រជាពលរដ្ឋថៃ៖ «បាទខ្ញុំតាមដានក្នុងបំណងចង់យកអ្វីដែលល្អពីប្រទេសរបស់គេ ដើម្បីយកប្រើរៀបចំឲ្យមានការបោះឆ្នោតរបស់ខ្មែរឲ្យបានដូចគេដែរ ហើយទី២ដោយសារនៅប្រទេសថៃ មានពលករដល់ទៅជាង១លាននាក់ ដូច្នេះបើសិនជាប្រទេសថៃគាត់ជ្រើសរើសមេដឹកនាំមិនល្អគឺវាមានផលប៉ះពាល់ទៅដល់ពលករខ្មែរយើងដែរ»។

ចំណែកពលករម្នាក់ លោក ខ្លី ចាន់ថុល លើកឡើងថា ពួកគាត់ធ្វើការរោងចក្រនៅទីក្រុងបាងកកបានឈប់សម្រាកនៅថ្ងៃបោះឆ្នោតនេះ ហើយលោកក៏បានតាមដានការបោះឆ្នោតនេះដែរ។ លោកបន្តថា ចង់ឲ្យរដ្ឋាភិបាលថ្មីនេះធ្វើយ៉ាងណាគិតគូរដល់ពលករក្រៅប្រទេសឲ្យបានច្រើនជាងពេលបច្ចុប្បន្ន ជាពិសេសជួយសម្រួលឲ្យពលករដែលកូនបានចូលមករស់នៅជុំជាមួយឪពុកម្ដាយនៅធ្វើការនៅប្រទេស ព្រោះសព្វថ្ងៃពួកគាត់ពិបាកនាំកូនឆ្លងដែនចូលមកធ្វើការជាមួយជាខ្លាំង ដោយសារអាជ្ញាធរថៃរឹតបន្តឹងការនាំកុមារចូលមកថៃ៖ «គឺពិបាកដោយសារឥឡូវនេះរដ្ឋាភិបាលថៃបង្កើតច្បាប់មកច្រើន ដោយកាលពីមុខពលករយើងអាចយកកូនក្មេង ឬក៏ដាក់រូបកូនក្មេងនឹងអាចចេញចូលតាមព្រំដែនយ៉ាងស្រួល តែឥឡូវនេះ ច្បាប់ហាមឃាត់មិនឲ្យយើងយកកូនក្មេងចេញចូលទេ យកចេញទៅបាន តែចូលមកវិញគឺមិនបានទេ ច្បាប់នេះ គឺពិបាកណាស់សម្រាប់ពួកខ្ញុំ ព្រោះអ្នកខ្លះមកប្ដីប្រពន្ធមានយកកូនមក ដោយសារនៅផ្ទះគ្មានអ្នកមើល ដល់ពេលខាងថៃបង្កើតច្បាប់នេះមកគឺពិបាកច្រើន»។

អ្នកវិភាគតាមមហាវិទ្យាល័យល្បីៗរបស់ថៃ បានចេញបកស្រាយតាមទូរស័ព្ទថា បើតាមលទ្ធផលឆ្នោតតាមការប្រជាមតិមិនបោះឆ្នោត រដ្ឋាភិបាលថ្មីរបស់ថៃ ជារដ្ឋាភិបាលចម្រុះ ដែលមានគណបក្សជាច្រើនរួមបង្កើតរដ្ឋាភិបាល។ ទោះជាយ៉ាងណាគិតត្រឹមម៉ោងផ្សាយនេះគណៈកម្មការរៀបចំការបោះឆ្នោតរបស់ថៃកំពុងរាប់សន្លឹកឆ្នោតមិនទាន់រួចរាល់នៅឡើយ ស្របពេលគណបក្សធំៗ ដែលមានអាសនៈច្រើនចេញថ្លែងអំណរគុណដល់ម្ចាស់ឆ្នោតជាបន្តបន្ទាប់៕

## អាជ្ញាធរថៃប្រគល់ពលរដ្ឋខ្មែរ៤នាក់មកប្រទេសខ្លួនវិញក្រោយជាប់ទោស២ឆ្នាំក្នុងទឹកដីគេ

http://www.rasmeinews.com/ March 26, 2019, 6:46 AM

ដោយៈសៅរ៉ាន់ឌី/ព្រះវិហារៈកាលពីរសៀលថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩នេះអាជ្ញាធរថៃបានប្រគល់ពលរដ្ឋខ្មែរ៤នាក់មកប្រទេសខ្លួនវិញក្រោយជាប់ទោស២ឆ្នាំក្នុងទឹកដីគេពីបទឆ្លងដែនខុសច្បាប់ចូលកាប់ឈើប្រណីត។ ការប្រគល់ខ្លួនពលរដ្ឋនៅមាត់ច្រកតំបន់អានសេះ ស្ថិតក្នុងស្រុកជាំក្សាន្តខេត្តព្រះវិហារ។

លោកវរសេនីយ៍ទោ ឱ សេង អធិការនគរបាលស្រុកជាំក្សាន្តបានឱ្យដឹងថា អាជ្ញាធរថៃបានបញ្ជូនខ្លួនពលរដ្ឋខ្មែរ៤នាក់ដែលជាប់ឃុំឃាំងក្នុងខេត្តអ៊ូប៊ុនមកឱ្យលោកអនុសេនីយ៍ឯកអ៊ុយស៊ីថាអនុប្រធានក្រុមទំនាក់ទំនង ច្រកតំបន់អានសេះ។ លោក ឱ សេង បានឱ្យដឹងទៀតថា ប្រជាពលរដ្ឋខ្មែរទាំង៤នាក់នេះ ត្រូវបានអាជ្ញាធរថៃ ចាប់ខ្លួនកាលពីថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៧ ក្នុងភូមិសាស្ត្រ ស្រុកណាំយឺន ខេត្តអ៊ូប៊ុន ពីបទឆ្លងដែនខុសច្បាប់ ចូលកាប់ឈើគ្រញូងក្នុងទឹកដីថៃ តាមច្រកមុំ៣។ លោកបន្តថា ប្រជាពលរដ្ឋខ្មែរទាំង៤នេះ ទី១៖ ឈ្មោះ សួន សៀន ភេទប្រុស អាយុ១៩ឆ្នាំ, ទី២៖ ឈ្មោះ ឌិន ថេង ភេទប្រុស អាយុ២០ឆ្នាំ អ្នកទាំងពីរនេះ រស់នៅភូមិរលំថ្ម ឃុំជាំក្សាន្ត ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។ ទី៣៖ ឈ្មោះ គុប ហៃ ភេទប្រុស អាយុ៤៧ឆ្នាំ រស់នៅភូមិឈើទាល ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងទី៤៖ ឈ្មោះ ពៅ ភា ភេទប្រុស អាយុ២៥ឆ្នាំ រស់នៅភូមិស្រែក្រសាំង ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ៕ទS/

# ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩

## សម្តេចតេជោ ហ៊ុន សែន បញ្ជាក់ពីគោលការណ៍ និងវិធានការសំខាន់ៗចំនួន៨ ដែលរាជរដ្ឋាភិបាលបានធ្វើនិងបន្តផ្តោតការយកចិត្តទុកដាក់ដើម្បីធានាការគោរពសិទ្ធិការងារនៅកម្ពុជា

http://www.freshnewsasia.com/ 2019-03-28

**(ភ្នំពេញ)៖** សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា នៅព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩នេះ បានអញ្ជើញជាអធិបតីប្រារព្ធពិធីអបអរសាទរខួប១០០ឆ្នាំ ថ្ងៃបង្កើតបង្កើតអង្គការអន្តរជាតិខាងការងារ (ILO) និងខួប៥០ឆ្នាំ ដែលកម្ពុជាក្លាយជាសមាជិកអង្គការ ILO នៅវិមានសន្តិភាព។ ក្នុងឱកាសដ៏មានតម្លៃនោះ សម្តេចតេជោប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានលើកឡើងពីគោលការណ៍ និងវិធានការសំខាន់ចំនួន៨ ដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើ និងបន្តផ្តោតការយកចិត្តទុកដាក់បម្លែមទៀត ដើម្បីធានាឲ្យបាននូវការគោរពសិទ្ធិការងារនៅកម្ពុជា ស្របតាមច្បាប់ និងអនុញ្ញាអន្តរជាតិខាងការងារ។

**គោលការណ៍ និងវិធានការសំខាន់ៗទាំង៨ ដែលសម្តេចតេជោ ហ៊ុន សែន ដាក់ចេញរួមមាន៖**

**១៖** អនុវត្តគោលនយោបាយធានា ការគោរពសិទ្ធិការងារ លក្ខខណ្ឌការងារស្របតាមច្បាប់ និងអនុសញ្ញាអន្តរជាតិខាងការងារ ដែលកម្ពុជាបានផ្តល់សច្ចាប័ន។ រាជរដ្ឋាភិបាលចាត់ទុកការ អនុវត្តន៍សិទ្ធិការងារ គឺជាការអនុវត្តន៍សិទ្ធិមនុស្ស ដោយបានដាក់ចេញនូវនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្ម ទៅនឹងលក្ខខណ្ឌការងារសហការជាមួយគម្រោងឃ្លាំមើលលក្ខខណ្ឌការងារនៅកម្ពុជា ដែលបច្ចុប្បន្នជាគម្រោងរោងចក្រ កាន់តែប្រសើរនៅកម្ពុជា (ILO-BFC) ដែលបង្ហាញពីធន្ទះ និងតម្លាភាពនៃបិរិយាកាសការងារនៅកម្ពុជា។

**២៖** ផ្តោតការយកចិត្តទុកដាក់ ក្នុងការអភិវឌ្ឍទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈបន្តយន្តការត្រីភាគី ដើម្បីដោះស្រាយបញ្ហាជាច្រើនទាក់ទងសិទ្ធិ និងផលប្រយោជន៍របស់កម្មករ និយោជិត និងនិយោជក។ ជាក់ស្តែងគណៈកម្មការប្រឹក្សាការងារ បានបង្កើតក្រុមការងារត្រីភាគី បានដោះស្រាយប្រាក់ឈ្នួលអប្បបរមា របស់កម្មករនិយោជិត វិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង បានកើនឡើងពី៤០ដុល្លារ ក្នុង១ខែ នាឆ្នាំ១៩៩៧ ដល់១៨២ដុល្លារ ក្នុង១ខែ នៅឆ្នាំ២០១៩នេះ ហើយបានបើកផ្តល់២ ដងក្នុង១ខែ។

**៣៖** បន្តលើកកម្ពស់សេរីភាពអង្គការវិជ្ជាជីវៈ តាមរយៈការអនុវត្តន៍ច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីសហជីព។ គិតមកដល់ខែធ្នូ ឆ្នាំ២០១៨ ចំនួនសហជីពសរុប ដែលបានចុះបញ្ជិកានៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានចំនួន៤,៨៣៨ ក្នុងនោះ សហជីពមូលដ្ឋានមានចំនួន ៤,៦២១ សហព័ន្ធសហជីពមានចំនួន១៨០ សហភាពសហជីពមានចំនួន២៨ និងសមាគមនិយោជកមានចំនួន៩។

**៤៖** ផ្តោតការការយកចិត្តទុកដាក់ លើការអភិវឌ្ឍអនាម័យ និងសន្តិសុខការងាររបស់កម្មករ និយោជិត ជំរុញឱ្យរោងចក្រសហគ្រាសទាំងអស់មានគិលានដ្ឋាន ប្រអប់សង្គ្រោះបន្ទាន់ប្រចាំរោងចក្រ មានកន្លែងហូបបាយ មានបន្ទប់បំបៅកូន និងមានទារកដ្ឋាន ដើម្បីកាត់បន្ថយបញ្ហាដួលសន្លប់ គ្រោះថ្នាក់ការងារ បង្កើនសុវត្ថិភាពក្នុងការដឹកជញ្ជូន និងការធ្វើដំណើររបស់កម្មករ និយោជិត។ បន្តអនុវត្តឱ្យមានប្រសិទ្ធភាព នូវផែនការជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មកុមារឆ្ពោះទៅការបញ្ចប់ ពលកម្មកុមារនៅឆ្នាំ២០២៥។

**៥៖** បន្តអនុវត្តក្របខណ្ឌគោលនយោបាយជាតិ គាំពារសង្គមតាមរយៈការអភិវឌ្ឍរបបសន្តិសុខសង្គម ដែលមកទល់ពេលនេះ មានសហគ្រាសគ្រឹះស្ថានជាង១ម៉ឺន ជាសមាជិក និងមានកម្មករ និយោជិត និងមន្ត្រីសាធារណៈ ១លាន៥សែននាក់ កំពុងទទួលបានអត្ថប្រយោជន៍ទាំងអស់នេះ។ នៅឆ្នាំ២០១៩ នេះ រាជរដ្ឋាភិបាលនឹងដាក់ឱ្យដំណើរការរបបសោធនសម្រាប់កម្មករ និយោជិត និងរបបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ ព្រមទាំងរៀបចំកិច្ចសហប្រតិបត្តិការ ភ្ជាប់របបសន្តិសុខសង្គមជាមួយប្រទេស ដែលទទួលពលករកម្ពុជា។ ជាមួយនេះ រាជរដ្ឋាភិបាលបានអនុ

វត្តគោលនយោបាយ ឧបត្ថម្ភសាច់ប្រាក់ដល់កម្មការិនី ទាំងក្នុង និងក្រៅប្រព័ន្ធ និងមន្ត្រីសាធារណៈនៅពេលសម្រាលកូន មកទល់ពេលនេះ កម្មការិនីសរុបចំនួន ៦ម៉ឺន៥ពាន់នាក់ និងចំនួនកូនជិត ៦ម៉ឺន៦ពាន់នាក់ ដោយសរុបជាទឹកប្រាក់ជិត ៦លាន៦សែនដុល្លារ។ ដោយឡែកចំពោះស្ត្រីដែលមានកូនភ្លោះបីបន្ថែម ពីលើប្រាក់របស់រាជរដ្ឋាភិបាល សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ផ្តល់បន្ថែមចំនួន៥លានរៀល។

**៦៖** បន្តយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដល់ប្រជាពលរដ្ឋ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ និងការបង្កើតមុខរបរថ្មីៗ។ បន្តអភិវឌ្ឍសេវារកការងារធ្វើជូនប្រជាពលរដ្ឋ តាមរយៈការផ្តល់ព័ត៌មានអំពីតម្រូវការ ការងាររបស់សហគ្រាស គ្រឹះស្ថានដល់យុវជនយុវនារី ដែលកំពុងស្វែងរកការងារធ្វើ និងជួយដល់សហគ្រាស គ្រឹះស្ថាន ក្នុងការស្វែងរកកម្លាំងពលកម្មតាមតម្រូវការ។ ទន្ទឹមនេះ បានបង្កើតកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ក្នុងកិច្ចការពារសិទ្ធិពលករទេសន្តរប្រវេសន៍កម្ពុជា។

**៧៖** រាជរដ្ឋាភិបាលកម្ពុជា បាននឹងបន្តភាពជាដៃគូយ៉ាងជិតស្និទ្ធជាមួយ អង្គការអន្តរជាតិខាងការងារការពារការរួមគ្នាអនុវត្តនូវគោលដៅរួមដែលបានដាក់ចេញកន្លងមក ជាពិសេសកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ យើងបានរួមគ្នាអនុវត្តប្រកបដោយជោគជ័យនូវកម្មវិធីការងារសមរម្យចំនួន ៤លើករួចមកហើយ ចាប់ពីឆ្នាំ ២០០៥ ជាមួយដៃគូតំណាងត្រីភាគី ហើយគម្រោងនេះនឹងបន្តអនុវត្តនូវកម្មវិធីការងារសមរម្យ សម្រាប់ប្រទេសកម្ពុជាលើកទី៥ ឆ្នាំ២០១៩-២០២៣ សំដៅសម្រេចឱ្យបាននូវអាទិភាពបី ទី១. ការលើកកម្ពស់មុខរបរ និងការងារ និងការអភិវឌ្ឍន៍សហគ្រាសប្រកបដោយចីរភាព, ទី២. ការពង្រឹង និងពង្រីកកិច្ចគាំពារសង្គមព្រមទាំងសុខភាព និងសុវត្ថិភាពការងារ និងទី៣. ការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងវិជ្ជាជីវៈ និងសិទ្ធិការងារ។

**៨៖** បន្តកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍លក្ខខណ្ឌការងារ សិទ្ធិសេរីភាព អង្គការវិជ្ជាជីវៈ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាពដើម្បីធ្វើឱ្យកាន់តែប្រសើរឡើង នូវសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ លើកកម្ពស់គម្រោងបទដ្ឋានសង្គម និងការងារក្នុងវិស័យវាយនភណ្ឌ និងកាត់ដេរ ក្នុងតំបន់អាស៊ី (GIZ-SLSG) គម្រោងគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសកល និងគម្រោងផ្សេងៗជាច្រើនទៀត។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានបង្ហាញនូវក្តីសង្ឃឹមថា ការបន្តកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិខាងការងារ និងដៃគូអភិវឌ្ឍនានា នឹងកាន់តែជិតស្និទ្ធថែមទៀត ដើម្បីរួមគ្នាសម្រេចបាន តាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ និងដើម្បីកម្ពុជាសម្រេចបានគោលដៅរបស់ខ្លួន ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០៕

## សមត្ថកិច្ចអសមត្ថភាពមិនហ៊ានបង្រ្កាបទីតាំងម៉ាស្សាយីហោ ៨៨១ម៉ាស្សាកោសជប់ ជាកន្លែងបម្រើសេវាផ្លូវភេទនោះទេ

http://nokorwatnews.com/ 27-03-2019

ខេត្តសៀមរាប៖ បច្ចុប្បន្នគេសង្កេតឃើញ ទីតាំងម៉ាស្សា ៨៨១ម៉ាស្សាកោសជប់ ត្រូវបានគេដឹងថា ជាកន្លែងបម្រើសេវាផ្លូវភេទ ឯការដាក់ស្លាកយីហោនេះ គ្រាន់តែដាក់បំភ័ន្តភ្នែកមហាជនតែប៉ុណ្ណោះ តែជាតុពិត ជាកន្លែងបម្រើផ្លូវភេទយ៉ាងពេញបន្ទុក ដែលមានទីតាំងស្ថិតនៅក្នុងភូមិទ្រាក សង្កាត់សៀមរាប ក្រុងសៀមរាប ។

តាមប្រភពព័ត៌មានពីពលរដ្ឋបានឲ្យដឹងថា គេឃើញមានសមត្ថកិច្ចមួយចំនួនមិនបង្រ្កាបទេ ទុកស្ងំពង និងដើរយកលុយ ជាថ្នូរទៅនឹងការមិនបង្រ្កាប កត្តាទាំងនេះហើយ ទើបធ្វើឲ្យក្រុងសៀមរាប ពោរពេញទៅដោយកន្លែងម៉ាស្សាស្ទើរពេញក្រុង ។ ពលរដ្ឋថ្លែងថា លុះមដល់ពេលសមត្ថកិច្ចចុះចាប់កន្លែងម៉ាស្សា មួយកន្លែងម៉ាស្សា យីហោ ៨៨១ម៉ាស្សាកោសជប់ នេះហើយ ម្យ៉ាងទៀត មួយរយៈពេលចុងក្រោយនេះ គេមិនដែលឃើញសមត្ថកិច្ចចុះបង្រ្កាបកន្លែងម៉ាស្សាឡើយ ប្រហែលជាទុកស្ងំពង ឬត្រូវរ៉ូវគ្នាយ៉ាងស្ងៀមស្ងាត់ ទើបបណ្តោយឲ្យកន្លែងម៉ាស្សារីកដុះដាលដូចផ្សិតបែបនេះ ។

ពាក់ព័ន្ធទៅនឹងកន្លែងម៉ាស្សានេះ លោក ពេជ សុខេន មេប៉ុស្តិ៍ សង្កាត់សៀមរាប បានឲ្យដឹងថា ទីតាំងម៉ាស្សាបម្រើផ្លូវភេទនេះ លោកធ្លាប់បានបង្ក្រាបម្តងហើយ តែមិនរាងចាលទេ តែលោកចុះបង្ក្រាបក្នុងពេលឆាប់ៗនេះ ។ តែរហូតមកដល់ពេលនេះ ជិតមួយខែហើយ ការរង់ចាំមើលចំណាត់ការរបស់លោក មេប៉ុស្តិ៍ គ្មានប្រសិទ្ធភាពអ្វីសូមម្បីតែបន្តិច បានត្រឹមតែអួតក្តែងៗ ឲ្យរួចតែពីពីមាត់។

ក្នុងរឿងនេះ មានពលរដ្ឋម្នាក់ប្រាប់ថា លោក ពេជ សុខេន មេប៉ុស្តិ៍ សង្កាត់សៀមរាប ក៏ជាប់ពាក់ព័ន្ធសំណូកប្រចាំខែជាថ្នូរទៅនឹងការបង្ក្រាបដែរ ៕ ប៊ុនរិទ្ធី

## ពលករដែលកាន់ប័ណ្ណព្រំដែនចាប់ផ្តើមវិលត្រឡប់តែអាណិតកុមារតូចៗបាត់បង់ការសិក្សា

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ ម៉ោង ០៩:០៦ ម៉ុត សារុន

បន្ទាយមានជ័យ ៖ ២ថ្ងៃចុងក្រោយនេះ ពលករកាន់ប័ណ្ណព្រំដែនហៅថា Border Pass ដែលទៅធ្វើការលើទឹកដីថៃ តាមខេត្តជាប់ព្រំដែនបានសម្រុកវិលត្រឡប់មកស្រុកកំណើតវិញជាបន្តបន្ទាប់ តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ប៉ុន្តែអ្វីដែលគួរអនិច្ចា គឺកុមារតូចៗត្រូវបាត់បង់ការសិក្សាស្ទើរទាំងស្រុង ។ ជាមួយឥវ៉ាន់សំពីងសំពោងមានផ្ទាំងចាន និងកន្ទេលមុងភួយជាលក្ខណៈគ្រួសារពលករវិលត្រឡប់ពីថៃដែលគ្រួសារខ្លះមានកូនរួមដំណើររហូត៣នាក់ ខ្លះម្នាក់ដែលអះអាងថា ពួកគាត់វិលត្រឡប់ពីស៊ីឈ្នួលធ្វើការឲ្យគេក្នុងខេត្តស្រះកែវ ដូចជា ដកដំឡូង កាប់អំពៅ និងផ្សេងៗទៀត ។ ពួកគាត់បន្តថា បានប្រើប្រាស់ប័ណ្ណព្រំដែន Border Pass សម្រាប់ឆ្លងទៅមកដីថៃរកការងារធ្វើ ហើយអ្នកខ្លះថា ធ្លាប់ទៅមក៣ទៅ៤ឆ្នាំមកហើយ ។ ពេលសាកសួររឿងកុមារតូចៗពួកគាត់ឆ្លើយតបថា កូនៗមិនបានចូលសាលាទេ ហើយបញ្ជាក់យ៉ាងខ្លីថា ដោយសារកត្តាជីវភាពក្រីក្រ ខណៈគ្រួសារខ្លះមានទាំងកូនតូចបំបៅដោយទឹកដោះតាមខ្លួនថែមទៀត ។

បុរសឈ្មោះ កែវ សុភា វ័យ៤៥ឆ្នាំ មានទីលំនៅក្នុងស្រុកជើងព្រៃខេត្តកំពង់ចាម ប្រាប់ថា គាត់វិលត្រឡប់ពីធ្វើការនៅខេត្តស្រះកែវ ប្រទេសថៃ ជាលក្ខណៈគ្រួសារជាមួយកូនស្រីម្នាក់អាយុ១២ឆ្នាំ ដោយកូនស្រីគាត់មិនបានចូលរៀនទេ ព្រោះតែជីវភាពខ្វះខាត ម្យ៉ាងនៅឯស្រុកកំណើតមិនមានការងារធ្វើ ។

ដោយឡែកស្ត្រីឈ្មោះ ស៊ុន ស៊ន អាយុ២៤ឆ្នាំ មកពីស្រុកសន្ទុកខេត្តកំពង់ធំប្រាប់ថា នាងមកពីធ្វើការលើទឹកដីថៃជាលក្ខណៈគ្រួសារ មានកូន២នាក់ ដោយកូនច្បងមិនបានចូលរៀនដូចគ្នា ។ ស្ទើគ្រប់ពលករប្រាប់ថា ក្រោយពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីយជាតិក្នុងខែមេសា ពួកគាត់និងត្រឡប់ទៅធ្វើការលើទឹកដីថៃវិញ ។ ពួកគាត់ថា ការវិលត្រឡប់មកស្រុកកំណើតឆ្នាំនេះ គឺសមត្ថកិច្ចខ្មែរ-ថៃ នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែតខ្លងលឹកមិនយកកម្រៃអ្វីឡើយ ។

មន្ត្រីនគរបាលអន្តោប្រវេសន៍ច្រកទ្វាអន្តរជាតិប៉ោយប៉ែតម្នាក់ប្រាប់តាមបណ្តាញសង្គមវ៉េសអាប់ថា យោងតាមគោលការណ៍ណែនាំរបស់ថ្នាក់លើ លោកខឹម ចិត្រា ដែលជានាយប៉ុស្តិ៍បានណែនាំដល់កម្លាំងក្រោមឱវាទត្រូវយកចិត្តទុកដាក់ការពារសន្តិសុខសណ្តាប់ធ្នាប់ និងសុវត្ថិភាព ដល់ភ្ញៀវជាតិ និងអន្តរជាតិដែលឆ្លងកាត់ព្រំដែន និងសម្រួលរាល់ដំណើរវិលត្រឡប់របស់ពលករខ្មែរពីថៃ ដោយមិនតម្រូវឲ្យយកប្រាក់ឡើយ ។ មន្ត្រីដដែលបញ្ជាក់ថា ពលករដែលទៅធ្វើការតាមបណ្តាខេត្តក៏ដូចជា ក្រុងបាងកក ប្រទេសថៃ ដែលកាន់លិខិតឆ្លងដែនការងារមកទល់ពេលនេះពុំទាន់មានការវិលត្រឡប់មកស្រុកកំណើតនៅឡើយទេ ហើយអះអាងថា មានតែពលករកាន់ប័ណ្ណព្រំដែនហៅថា Border Passតែប៉ុណ្ណោះដែលវិលត្រឡប់ ៕

# កម្ពុជា-ជប៉ុន ចុះអនុស្សរណៈ ស្តីពីការបញ្ជូនពលករ ខណៈ ជប៉ុនចង់បានពលករ ជំនាញខាងថែទាំមនុស្ស ចាស់ខ្លាំងជាងគេ

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ ម៉ោង ០៧:៤០ គុច ណារ៉េន

រាជធានីភ្នំពេញ៖ ក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសេវារកការងារធ្វើជូនប្រជាពលរដ្ឋតាមរយៈទីភ្នាក់ងារជាតិមុខរបរនិងការងារ សម្រាប់ការងារក្នុងប្រទេស និងតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់សម្រាប់ការងារនៅក្រៅប្រទេស យ៉ាងហោចណាស់មានពលករខ្មែរ ធ្វើការនៅបរទេសមានចំនួនប្រមាណជាង ១.២ លាននាក់ ដែលក្នុងនោះ មានកម្មសិក្សាការីខ្មែរ បំរើការងារនៅប្រទេសជប៉ុន មានប្រមាណជិត៧ពាន់នាក់ ។

ជាថ្មីម្តងទៀត កម្ពុជានិងជប៉ុន បានចុះ ហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការ ការបញ្ជូនពលករជំនាញទៅធ្វើការនៅប្រទេសជប៉ុន រវាង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ នៅក្រសួងយុត្តិធម៌ប្រទេសជប៉ុន ក្រោមវត្តមានរបស់រដ្ឋមន្រ្តីក្រសួងការងារកម្ពុជា លោក អ៊ិត សំហេង និងលោក Takashi YAMASHITA រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃប្រទេសជប៉ុន ។ ដែលពិធីចុះហត្ថលេខានេះ ធ្វើឡើងរវាងលោក សេង សក្ដា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានការងារ និងលោកជំទាវ Shoko SASAKI អគ្គនាយកអន្តោប្រវេសន៍ជប៉ុន។

លោក Takashi YAMASHITA រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃប្រទេសជប៉ុន បានលើកឡើងថា កាលពីឆ្នាំកន្លងទៅ កម្ពុជា-ជប៉ុន បានប្រារព្ធពិធីអបអរសាទរខួបលើកទី៦៥នៃទំនាក់ទំនងការទូតកម្ពុជាជប៉ុន ហើយការចុះអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការស្តីពីពលករជំនាញនាថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៩ ជាភស្តុតាងបញ្ជាក់យ៉ាងច្បាស់ ពីទំនាក់ទំនងដ៏ស្អិតរមួត រវាងប្រទេសទាំងពីរឱ្យកាន់តែរឹងមាំថែមទៀត ។ លោក អ៊ិត សំហេង បានសម្តែងនូវការកោតសរសើរ ចំពោះក្រុមការងារបច្ចេកទេសនៃប្រទេសទាំងពីរ កម្ពុជា-ជប៉ុន ដែលបានខិតខំសហការគ្នា ប្រកបដោយការទទួលខុសត្រូវខ្ពស់ នាពេលកន្លងមករហូតឈានដល់ការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ។ រដ្ឋមន្ត្រីក្រសួងការងារកម្ពុជា បានបញ្ជាក់ថា បច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជាកំពុងរស់នៅ សិក្សា និងធ្វើការនៅប្រទេសជប៉ុនមានចំនួនប្រមាណ ១១,០០០ ពាន់នាក់ ក្នុងនោះកម្មសិក្សាការីមានប្រមាណជិត៧ពាន់នាក់។

លោក អ៊ិត សំហេង មានប្រសាសន៍បញ្ជាក់ថា «តាមរយៈអនុស្សារណៈនៃកិច្ចសហប្រតិបត្តិការនេះ ពលករជំនាញកម្ពុជានឹងមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចាប់យកឱកាសមាសនេះ ដើម្បីជាផលប្រយោជន៍សម្រាប់ខ្លួនឯងផងសម្រាប់កម្ពុជាផង ក៏ដូចជាចូលរួមចំណែកដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មរបស់ជប៉ុន ជាពិសេសសម្រេចឱ្យបាននូវចក្ខុវិស័យគ្រប់ជ្រុងជ្រោយជាយុទ្ធសាស្ត្រនៃប្រទេសទាំងពីរ » ។

សូមបញ្ជាក់ថា រដ្ឋាភិបាលជប៉ុនបានធ្វើវិសោធនកម្មច្បាប់ស្តីពីការទទួលជនភៀសខ្លួន និងការគ្រប់គ្រងជនអន្តោប្រវេសន៍ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៨ ដោយបង្កើតទិដ្ឋាកាការងារថ្មីចំនួន២ប្រភេទគឺ «ពលករជំនាញ១» និង «ពលករជំនាញ២» ។ ច្បាប់នេះនឹងចាប់ផ្តើមអនុវត្តនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩។ ដោយឡែកប្រព័ន្ធបញ្ជូនកម្មសិក្សាការីនៅអនុវត្តដដែល។

ជប៉ុនគ្រោងទទួលយកពលករជំនាញទាំង ២ ប្រភេទ ពីប្រទេសចំនួន៨ រួមមាន កម្ពុជា ចិន វៀតណាម ហ្វីលីពីន ឥណ្ឌូនេស៊ី ថៃ មីយ៉ាន់ម៉ា និងនេប៉ាល់ ចំនួន ៣៤៥,១៥០នាក់ ក្នុងរយៈពេល៥ឆ្នាំដំបូងក្នុងនោះ ៖ ពលករជំនាញសម្រាប់ការងារចំនួន១៤ប្រភេទ រួមមានផ្នែកថែទាំមនុស្សចាស់ ការសំអាតអាគារ ការផលិតគ្រឿងបន្លាស់ ការផលិតគ្រឿងម៉ាស៊ីន ការផលិតគ្រឿងអគ្គិសនី និងគ្រឿងអេឡិចត្រូនិច ការងារសំណង់ ការផលិតនាវា ការជួសជុលនិងតម្លើងរថយន្ត ការងារអាកាសចរណ៍ ការរៀបចំបន្ទប់ស្នាក់នៅ កសិកម្ម នេសាទ និងវារីវប្បកម្ម ការផលិតអាហារ

និងភេសជ្ជៈ និងការងារនៅភោនីយដ្ឋាន។ សូមបញ្ជាក់ថា កម្ពុជាជាប្រទេសទី២ ដែលបានចុះអនុស្សារណៈនេះនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ បន្ទាប់ពីហ្វីលីពីនដែលបានចុះនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ ។

បើតាម លោកហេង សួរ អ្នកនាំពាក្យក្រសួងការងារ បានបញ្ជាក់ឲ្យដឹងថាតាមរយៈ MoU ថ្មីនេះ គឺមានន័យថា «កម្មសិក្សាការី ដែលស្របច្បាប់អាចក្លាយទៅជាពលករជំនាញកំរឹត១ ប្រសិនជាជំនាញដែលកម្មសិក្សាការីកំពុងធ្វើបច្ចុប្បន្នស្ថិតនៅក្នុងចំណោមជំនាញទាំង១៤ ដែលជប៉ុនអនុញ្ញាត។ បងប្អូននឹងអាចបន្តធ្វើការជាពលករជំនាញនៅជប៉ុនបាន ៥ឆ្នាំថែមទៀត »។ លោកបានបន្តថា យោងតាមច្បាប់អន្តោ ប្រវេសន៍ថ្មីរបស់ជប៉ុន ជនបរទេសដែលទៅប្រទេសជប៉ុនជារូបភាពទេសចរណ៍ ឬជាកម្មសិក្សាការី ហើយគេចខ្លួនខុសច្បាប់ រួចស្នើសុំសិទ្ធស្នាក់នៅជប៉ុនជាបន្តក្រោមហេតុផលជនភៀសខ្លួននយោបាយ ឬហេតុផលផ្សេងៗ គឺនឹងមិនត្រូវបានអនុញ្ញាតិឲ្យធ្វើការទៀតឡើយ។ ហេតុដូច្នេះដើម្បីការងារយូរអង្វែង សូមបងប្អូនដែលមានបំណងទៅធ្វើការនៅជប៉ុនជាកម្មសិក្សាការីក្តី ឬជាពលករជំនាញក្តី ព្យាយាមធ្វើជាកម្មសិក្សាការីស្របច្បាប់ កុំជឿតាមការអូសទាញរបស់មេខ្យល់ដែលអាចធ្វើឲ្យខូចអនាគតយូរអង្វែងរបស់ខ្លួន ។

សូមរម្លឹកថា លោក MIZUI Kenta នាយករងនៃការិយាល័យគោលនយោបាយសុខាភិបាលនៃខុទ្ទកាល័យលេខាធិការដ្ឋានសម្រាប់សុខភាព និងសុមាលភាពអាស៊ី ធ្លាប់បានប្រាប់សារព័ត៌មានកោះសន្តិភាពថា ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលជប៉ុន កាលពីខែវិច្ឆិកា ឆ្នាំ២០១៧ បានចុះ MOU សម្រាប់ការចាប់ផ្តើមអនុវត្តកិច្ចសហប្រតិបត្តិការរយៈពេល៥ឆ្នាំ ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់ឆ្នាំ២០២២ ដែលក្នុងនោះកម្ពុជានឹងបញ្ជូនកម្មសិក្សាការីរបស់ខ្លួនទៅធ្វើកម្មសិក្សា និងបម្រើការងារនៅប្រទេសជប៉ុន លើវិស័យការថែទាំមនុស្សចាស់ ។

សម្រាប់ការងារថែទាំមនុស្សចាស់ ជប៉ុនគឺផ្តល់អត្ថប្រយោជន៍ជាច្រើនដល់កម្មសិក្សាការីបរទេស ដោយការផ្តល់ជាប្រាក់បៀវត្សជាធម្យម ១៤៣០០០ យ៉េន (ប្រមាណជាង ១៣០០ដុល្លារ) ក្នុងមួយខែសម្រាប់ឆ្នាំទី១ បន្ទាប់មកទៀតប្រាក់បៀវត្សនឹងឡើងដល់ចំនួនប្រមាណជា ១៣៧៤ ដុល្លារក្នុង១ខែ និងឆ្នាំទី៣ ទទួលបានប្រមាណជាង ១៣៩៤ ដុល្លារសហរដ្ឋអាមេរិកក្នុង១ខែ ៕

## ប្រាក់ខែនៅប្រទេសជប៉ុន ជំនាញផ្នែកគិលានុបដ្ឋាកខ្ពស់ជាងជំនាញដទៃ

http://bayontv.com.kh/ 27/03/2019

ភ្នំពេញ៖ តាមការបញ្ជាក់របស់ក្រុមហ៊ុនឯកជនក្នុងស្រុក បានឲ្យដឹងថា ប្រាក់ខែដែលពលករខ្មែរបម្រើការងារនៅក្នុងប្រទេសជប៉ុន ជំនាញផ្នែកគិលានុបដ្ឋាក គឺខ្ពស់ជាងជំនាញផ្នែកដទៃ ដូចជាខាងផ្នែកឧស្សាហកម្ម កសិកម្ម វេចខ្ចប់ និងផ្នែកសំណង់ជាដើម។

លោកស្រី យោគ សិរីសុភ័ស្ស ប្រធានក្រុមហ៊ុននាំពលករខ្មែរទៅធ្វើការនៅប្រទេសជប៉ុន ជេអ៊ិលអេស (JLS) បានមានប្រសាសន៍ប្រាប់ នៅល្ងាចថ្ងៃទី២៦ មីនា ឆ្នាំ២០១៩ថា ជាមធ្យមប្រាក់ខែរបស់ពលករជំនាញផ្នែកគិលានុបដ្ឋាក ទទួលបានប្រមាណ១.៦០០ដុល្លារអាមេរិក ដែលជំនាញដទៃផ្សេងទៀតចន្លោះពី១.២០០ ឬ១.៣០០ ដុល្លារប៉ុណ្ណោះ។ ចំពោះលក្ខខណ្ឌនិងនីតិវិធីដែលពលករខ្មែរអាចមានសិទ្ធិ និងអាចជាប់ទៅបំពេញការងារនៅប្រទេសជប៉ុនបាន គឺទាមទារចាំបាច់ឲ្យបុគ្គលត្រូវចេះភាសាជប៉ុន និងត្រូវមានអាយុចាប់ពី១៨ ដល់៤០ឆ្នាំ។ ដោយមើលឃើញពីតម្រូវការការងារ ក៏ដូចជាធ្លាប់មានបទពិសោធន៍យូរឆ្នាំនៅប្រទេសជប៉ុនលើជំនាញផ្នែក គិលានុបដ្ឋាក លោកស្រីប្រធានបានឲ្យដឹងទៀតថា សម្រាប់ក្រុមហ៊ុន ជេអ៊ិលអេស រាល់សំណុំបែបបទនិងថ្លៃធ្វើដំណើរទាំងអស់ គឺមិនតម្រូវឲ្យប្រាក់ឡើយ (អ្នកមានបំណងចង់ធ្វើការនៅជប៉ុន)។

សូមបញ្ជាក់ថា កាលពីថ្ងៃទី២៥ ខែមីនាកន្លងទៅនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃប្រទេសកម្ពុជា និងក្រសួងយុត្តិធម៌នៃប្រទេសជប៉ុន បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការ ការបញ្ជូនពលករជំនាញទៅធ្វើការនៅប្រទេសជប៉ុន ដែលនេះជាដំណឹងល្អមួយកម្រិតទៀតដល់ពលករកម្ពុជា។ គិតមកទល់បច្ចុប្បន្នប្រជាពលរដ្ឋកម្ពុជាកំពុងរស់នៅ សិក្សា និងធ្វើការនៅប្រទេសជប៉ុនមានចំនួនប្រមាណ ១ម៉ឺន ១៣ពាន់នាក់ ក្នុងនោះកម្មសិក្សាការីមានប្រមាណជិត៧ពាន់នាក់៕

## ពលករខ្មែរទាំង ០៧នាក់ ដែលឆ្លងដែនខុសច្បាប់ ត្រូវភាគីថៃបញ្ជូនត្រឡប់មកវិញ

https://www.facebook.com/ Department of Immigration - GDI 28-03-2019

កោះកុង៖ កម្លាំងនគរបាលប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម នាវេលាម៉ោង ១៧និង១០នាទី ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ បានទទួលពលករខ្មែរឆ្លងដែនខុសច្បាប់ ពីភាគីថៃចំនួន ០៧នាក់។ បច្ចុប្បន្នកម្លាំងនគរបាលប៉ុស្តិ៍បានធ្វើការអប់រំណែនាំ រួចអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះវិញ៕

## ក្នុងត្រីមាសទី១ សួនភ្លូបានបញ្ជូនពលរដ្ឋខ្មែរខុសច្បាប់ចំនួន៥៨៣នាក់ ទៅប្រទេសកម្ពុជាវិញ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 28-03-2019

នៅរសៀលថ្ងៃទី២៧ មិនា ២០១៩ ក្រុមការងារស្ថានទូតបានជួបជាមួយការិយាល័យអន្តោប្រវេសន៍សួនភ្លូ ទីក្រុងបាងកក ដើម្បីពិភាក្សាការងារត្រីមាសទី១ និងបានសួរសុខទុក្ខពលរដ្ឋខ្មែរ និងទិសដៅត្រីមាសទី២ ២០១៩ ។ ក្នុងត្រីមាសទី១ សួនភ្លូបានបញ្ជូនពលរដ្ឋខ្មែរខុសច្បាប់ចំនួន៥៨៣នាក់ ទៅប្រទេសកម្ពុជាវិញ និងបន្តសហការសំរាប់ត្រីមាសទី២ ។

## ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានពន្យល់ណែនាំដល់បងប្អូនពលករ

https://www.facebook.com/ Royal Embassy of Cambodia in Bangkok 27-03-2019

នាថ្ងៃពុធ ៧រោច ខែផល្គុន ឆ្នាំច ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ ស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសថៃ បានពន្យល់ណែនាំដល់បងប្អូនពលករ ដែលមកទទួលសេវានៅស្ថានទូត អំពីច្បាប់ការងារ សិទ្ធិនិងអត្ថប្រយោជន៍ បម្រាម ទោសបញ្ញត្តិ និងការស្នើសុំជំនួយក្នុងករណីបងប្អូនពលករជួបប្រទះបញ្ហាផ្សេងៗក្នុងការស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ។ ឆ្លៀតឱកាសនេះ ស្ថានទូតក៏បានចែកនំជូនកូនរបស់បងប្អូនពលករផងដែរ។

## ស្ត្រីក្មេងៗជនជាតិមីយ៉ាន់ម៉ាត្រូវបានមេខ្យល់លក់ឲ្យទៅពពោះបង្កើតកូននៅចិន

http://vayofm.com/entertain/ ដោយ៖ ពេញ ផេង 28-03-2019 8:32 AM

តាមរបាយការណ៍បង្ហាញដោយអង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) បានឲ្យដឹងថា ស្ត្រីជនជាតិមីយ៉ាន់ម៉ាក្មេងៗរស់នៅតំបន់ព្រំដែនជាមួយចិន ដែលទៅស្វែងរកការងារធ្វើក្នុងប្រទេសចិន ពួកគេមិនមានការងារល្អឡើយ ផ្ទុយទៅវិញត្រូវបានក្រុមមេខ្យល់បោកបញ្ឆោតយកទៅលក់ប៉ុណ្ណោះ។ ស្ត្រីទាំងនោះត្រូវបានគេលក់ទៅឲ្យក្រុមគ្រួសារជនជាតិចិន ដើម្បីឲ្យធ្វើជាភរិយានិងបង្កើតកូនសម្រាប់ពួកគេ។ ស្ត្រីខ្លះត្រូវលក់បន្តពីគ្រួសារមួយទៅគ្រួសារមួយទៀត ហើយនៅពេលពួកគេបង្កើតបានកូនហើយ ពួកគេនឹងអាចវិលត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែមិនអាចយកកូនមកជាមួយដាច់ខាត។ ក្រុមមេខ្យល់អាចរកប្រាក់បានពីការជួញដូរស្ត្រីទៅឲ្យជនជាតិចិន ចន្លោះពី៣,០០០ទៅ១៣,០០០ដុល្លារអាមេរិក។

សូមបញ្ជាក់ថា ដោយសារតែជម្លោះក្នុងតំបន់ពួកគេរស់នៅ គឺស្ថិតក្នុងរដ្ឋកាជីនរបស់មីយ៉ាន់ម៉ា ជំរុញឲ្យប្រជាជនត្រូវចំណាកស្រុក ពិសេសទៅប្រទេសចិនដែលមានព្រំដែនជាប់គ្នា ដើម្បីស្វែងរកការងារធ្វើនិងគេចចេញពីការប្រយុទ្ធគ្នា។ ប៉ុន្តែការចាកចេញទាំងប្រថុយប្រថា បានធ្វើឲ្យពួកគេក្លាយជាជនរងគ្រោះដោយសារតែការជួញដូរមនុស្សទៅវិញសំខាន់បំផុតគឺស្ត្រីជនជាតិមីយ៉ាន់ម៉ាដែលត្រូវគេលក់ឲ្យទៅធ្វើជាអ្នកពពោះបង្កើតកូនសម្រាប់ជនជាតិ៕

# ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩

## ថៃបញ្ជូនពលរដ្ឋខ្មែរម្នាក់តាមច្រកអន្តរជាតិជាំបន្ទាប់ដោះលែងពីពន្ធនាគារ

http://www.rasmeinews.com/ March 28, 2019, 6:23 PM

ដោយៈ បាយ័ន/ឧត្តរមានជ័យ: ពលរដ្ឋខ្មែរម្នាក់ត្រូវបានអាជ្ញាធរប្រទេសថៃបញ្ជូនមកឱ្យភាគីកម្ពុជាតាមច្រកអន្តរជាតិជាំស្រងាំ បន្ទាប់ពីបុរសរូបនោះបានឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ នៅក្នុងទឹកដីថៃ ។ត្រូវភាគីថៃចាប់យកទៅដាក់ពន្ធនាគារនៅទីនោះរហូតដល់ថ្ងៃទី២៨ខែមីនាឆ្នាំ២០១៩នេះទើបដោះលែងឱ្យមានសេរីភាពពីពន្ធនាគារនៃខេត្តស៊ីសាកេតប្រទេសថៃ។ការប្រគល់និងទទួលនេះបានធ្វើឡើងនៅច្រកអន្តរជាតិជាំស្រងាំ ក្នុងទឹកដីស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យកាលពីរសៀលថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។

សមត្ថកិច្ចនគរបាលប្រចាំច្រកអន្តរជាតិជាំស្រងាំបាននិយាយថាពលរដ្ឋខ្មែរម្នាក់នោះឈ្មោះ ចួន រឿន ភេទប្រុសអាយុ៣៧ឆ្នាំរស់នៅភូមិម្កាក់ឃុំថមល្អស្រុកសំរោងទងខេត្តកំពង់ស្ពឺ។សមត្ថកិច្ចបានបន្តថាជនឈ្មោះចួនរឿនត្រូវបានចាប់ខ្លួនកាលថ្ងៃទី២ខែមេសាឆ្នាំ២០១៦កន្លងទៅនេះពីបទឆ្លងដែនកាប់ឈើគ្រញូងខុសច្បាប់ចូលតាមច្រកអូរស្វាយហើយយកទៅដាក់ពន្ធនាគារនៅស្រុកខាន់តាឡាក់ខេត្តស៊ីសាកេតប្រទេសថៃរហូតមកដល់ពេលនេះទើបបានធ្វើការដោះលែងឱ្យមានសេរីភាពវិញហើយបញ្ជូនមកស្រុកកំណើតតែម្តង៕S/

## ពលករមានកូនតូចធ្វើការនៅថៃ រិះគន់មន្ត្រីស្ថានទូតខ្មែរនៅទីក្រុងបាងកកថា មិនយកចិត្តទុកដាក់ចំពោះពួកគេ

https://www.rfa.org/khmer/news/ ដោយ សន ចាន់រដ្ឋា 2019-03-28

ពលករខ្មែរធ្វើការនៅប្រទេសថៃ ដែលមានកូនតូចយកទៅនៅជាមួយ រិះគន់មន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ថាមិនគិតពីទុក្ខលំបាករបស់ពលករ។ ការរិះគន់នេះ ធ្វើឡើងបន្ទាប់ពីពួកគាត់ទៅបំពេញឯកសារនៅស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ត្រូវចំណាយពេលយូរពេកចំណាយអស់ថវិកាច្រើន និងតឹងចិត្តនៅពេលឃើញមន្ត្រីទូតធ្វើការយឺត។ ពលករខ្មែរដែលធ្វើការនៅប្រទេសថៃ ហើយមានកូនតូច ចោទថា មន្ត្រីស្ថានទូតខ្មែរព្រងើយកន្តើយដាក់ពួកគាត់ នៅពេលពួកគាត់ទៅរកជំនួយឯកសារផ្លូវច្បាប់។

ពលករខ្មែរធ្វើការនៅប្រទេសថៃ លោក វិន មករា ថ្លែងប្រាប់អាស៊ីសេរីឲ្យដឹងនៅថ្ងៃទី២៧មីនាថា ពួកគាត់ជួបការលំបាកយ៉ាងខ្លាំងក្នុងការធ្វើលិខិតបញ្ជាក់ពីស្ថានទូតខ្មែរម្តងៗ ជាពិសេសលិខិតបញ្ជាក់ដើម្បីយកកូនទៅតាមក្នុងពេលធ្វើការនៅប្រទេសថៃ។ ពលកររូបនេះ អះអាងថា កាលពីថ្ងៃទី២៣ មីនាកន្លងទៅ ពួកគាត់បាននាំកូនទៅធ្វើលិខិតបញ្ជាក់ពីស្ថានទូត ត្រូវចំណាយពេលរង់ចាំតាំងពីម៉ោង ៨កន្លះព្រឹករហូតដល់ម៉ោង១០យប់ ទើបបានឯកសារ។ លោកបន្តថា មន្ត្រីស្ថានទូតមិនអើពើជួយដល់ពលករ ដែលចង់បានឯកសារឆាប់ ធ្វើមួយថ្ងៃរួចនោះទេ ប្រសិនបើពួកគាត់មិនបានបង់ប្រាក់ក្រៅផ្លូវការចំនួន២០០បាត ឬប្រមាណ ២ម៉ឺន ៥ពាន់រៀល (២៥.០០០រៀល) ក្នុងម្នាក់ជូនដល់មន្ត្រីទូតនោះ។ លោកថា នៅក្នុងស្ថានទូតមិនតម្រូវឲ្យបង់ប្រាក់ធ្វើលិខិតបញ្ជាក់នាំកូនទៅជាមួយឪពុកម្តាយនោះទេ ក៏ប៉ុន្តែពលករដែលគ្មានប្រាក់បង់ គឺត្រូវរង់ចាំរយៈពេល ៣ថ្ងៃ ទើបបាន។ បញ្ហានេះប៉ះពាល់ដល់ពលករនៅខេត្តឆ្ងាយៗ ត្រូវស្នាក់នៅទីក្រុងបាងកកច្រើនថ្ងៃ៖ «វាផ្ទុយនឹងស្ថានទូតប្រទេសគេ ហើយមិនគោរពពេលវេលាទេ បើស្ថានទូត

លាវនៅជិតនោះ គឺគេធ្វើការបម្រើពលរដ្ឋរបស់គេល្អណាស់ គេសឹងតែមិនឈប់សម្រាកផង គេសុខចិត្តផ្លាស់ប្ដូរគ្នាបម្រើពលរដ្ឋគេធ្វើមិចឲ្យបានហើយ គេយល់ពីសុខទុក្ខរបស់ពលករ។ចំពោះទូតខ្មែរគឺ ផ្ទុយស្រឡះ ដល់ពេលឈប់គឺឈប់តែម្ដង ហើយចាក់សោមិនឲ្យចេញទៀត ទាល់តែពួកខ្ញុំទៅសុំ ថាបងអើយខ្ញុំសុំយកក្មេងទៅហូបអីសិន បើបងចាក់សោអ៊ីចឹងក្មេងៗ ចេញទៅក្រៅមិនកើត គាត់ថា ម៉េចក៏មិនប្រាប់មុន»។ លោកបន្តថា បញ្ហានេះបានប៉ះពាល់យ៉ាងខ្លាំងដល់សតិអារម្មណ៍របស់ពលករ ព្រោះត្រូវចំណាយអស់ថវិកាច្រើន ដើម្បីស្នាក់នៅទីក្រុងបាងកក ព្រោះពលករមួយចំនួនធ្វើការនៅតាមខេត្ត មិនមានបងប្អូននៅក្បែរស្ថានទូតនោះទេ ម្យ៉ាងទៀតក៏ប្រឈមនឹងថៅកែបញ្ឈប់បីការងារដែរ ដោយសារមិនបានធ្វើការច្រើនថ្ងៃ។

ពលករម្នាក់ទៀត ធ្វើការនៅខេត្តរ៉ាក់យ៉ង (Rakyorng) នៅភាគខាងកើតទៅក្រុងបាងកក លោក ឡេង ឡុង អះអាងថា នៅពេលធ្វើលិខិតបញ្ជាក់ពីស្ថានទូតម្ដងៗ ពួកគាត់នៅរង់ចាំដាច់បាយក្រហាយទឹកយ៉ាងលំបាកលំបិនស្ទើរតែខ្យល់ចាប់ ព្រោះទាំងម្ដាយឪពុកនឹងកូនឈរនៅក្រោមកម្ដៅថ្ងៃនៅក្នុងស្ថានទូតពេញមួយថ្ងៃ។ លោកបន្តថា ទោះបីជាពួកគាត់លំបាកយ៉ាងនេះក្ដី ក៏មន្ត្រីទូតមិនអើពើជាមួយពួកគាត់ដែរ ដោយប្រៀបដូចពួកគាត់ជាជនអន្តោប្រវេសន្តខុសច្បាប់ទៅសុំសិទ្ធជ្រកកោនប្រទេសដទៃដូច្នេះដែរ៖ «មើលតាមទូរទស្សន៍វាខុសពីកន្លែងដែលខ្ញុំទៅ ព្រោះខ្ញុំទៅទូត ៣ដងហើយ ក្នុងទូរទស្សន៍គេថាជួយពលករ ដល់ពេលខ្ញុំទៅដល់ផ្ទាល់វាអត់ដូច។ ជនជាតិថៃនៅក្បែរទូតក៏គេនិយាយប្រាប់ខ្ញុំដែរ គេថាស្ថានទូតខ្មែរធ្វើការយឺតណាស់ ហើយធ្វើការមិនទៀតទាត់ម៉ោងទៀត។ ចំពោះមនុស្សធំខ្ញុំមិនសូវខឹងទេ តែនេះកូនក្មេងគ្នាក្ដៅលំបាក»។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកទទួលបន្ទុកផ្នែកពលករ លោក ចិន សំណាង ដើម្បីឆ្លើយតបជុំវិញការចោទប្រកាន់នេះបានទេនៅថ្ងៃទី២៦ និងទី២៧ មីនា ដោយអ្នកលើកទូរស័ព្ទអះអាងថា ខ្លួនជាជំនួយការមន្ត្រីទូតមានប្រសាសន៍ថា លោក ចិន សំណាង ជាប់រវល់ ហើយថា លោកក៏មិនអាចបកស្រាយជុំវិញបញ្ហានេះបានដែរ៖ «ខ្ញុំអត់ដឹងដែរបងចំណុចនឹងទាល់តែបងទាក់ទងទៅខាងមន្ត្រីទទួលបន្ទុកដោយត្រង់ ព្រោះខ្ញុំគ្រាន់តែបុគ្គលិកកិច្ចសន្យារបស់ទីប្រឹក្សាទទួលបន្ទុកពលករ។ តាមធម្មតា គឺយើងធ្វើការពីម៉ោង ៨ន្លះទៅដល់ម៉ោង ១២ថ្ងៃ រួចហើយយើងធ្វើការម្ដងទៀតពី ២ ដល់ម៉ោង ៥ល្ងាច»។

ទោះជាយ៉ាងនេះក្ដីនាយកប្រតិបត្តិមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស ហៅថា សង់ត្រាល់ (CENTRAL) លោក មឿន តុលា មានប្រសាសន៍ថា កន្លងមកលោកតែងទទួលដំណឹងពីពលករអំពីការលំបាកក្នុងពេលធ្វើលិខិតស្នាមពីស្ថានទូតខ្មែរជាប្រចាំ។ លោកបន្តថា ការមិនយកចិត្តទុកដាក់ដល់ពលករ គឺជារឿងមិនត្រឹមត្រូវឡើយ ព្រោះមន្ត្រីទូតជាតំណាងឲ្យអាជ្ញាធរខ្មែរប្រចាំនៅក្រៅប្រទេសសម្រាប់ជួយដោះស្រាយទុកលំបាករបស់ពលករពីព្រោះពួកគាត់ក៏បានបង់ពន្ធជូនរដ្ឋបានប្រាក់ចំណូលជាតិជាច្រើនដែរ។ លោកបន្តថា ការបំពេញការងារយឺតយ៉ាវ នាំឲ្យប៉ះពាល់ដល់ប្រាក់ចំណូល និងការងាររបស់ពលករ ព្រោះត្រូវចំណាយពេលច្រើនថ្ងៃក្នុងការធ្វើដំណើរ និងស្នាក់នៅទីក្រុងបាងកក៖ «កន្លែងនេះខ្ញុំគិតថារដ្ឋយើងគួរតែចាប់ផ្ដើមពិចារណារឿងនេះ ហើយសម្រួលតាំងពីឯកសារផ្សេងៗហើយអាចយកសេចក្ដីប្រកាសរបស់សមាគមអាស៊ាន ព្រោះយើងនៅក្នុងប្រទេសអាស៊ានក៏ដូចជំហរលើការគោរពការលើកស្ទួយរបស់ពលករចំណាកស្រុកក៏មានចែង ហើយចង្អុលបង្ហាញប្រទេសទាំងអស់ដែលជាសមាជិកអាស៊ានទោះបីជាប្រទេសបញ្ជូនក៏ដោយប្រទេសទទួលក៏ដោយ គឺគោរពយ៉ាងម៉ឺងម៉ាត់បំផុតទៅលើអនុសញ្ញាពលកម្មអន្តរជាតិពាក់ព័ន្ធការលើកស្ទួយសិទ្ធិពលករចំណាកស្រុកនិងក្រុមគ្រួសាររបស់គាត់»។ មន្ត្រីសង្គមស៊ីវិលរូបនេះបន្តថា ពលករនាំកុមារទៅធ្វើការជាមួយឪពុកម្ដាយនៅក្រៅប្រទេសដោយសារពួកគេមានជីវភាពក្រីក្រ ហើយគ្មានអ្នកមើលថែពួកគេនៅស្រុកកំណើត។ ដូច្នេះ ពួកគេត្រូវនាំកូនទៅធ្វើការជាមួយដោយមិនបានរៀនសូតនោះទេ។ ពលករអះអាងថា ប្រមាណ ២ឆ្នាំចុងក្រោយមកនេះ អាជ្ញាធរថៃបានរឹងបន្តឹងច្បាប់នាំក្មេងឆ្លងដែនទៅប្រទេសថៃ ហើយបើទោះបីជាឪពុកម្ដាយ

មានលិខិតឆ្លងដែនស្របច្បាប់ក៏ដោយ ក៏តម្រូវឲ្យមានលិខិតបញ្ជាក់ពីស្ថានទូតដែរ ទើបអាជ្ញាធរថៃអនុញ្ញាតឲ្យពួកគេឆ្លងដែនបាន៕

## ស្ថានទូតកម្ពុជា ប្រកាសថា វិទ្យុអាស៊ីសេរីផ្សាយ ប្រាសចាកពីការពិត ពាក់ព័ន្ធនឹងការផ្តល់សេវាដល់ពលករខ្មែរ នៅប្រទេសថៃ

http://www.freshnewsasia.com/ 2019-03-28

**(ភ្នំពេញ)៖** ស្ថានទូតកម្ពុជាប្រចាំនៅប្រទេសថៃ នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩នេះ បានចេញសេចក្តីប្រកាសមួយថា ការផ្សព្វផ្សាយរបស់វិទ្យុអាស៊ីសេរី (RFA) ពាក់ព័ន្ធនឹងការផ្តល់សេវាដល់ពលករខ្មែរ នៅប្រទេសថៃ កាលពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩ គឺភាគច្រើនប្រាសចាកពីការពិត។ សេចក្តីប្រកាសបានបញ្ជាក់ថា **«យោងតាមការចាក់ផ្សាយរបស់វិទ្យុអាស៊ីសេរី ពាក់ព័ន្ធនឹងការផ្តល់សេវាផ្សេងៗដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅក្នុងប្រទេសថៃ ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ មានកិត្តិយសសូមជម្រាបជូនដល់សាធារណជនជាពិសេសបងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃមេត្តាជ្រាបថា ស្ថានទូតសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់វិទ្យុអាស៊ីសេរី ដែលបានទទួលស្គាល់ថា ស្ថានទូតផ្តល់សេវាជូនដល់ពលកររហូតដល់ម៉ោង១០យប់ ក៏ប៉ុន្តែព័ត៌មានភាគច្រើនគឺប្រាកចាកពីការពិត»។ ជាមួយគ្នាផងដែរ ស្ថានទូតក៏បានថា កន្លងមកស្ថានទូតបានយកចិត្តទុកដាក់ដល់ពលករកម្ពុជា ដោយបានជួយសម្រួល និងដោះស្រាយបញ្ហានានារបស់បងប្អូនពលករដូចជា៖**

**១៖** រៀបចំទីតាំងដែលមានម៉ាស៊ីនត្រជាក់ មានទឹកសម្រាប់ហូប និងមានកៅអីអង្គុយរងចាំសមរម្យដល់បងប្អូនពលករដែលមកទទួលសេវា។

**២៖** បន្ថែមរយៈពេលអនុវត្តការងារផ្តល់សេវាសាធារណជូនដល់បងប្អូនពលករ ដោយមិនមានឈប់សម្រាកពេលថ្ងៃត្រង់ និងបន្ថែមថ្ងៃធ្វើការ នៅថ្ងៃសៅ-អាទិត្យ ចាប់ពីថ្ងៃទី២៧ ខែមីនាឆ្នាំ២០១៩ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៩ ដើម្បីសម្រួលការងារបញ្ជាក់លិខិតស្នាមនានាជូនដល់បងប្អូនប្រជាពលរដ្ឋនៅមុនពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ។

**៣៖** ផ្តល់សេវាក្នុងថ្ងៃតែមួយដល់ពលករ មានន័យថាពលករមកស្នើសុំឯកសារផ្សេង ដូចជាលិខិតបញ្ជាក់អោយកូនក្រោមអាយុ១៥ឆ្នាំ គ្មានលិខិតឆ្លងដែនរស់នៅជាមួយឪពុកម្តាយនៅប្រទេសថៃបណ្តោះអាសន្ន គឺអាចទទួលបានលិខិតបញ្ជាក់នោះនៅក្នុងថ្ងៃតែមួយតែម្តង ដើម្បីជួយកាត់បន្ថយការចំណាយក្នុងការធ្វើដំណើររបស់បងប្អូនពលករទៅវិញទៅមក ក៏ដូចជារយៈពេលដែលបងប្អូនពលករត្រូវសុំច្បាប់ឈប់សម្រាកពីការងារក្រុមហ៊ុន។ ចំពោះការផ្តល់លិខិតបញ្ជាក់អោយកូនក្រោមអាយុ១៥ឆ្នាំ គ្មានលិខិតឆ្លងដែនរស់ជាមួយឪពុកម្តាយនៅប្រទេសថៃបណ្តោះអាសន្ន ស្ថានទូតត្រូវធ្វើការត្រួតពិនិត្យអោយបានល្អិតល្អន់ជៀសវាងការចេញលិខិតបញ្ជាក់ជូនហើយ ប៉ុន្តែមិនអាចយកទៅប្រើប្រាស់បាន ឬចេញលិខិតជូនជនខិលខូចដែលនាំអោយមានការពាក់ព័ន្ធនឹងការជួញដូរកុមារ បើគ្មានការពិនិត្យច្បាស់លាស់នោះទេ កុមារនឹងក្លាយជាជនរងគ្រោះដាក់ជាពុំខានឡើយ។

**៤៖** ពន្យល់ណែនាំដល់បងប្អូនពលករអោយបានយល់អំពីនិតិវិធីផ្សេងៗពាក់ព័ន្ធការស្នាក់នៅ និងធ្វើការដោយស្របច្បាប់នៅក្នុងប្រទេសថៃ ក៏ដូចជាសិទ្ធិ និងអត្ថប្រយោជន៍ផ្សេងៗដែលបងប្អូនពលករយើងអាចទទួលបាន។

**៥៖** ជួយដោះស្រាយនូវបញ្ហាផ្សេងៗជូនដល់បងប្អូនពលករ ដូចជាករណីនិយោជកមិនគោរពកិច្ចសន្យាការងារ ករណីអាជ្ញាធរថៃចាប់ខ្លួន ករណីចាញ់បោកមេខ្យល់ ករណីគ្រោះថ្នាក់ការងារ។ល។

## ភាគីថៃនៅច្រករបៀងប៉ុស្តិ៍គីឡូ៩ ស្នើសុំឲ្យពលរដ្ឋខ្មែរចូលទៅធ្វើការវិលល្ងាច

http://mekong-post.com/ ដោយ មេគង្គ ប៉ុស្តិ៍ ចេញផ្សាយ ថ្ងៃទី 29 March, 2019

ខេត្តបាត់ដំបង ៖ ស្រុកសំពៅលូនតាមការស្នើសុំពីភាគីថៃ និងសហការ ជាមួយ កងកម្លាំង ការពារព្រំដែនកម្ពុជាប្រចាំស្រុក សំពៅលូន បានស្នើសុំឲ្យប្រជាពលរដ្ឋខ្មែរចូលទៅធ្វើការ នៅទឹកដីថៃ ព្រឹក វិលល្ងាច ក្នុងរយៈពេល១០ថ្ងៃ នៅ ខែមីនា ឆ្នាំ២០១៩ ស្ថិត នៅចំណុចច្រករបៀងប៉ុស្តិ៍នគបាលវិរៈការពារព្រំដែនគោកគីឡូ៩ និងផ្នែកសឹករងកងអនុសនាតូចទី១ដែលមាន លោកអនុសេនីយ៍ឯក អ៊ួន ខុន មេប៉ុស្តិ៍នគបាលការពារព្រំដែន៩១៧និងលោកអនុសេនីយ៍ទោ ឡាក ឌី ផ្នែកសឹករងស្រុកសំពៅលូន បានឯកភាពបើកច្រករបៀងអនុញ្ញាតអោយពលករខ្មែរឆ្លងដែនទៅធ្វើការព្រឹក វិលល្ងាច ក្នុងទឹកដីថៃ ដោយមានការស្នើសុំពីសមត្ថកិច្ចថៃ រវាងប្រទេសជិតខាង និងត្រូវបានលោកមេប៉ុស្តិ៍ទាំងពីរ ស្នើសុំ ទៅថ្នាក់លើ និងបានឯកភាពឲ្យប្រជាពលរដ្ឋទៅធ្វើការព្រឹកវិលល្ងាច និងជួយរកការងារឲ្យពួកគាត់បានធ្វើ និងបានប្រាក់កម្រៃ គ្រាន់ដោះស្រាយជីវភាពប្រចាំថ្ងៃ។

ដោយឡែក បើតាមប្រភពមច្បាស់ការ ពីប្រជាពលរដ្ឋបានសរសើរ និងថ្លែងអំណរគុណដល់សមត្ថកិច្ចដែលឈរជើងនៅទីនោះ មានកិច្ចសហការល្អរវាងប្រទេសជិតខាង និងមានការយោគយល់គ្នាទៅវិញទៅមក យកចិត្តទុកដាក់ ដល់ប្រជាពលរដ្ឋឲ្យមានការងារធ្វើ ដើម្បី បានប្រាក់កម្រៃខ្លះ ដើម្បីដោះស្រាយជីវភាពក្នុងគ្រួសារ។ គួរបញ្ជាក់ផងដែរ ប្រជាពលរដ្ឋដែលមកធ្វើការ ព្រឹកវិលល្ងាច មកពីស្រុកភូមិឃុំផ្សេងៗគ្នា សរុបក្នុងមួយថ្ងៃៗមានចំនួនមនុស្សទៅធ្វើការប្រមាណពី៥០០ ទៅ ៦០នាក់ក្នុងមួយថ្ងៃៗ៕ ដោយ ៖ សុផល

## បរទេសរហូតដល់ជាង១៣ម៉ឺននាក់ ដាក់ពាក្យសុំធ្វើការនៅកម្ពុជា

https://kohsantepheapdaily.com.kh/ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩ ម៉ោង ១៦:៥៣ រ័ត្ន ធីយ៉ា

ក្រសួងមហាផ្ទៃបាននិយាយថា ពលករបរទេសចំនួន១៣៥០០០នាក់ បានដាក់ពាក្យសុំធ្វើការងារនៅក្នុងប្រទេសកម្ពុជា កាលពីឆ្នាំ២០១៨ ។ របាយការណ៍ដែលកោះសន្តិភាពទទួលបាននោះបានអោយដឹងទៀតថា បើប្រៀបធៀបនឹងឆ្នាំ២០១៧ ចំនួននេះ វាមានការកើនឡើងច្រើនដោយក្នុងឆ្នាំ២០១៧ មានតែចំនួន៧៨២០០នាក់ប៉ុណ្ណោះ។ តាមរយៈរបាយការណ៍នោះ ក្រសួងមហាផ្ទៃបាននិយាយថា ចំនួននេះមានត្រឹមតែប្រហែល៣៧ភាគរយ ប៉ុណ្ណោះ បើប្រៀបធៀបនឹងចំនួនជនបរទេស៣៦០ ៥៤០នាក់ ដែលបានសុំពន្យារទិដ្ឋាការបន្តរយៈពេលស្នាក់នៅក្នុងប្រទេសកម្ពុជា ដែលអាចអោយពួកគេស្វែងរកការងារធ្វើនៅកម្ពុជា ។ របាយការណ៍នោះមិនបានប្រាប់ថា តើជនបរទេសមកពីប្រទេសណាខ្លះនោះទេ ។ ប៉ុន្តែការសង្កេតឃើញជាទូទៅនោះ កម្មករចិនមានកាន់តែច្រើននៅក្នុងប្រទេសកម្ពុជា ពិសេសនៅ ក្រុងព្រះសីហនុ ខណៈដែលចិនបានធ្វើការវិនិយោគកាន់តែច្រើន នៅក្នុងប្រទេសកម្ពុជា ជាពិសេសលើវិស័យសំណង់ ។

## ពលករខ្មែរបំរើការងារក្នុងប្រទេសថៃចាប់ផ្តើមធ្វើដំណើរវិលត្រឡប់ទៅលេងស្រុកកំណើត

https://www.facebook.com/OfficialPheaktra/ By Pheaktra Prak 28/03/2019

ប្រទេសថៃ ៖យោងតាមរបាយការណ៍ពីកម្លាំងអន្តោប្រវេសន៍ ស្រុកអារញ្ញប្រាថេត ខេត្តស្រះកែវ ប្រទេសថៃបានអោយដឹងថា នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី២៨ ខែមីនា ឆ្នាំ២០១៩នេះមានពលករខ្មែរបម្រើការងារទូទាំងប្រទេសថៃជាច្រើនអ្នកបានធ្វើដំណើរវិលត្រឡប់ទៅលេងស្រុកកំណើតក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិប្រចាំឆ្នាំ២០១៩នេះ តាតាមរយៈជើងរថភ្លើង ពីទីក្រុងបាងកកមកស្រុកអារញ្ញប្រាថេត ប្រមាណជាង០៦នាក់ ក្នុងការត្រួតពិនិត្យសណ្តាប់ធ្នាប់ និងឯកសារចេញ-ចូល របស់ពលករទាំងអស់កម្លាំងសមត្ថកិច្ចអន្តោប្រវេសន៍ ស្រុកអារញ្ញប្រាថេត

បានរកឃើញពលករខុសច្បាប់ចំនួន០៤នាក់ ដែលលាយឡំធ្វើដំណើរជាមួយពលករស្របច្បាប់ដ៏ទៃទៀត សមត្ថកិច្ចថៃបានធ្វើការឃាត់ខ្លួនដើម្បីសាកសួរ និងចាត់វិធានការណ៍តាមផ្លូវច្បាប់ប្រទេសថៃ ។

## ពីដើមឆ្នាំ២០១៩រហូតមកដល់ពេលនេះ ពលករចំណាកស្រុកខុសច្បាប់ជិត៥០០នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនមកមីយ៉ាន់ម៉ាវិញ

http://www.freshnewsasia.com/ 2019-03-28

**(រ៉ង់ហ្គូន)៖** ថ្មីៗនេះពលករចំណាកស្រុកខុសច្បាប់ជាជនជាតិមីយ៉ាន់ម៉ាចំនួន៦០នាក់ទៀត ត្រូវបានបញ្ជូនមកកាន់មាតុភូមិវិញ នៅក្រោមកិច្ចព្រមព្រៀងរវាងអាជ្ញាធរថៃនិងមីយ៉ាន់ម៉ា។ នេះបើតាមការដកស្រង់ការផ្សាយចេញពីទីភ្នាក់ងារព័ត៌មានចិន ស៊ីនហួរ នៅយប់ថ្ងៃព្រហស្បតិ៍ ទី២៨ ខែមីនា ឆ្នាំ២០១៩។ បើតាមការឲ្យដឹងពីក្រសួងការងារនិងអន្តោប្រវេសន៍ នៃប្រទេសមីយ៉ាន់ម៉ានថ្ងៃព្រហស្បតិ៍នេះ ដោយសារតែទិដ្ឋាការរបស់ពួកគេ បានផុតសុពលភាពហើយនោះ ពលករចំណាកស្រុកមីយ៉ាន់ម៉ាទាំង៦០នាក់ខាងលើ ក្នុងនោះមានស្ត្រី០៧នាក់ ត្រូវបាននាយកដ្ឋានអន្តោប្រវេសន៍ខេត្ត Ranong ភាគនិរតីប្រទេសថៃ បញ្ជូនត្រឡប់មកប្រទេសកំណើតវិញកាលពីថ្ងៃអង្គារ តាមច្រកព្រំដែន Kwathoung នៅរដ្ឋ Kayin។

គួរជម្រាបថា គិតចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ពលករចំណាកស្រុកខុសច្បាប់សរុប៤២៨នាក់ (សរុបទាំងថ្ងៃអង្គារទៀតជិត៥០០នាក់) ក្នុងនោះ មានស្ត្រី១៤៦នាក់និងកុមារ១៩នាក់ ត្រូវបានបញ្ជូនពីថៃមកកាន់មីយ៉ាន់ម៉ាវិញ។ ពលករចំណាកស្រុកមីយ៉ាន់ម៉ាភាគច្រើនមកពីតំបន់ Tanintharyi និង Ayeyarwady ក្រុងរ៉ង់ហ្គូន និង ក្រុង Bago ព្រមទាំងរដ្ឋ Mon និង Rakhine ហើយពួកគេមួយចំនួនធំធ្វើការ ងារក្នុងផ្នែកនេសាទ សំណង់ វាយណភណ្ឌ និងតាមផ្ទះ។ មួយចំណែកធំនៃជនអន្តោប្រវេសន៍នៅប្រទេសថៃ គឺជាពលករចំណាក ស្រុក មីយ៉ាន់ម៉ា៕

គួរជម្រាបថា គិតពីថ្ងៃទី០១ ខែមករា ដល់សប្តាហ៍ចុងក្រោយនេះ ខែមីនា ពលករចំណាកស្រុកខុសច្បាប់សរុប៤៨៨នាក់ហើយ ក្នុងនោះមានស្ត្រី១៥៣នាក់ និងកុមារ១៩នាក់ ត្រូវបានបញ្ជូនពីថៃមកកាន់មីយ៉ាន់ម៉ាវិញ។ ពលករចំណាកស្រុកមីយ៉ាន់ម៉ាភាគច្រើន មកពីតំបន់ Tanintharyi និង Ayeyarwady ក្រុងរ៉ង់ហ្គូន និង ក្រុង Bago ព្រមទាំងរដ្ឋ Mon និង Rakhine ហើយពួកគេមួយចំនួនធំ ធ្វើការងារក្នុងផ្នែកនេសាទ សំណង់ វាយណភណ្ឌ និងបម្រើការតាមផ្ទះ ខណៈមួយចំណែកធំនៃជនអន្តោប្រវេសន៍នៅប្រទេសថៃ គឺជាពលករចំណាកស្រុកមីយ៉ាន់ម៉ា៕